ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ផលវិជ្ជមានរបស់សាលាក្តីខ្មែរក្រហម

◆ ចាប់ពីរបបខ្មែរក្រហម ដល់ឧទ្ទវហេតុ ហាំ បាលី

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៧៩ ខែវិច្ឆិកា ឆ្នាំ២០១៤

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៧៩ ខែវិច្ឆិកា ឆ្នាំ២០១៤

## មាតិកា

◆ ផលវិជ្ជមានរបស់សាលាក្តីខ្មែរក្រហម ..................................................១

**ផ្នែកឯកសារ**

◆ ១៨ឆ្នាំ ក្នុងព្យុះសង្ឃរានៃមហាចលនាបដិវត្តន៍...................................៤

◆ សេចក្តីប្រកាសព័ត៌មានឯកសារ បានមកពីប្រភព............................១១

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ខ្មែរសុរិន្ទក្នុងចលនាបដិវត្តន៍ ......................................................១២

◆ ប្រាក់ សុខា : អង្គការដកសេចក្តីទុកចិត្ត ......................................១៤

◆ អ៊ុង វ៉ែន អតីតប្រធានវរសេនាធំ៨២ .........................................១៦

◆ ចាប់ពីរបបខ្មែរក្រហម ដល់ខប្បទ្ទវហេតុ ហាំ បាលី .......................១៧

**ផ្នែកច្បាប់**

◆ របាយការណ៍សន្និដ្ឋានស្តីពីបទពិសោធសង្កេតការណ៍ .........................២៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការឆ្លើយតបទៅអត្ថបទ វ៉េនឌុល ដឺហ្វាលកូ ....................................៤១

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ សុខ រ៉េត អតីតកម្មកររោងចក្រថ្មពិល ..........................................៤៤

◆ យុត្តិធម៌ពិតជាមានសម្រាប់ជនរងគ្រោះ ........................................៤៦

◆ អ្នករួចរស់ជីវិតពីរបបខ្មែរក្រហម ...............................................៤៨

◆ ការកម្ទេចខ្មាំងរបស់អង្គការ ..................................................៥៨



ក្មេងស្រីវិលមកស្រុកកំណើត ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្មេរលេខនេះ*** : រី លក្ខិណា, អេង កុកថាយ, លឹម ជ័យទត្ត, ឌី សុជាតា, ទូន ឡៃហ៊ុល, ម៉ៃឃើល កាណាវ៉ាស, អ៊ុច ស៊ុនឡាយ, ហេង កុសល ***អ្នកនិពន្ធនិងស្រាវជ្រាវ*** : ទាវ សារៈមុនិន្ទ ***អ្នកបកប្រែ*** : សយ សូលីដា ***និពន្ធនាយកទូទៅ*** : ឆាំង យុ ***ជំនួយការនិពន្ធនាយក*** : សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ*** : សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ*** : ឆេង វ៉េង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ផលវិជ្ជមានរបស់សាលាក្តីខ្មែរក្រហម

យើងបានធ្វើដំណើរយ៉ាងវែងឆ្ងាយក្នុងការបង្កើតឲ្យមានគោលនយោបាយ និងមធ្យោបាយដ៏មានតម្លៃជាច្រើនដើម្បីបំពេញមុខងារដោះស្រាយបញ្ហាអំពើហិង្សា និងអំពើឃោរឃៅ និងដើម្បីដាក់ទោសទណ្ឌដល់ជនទាំងឡាយណាដែលបានប្រព្រឹត្តអំពើបែបនេះ ។ ដោយទទួលស្គាល់ថា ឫសគល់ដែលបង្កឲ្យមានអំពើឃោរឃៅតែងតែមានប្រភពចេញពីភាពមិនស្មើភាពគ្នារបស់សមាជិកក្នុងក្រុមណាមួយ យើងបានប្រើយន្តការទិដ្ឋភាពច្បាប់ និងរដ្ឋាភិបាលដើម្បីជាយុទ្ធសាស្ត្រក្នុងការទប់ស្កាត់អំពើហិង្សា ។ ក្នុងន័យដាក់ទោសទណ្ឌនេះដែរ តុលាការជាច្រើនប្រភេទត្រូវបានបង្កើតឡើងដើម្បីផ្តល់ជាពន្លឺដល់សកម្មភាពព្រៃផ្សៃនៃរបបខ្ក្រិដ្ឋ និងដាក់ទោសមេដឹកនាំជាន់ខ្ពស់ដែលទទួលខុសត្រូវខ្ពស់បំផុត ។

ការកាត់ទោសដែលកំពុងតែដំណើរការ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ សាលាក្តីខ្មែរក្រហម គឺជាឧទាហរណ៍មួយដែលប្រជាជនកម្ពុជាជ្រើសរើសដើម្បីដោះស្រាយ ទៅនឹងបទឧក្រិដ្ឋដែលបានញាំញីប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ - ១៩៧៩ ។ តុលាការខ្មែរក្រហមនេះបានបង្កើតឲ្យមានបួនសំណុំរឿង ។ សំណុំរឿងដែលបានបញ្ចប់ជាស្ថាពរ កាលពីឆ្នាំ២០១១កន្លងទៅ ផ្តោតសំខាន់ទៅលើការកាត់ទោសអតីតប្រធានមន្ទីរសន្តិសុខស-២១ ដែលត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ថ្មីៗនេះដែរ សាលាក្តីខ្មែរក្រហមបានចេញសាលក្រមក្នុងសំណុំរឿង ០០២ ដំណាក់កាលទី១ ទៅលើជនជាប់ចោទដែលជាអតីតមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ។ សំណុំរឿង០០២ ដែលត្រូវចែកជាដំណាក់កាលផ្សេងៗពីគ្នាទៀតនោះ បង្ហាញឲ្យឃើញការចោទប្រកាន់ផ្សេងៗប្រឆាំងនឹងជនជាប់ចោទ គឺជាដំណើរការដ៏សំខាន់ក្នុងកិច្ចការតស៊ូដ៏វែងឆ្ងាយរបស់កម្ពុជាដើម្បីឲ្យយល់ច្បាស់ថា តើហេតុអ្វី និងអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណែកសំណុំរឿង០០៣ និង ០០៤ វិញ ឋិតក្នុងដំណាក់កាលស៊ើបអង្កេតនៅឡើយ ។

ខណៈពេលដែលតុលាការកំពុងមានកិច្ចការជាច្រើនដែលត្រូវបំពេញ យើងក៏ឃើញមានផលវិជ្ជមានជាច្រើននៅក្នុងសង្គមកម្ពុជាទាំងមូល ។ ផលវិជ្ជមានដ៏សំខាន់បំផុតមួយគឺថា សាលាក្តីនេះបានជំរុញឲ្យមានការពិភាក្សា និងលើកកម្ពស់ការយល់ដឹងជាច្រើន ។ ជាងសាមសិបឆ្នាំក្រោយរបបខ្មែរក្រហមដួលរលំ កម្ពុជានៅតែទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត និងស្លាកស្នាមពីសម័យខ្មែរក្រហម ។ វាជាការលំបាកណាស់សម្រាប់ក្មេងជំនាន់ក្រោយនាពេលបច្ចុប្បន្ននេះ ក្នុងការយល់ពីទិដ្ឋភាពនៃបទឧក្រិដ្ឋដែលបានកើតឡើងជាច្រើនឆ្នាំកន្លងទៅ ។ ស្រដៀងគ្នានេះដែរ ជនរងគ្រោះដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមផ្ទាល់ក៏មានការលំបាកក្នុងការលាតត្រដាងហេតុការណ៍ពិតប្រាកដ ដែលបានកើតឡើងចំពោះខ្លួនទៅកាន់ក្មេងជំនាន់ក្រោយដែរ ។ ខណៈពេលដែលសាលាក្តីខ្មែរក្រហមត្រូវបានរិះគន់ពីសំណាក់សាធារណជនទាក់ទងទៅនឹងភាពខ្វះខាតរបស់តុលាការ គ្មាននរណាម្នាក់បដិសេធទេថា សាលាក្តីនេះបានជំរុញឲ្យមានការពិភាក្សាអំពីប្រវត្តិពីអតីតកាលទេ ។

ប៉ុន្តែ ខណៈពេលដែលសាលាក្តីនេះកំពុងធ្វើកិច្ចការដ៏សំខាន់សម្រាប់ផ្តល់នូវភាពយុត្តិធម៌ យើងទាំងអស់គ្នាក៏ត្រូវមានភាពច្បាស់លាស់ដែរនូវអ្វីដែលសាលាក្តីនេះអាចផ្តល់ឲ្យបាន ។ នៅពេលដែលយើងប្រឹងប្រែងស្វែងរកមើលជម្រើសណាមួយដើម្បីដោះស្រាយបញ្ហាពីអតីតកាលសម្រាប់ប្រទេសក្រោយជម្លោះឲ្យធូរស្បើយឡើងវិញ យើងតែងតែជ្រើសយកវិធីដែលផ្តោតទៅលើការដាក់ទោសដល់ជនដែលប្រព្រឹត្តបទល្មើស ។ មានការយល់ស្របរួមមួយក្នុងការចាប់យកជម្រើសមួយនេះ ពីព្រោះវិធីសាស្ត្រដាក់ទោសទណ្ឌដល់ជនប្រព្រឹត្តបទល្មើស បានផ្តល់លទ្ធផលដែលអាចវាស់បាននៅក្នុងសណ្ឋានជាការកាត់ក្តី និងការដាក់ទោស ហើយវិធីនេះក៏អាចបំពេញតម្រូវការរបស់យើងក្នុងការយល់នូវមូលហេតុ និងបុព្វហេតុដែលបានកើតឡើងពីអតីតកាល ។ ក៏ប៉ុន្តែ ខណៈពេលដែលតុលាការផ្តល់នូវតម្លៃយ៉ាងវិសេសតាមរយៈការផ្តល់ការពិត

ចំពោះភាពមន្ទិល និងការបង្ហាញឲ្យឃើញនូវឫសគល់នៃពិរុទ្ធភាពរបស់បុគ្គលដែលបានប្រព្រឹត្តបទឧក្រិដ្ឋ យើងក៏ទទួលស្គាល់ដែរថា តុលាការមានដែនកំណត់របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចក្នុងការស្វែងយល់អំពីប្រវត្តិ និងវប្បធម៌ដែលជំរុញ និងបង្កឲ្យមានអំពើហិង្សានិងអំពើឃោរឃៅ ។

នេះមិនមែនជាបញ្ហាតូចតាចដែលត្រូវមើលស្រាលទេ ។ អំពើហិង្សាទ្រង់ទ្រាយធំមិនមែនកើតឡើងដាច់ដោយឡែកពីប្រវត្តិសាស្ត្រ និងវប្បធម៌ទេ ។ ខណៈពេលដែលការដាក់ទោសជនដែលទទួលខុសត្រូវ គឺជាតម្រូវការដ៏ចាំបាច់មួយ វាក៏សំខាន់ដែរដែលសង្គមទាំងមូលត្រូវធ្វើកិច្ចការមួយចំនួនទៀតដែលមិនតម្រូវឲ្យមានបែបបទលំដាប់លំដោយណាមួយទេ ។ ការប្រកាន់ពូជសាសន៍ ការប្រកាន់បក្សពួក ការសម្លុតធ្វើបាប និងអំពើអមនុស្សធម៌ជាច្រើនដែលបង្កឲ្យមានវប្បធម៌ហិង្សាប្រឆាំងនឹងក្រុមមនុស្សផ្សេងទៀត ក៏ត្រូវយកមកពិចារណាដែរ ។ តើយើងត្រូវធ្វើកិច្ចការនេះដោយរបៀបណា? តើយើងអាចកាត់ទោសសង្គម និងវប្បធម៌ទាំងមូលបានទេ? ប្រសិនបើយើងធ្វើការស៊ើបអង្កេតក្នុងន័យបង្កើតទម្រង់នៃការដាក់ទោសទណ្ឌ និងទម្រង់ផ្លូវច្បាប់ផ្សេងទៀត យើងនៅតែដាក់ខ្លួនយើងក្នុងកម្រិតដែលមានដែនកំណត់ដដែល ដែលតុលាការអាចផ្តល់ឲ្យយើង ឬក៏បេសកកម្មស្វែងរកការពិត ។ ជាជាងទាមទារភាពយុត្តិធម៌ យើងក៏ទាមទារឲ្យមានការអប់រំអំពីអតីតកាលដែរ ។ ការអប់រំពីអំពើប្រល័យពូជសាសន៍ ក៏ជាចំណុចឧកញ្ចនមួយនៅក្នុងយុទ្ធនាការរបស់យើងក្នុងការបង្កើតជាវប្បធម៌មួយដែលផ្តល់តម្លៃដល់បុគ្គល និងសិទ្ធិមនុស្ស ។

ការអប់រំពីអំពើប្រល័យពូជសាសន៍ អាចជាវិធីសាស្ត្រមួយសម្រាប់ទទួលបាននូវភាពយុត្តិធម៌ ការផ្សះផ្សាជាតិ ការចងចាំ និងពិសេសជាងនេះទៅទៀតគឺផ្តល់នូវសមានចិត្តដល់មនុស្សជាតិទាំងមូល ។ ខណៈពេលដែលការអប់រំពីអំពើប្រល័យពូជសាសន៍មិនមែនជាឧសថកែរោគតែមួយមុខសម្រាប់ដោះស្រាយបញ្ហាក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ តែការអប់រំគឺជាវិធីសាស្ត្រមួយដែលគួរតែទទួលបាននូវការចាប់អារម្មណ៍កាន់តែច្រើន ។

វាជារឿងមួយងាយស្រួលសម្រាប់យើង ដោយគ្រាន់តែនិយាយក្នុងសេចក្តីថ្លែងសុន្ទរកថា យើងគាំទ្រឲ្យមានការអប់រំពីអំពើប្រល័យពូជសាសន៍ និងជំរុញឲ្យមានការពិភាក្សាក្នុងគ្រប់កាលៈទេសៈ ប៉ុន្តែ វាបែរជារឿងមួយពិបាកក្នុងការធ្វើឲ្យសេចក្តីប្តេជ្ញាចិត្តនេះលេចរូបរាងឡើងនៅក្នុងកាលៈទេសៈខ្វះក្នុងប្រទេសជាក់លាក់មួយចំនួន ។ ឧទាហរណ៍ មកទល់សព្វថ្ងៃនេះ ប្រទេសអាមេនីនៅតែជាប្រធានបទពិបាកលើកឡើងក្នុងមជ្ឈដ្ឋានមួយចំនួន ហើយខ្ញុំសួរថានេះបណ្តាលមកពីមូលហេតុអ្វី? ប្រសិនបើយើងពិតជាប្តេជ្ញាចិត្តចំពោះបូជនីយកិច្ចជាសកលប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅ តើមូលហេតុអ្វីបានជាយើងមើលរំលង ឬក៏បង្កើតឲ្យមានករណីលើកលែងសម្រាប់ប្រទេសនិងប្រធានបទជាក់លាក់មួយចំនួន ។ ចំណុចរសើបផ្នែកនយោបាយ និងវប្បធម៌តែងតែជាអ្វីដែលយើងយកមកពិចារណានៅក្នុងការស៊ើបអង្កេត ការពិភាក្សា និងការអប់រំពីបញ្ហាមនុស្សជាតិរបស់យើង ប៉ុន្តែយើងមិនគួរឲ្យចំណុចរសើបទាំងអស់នេះប៉ះពាល់ដល់ការប្តេជ្ញាចិត្តរបស់យើងក្នុងការស្វែងរកការពិត ឬយកឈ្នះការតាំងចិត្តទាមទារឲ្យមានភាពស្មោះត្រង់ និងការយល់ដឹងជាសាធារណៈទេ ។ ក៏ដូចគ្នាដែរ តើប្រទេសមួយអាចអះអាងថា ខ្លួនមានសេចក្តីក្លាហានទទួលខុសត្រូវចំពោះបញ្ហានានា ដែលកើតឡើងនាពេលបច្ចុប្បន្ន និងអនាគតបានយ៉ាងដូចម្តេច នៅពេលដែលប្រទេសនេះមិនទាំងមានសេចក្តីក្លាហានហ៊ានប្រឈមមុខនឹងអតីតកាលរបស់ខ្លួនផង?

ការអប់រំគឺជាមធ្យោបាយ តែមួយគត់ដែលអាចយកឈ្នះភាពភ័យខ្លាចនេះបាន ។ ជាការពិត មានកម្មវិធីកសាងសន្តិភាពជាច្រើនប្រភេទដែលប្រទេសក្រោយជម្លោះជាច្រើនបានយកមកអនុវត្ត ហើយការសិក្សាពីអំពើប្រល័យពូជសាសន៍តែងតែជាកម្មវិធីដ៏សំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការបង្កើតឲ្យមានភាពពេញលេញនៃសិទ្ធិមនុស្ស និងសមានចិត្តពីប្រវត្តិសាស្ត្រ ។ ប៉ុន្តែ ដើម្បីឲ្យមានប្រសិទ្ធភាព ការអប់រំពីអំពើប្រល័យពូជសាសន៍ត្រូវតែធ្វើឡើងដោយអនុលោមតាមវប្បធម៌ក្នុងតំបន់ ។ កម្មវិធីសិក្សាក្នុងកម្រិតវប្បធម៌ក្នុងតំបន់គឺជាកម្មវិធីមួយដែលស៊ីគ្នា និងវប្បធម៌ក្នុងស្រុក ការបង្រៀនបែបវប្បធម៌របស់អ្នកស្រុក ហើយសំខាន់ជាងនេះទៅទៀតនោះ គឺការសិក្សាពីប្រវត្តិរបស់ភូមិស្រុកនោះផ្ទាល់ ។ ការអប់រំពីអំពើប្រល័យពូជសាសន៍ ដែលតាក់តែងឡើងដោយបរទេស ដោយយកប្រវត្តិ វប្បធម៌ និងគរុកោសល្យ

របស់ប្រទេសផ្សេងមកបង្រៀនប្រៀបដូចជាការដាក់សម្ពាធដូចទៅនឹងសម្ពាធដែលបានកើតឡើងក្នុងរបបឃោរឃៅដូច្នោះដែរ ។ សិទ្ធិមនុស្ស សមានចិត្ត និងការយោគយល់ពីភាពខុសគ្នា គឺជាតម្លៃមួយដែលអាចនិយាយបានពេលដែលបុគ្គលនីមួយៗមានការទុកចិត្តគ្នាដោយសេរីភាព និងការទទួលខុសត្រូវដើម្បីរៀនដោយខ្លួនឯង ។

ក្នុងបុព្វហេតុនេះ ការអប់រំពីអំពើប្រល័យពូជសាសន៍គឺជាការអប់រំមួយដែលត្រូវបង្កើតឡើង ដោយសហគមន៍អ្នករៀន មិនមែនបង្កើតឡើងសម្រាប់សហគមន៍នោះទេ ។ វិធីសាស្ត្រនៃការអប់រំបែបវប្បធម៌ក្នុងតំបន់នេះមិនមែនជាកិច្ចការងាយស្រួលក្នុងការបង្កើតទេ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានតស៊ូយ៉ាងស្វិតស្វាញដើម្បីបង្កើតកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍របស់ខ្លួនតាំងពីឆ្នាំ២០០៤មក ។ ប្រវត្តិសាស្ត្រខ្មែរក្រហម ឬរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្រៀន និងអាក់ខានមកវិញអស់រយៈជាច្រើនឆ្នាំកន្លងមកនេះ ។ ប៉ុន្តែ ក្នុងឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយក្រោយមក ក្នុងឆ្នាំ២០០៩ មជ្ឈមណ្ឌលបានបណ្តុះបណ្តាលគ្រូបង្គោល ទូទាំងប្រទេសទាក់ទងទៅនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ។

ចាប់តាំងពីឆ្នាំ២០០៧មក សៀវភៅជាងប្រាំសែនក្បាលត្រូវបានបោះពុម្ព និងចែកចាយដល់សាលាមធ្យមសិក្សាទូទាំងប្រទេស ហើយគ្រូបង្គោលជាងបីពាន់នាក់ ត្រូវបានបង្រៀនពីវិធីសាស្ត្របង្រៀនរបបកម្ពុជាប្រជាធិបតេយ្យ ។ នាពេលបច្ចុប្បន្ននេះប្រវត្តិសាស្ត្រខ្មែរក្រហម គឺមុខវិជ្ជាតម្រូវការសម្រាប់សាលាមធ្យមសិក្សា ហើយមុខវិជ្ជានេះនឹងក្លាយជាមុខវិជ្ជាតម្រូវការសម្រាប់មហាវិទ្យាល័យ និងសាលាបណ្ឌិតសភានគរបាល និងសាលាយោធា ។ ផលលំបាកក្នុងការបង្កើតយុទ្ធសាស្ត្រទប់ស្កាត់របបប្រល័យពូជសាសន៍ឲ្យស៊ីគ្នាទៅនឹងវប្បធម៌ក្នុងតំបន់តាមរយៈការអប់រំ មិនមែនជារឿងងាយស្រួលទេ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជានៅមានកិច្ចការមួយចំនួនទៀតដែលត្រូវបំពេញ ។ ក៏ប៉ុន្តែតម្លៃនៃការអប់រំពីរបបប្រល័យពូជសាសន៍ក្នុងន័យលើកកម្ពស់យុត្តិធម៌ ការផ្សះផ្សាជាតិ និងការចងចាំសម្រាប់ជាតិ គឺជាកិច្ចការមួយមិនអាចបំភ្លេចបានទេ ។ ដោយសារតែមូលហេតុនេះ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងតែប្រែខ្លួនទៅជាវិទ្យាស្ថានស្លឹករឹត ដែលជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍ សម្រាប់ការចងក្រងឯកសារការអប់រំ និងការស្រាវជ្រាវ ។

មានទីតាំងនៅរាជធានីភ្នំពេញ វិទ្យាស្ថានស្លឹករឹតនឹងក្លាយទៅជាទីកន្លែងអចិន្ត្រៃយ៍ ដែលតម្កល់ឯកសារទាក់ទងនឹងអំពើប្រល័យពូជសាសន៍ច្រើនជាងគេនៅអាស៊ីអាគ្នេយ៍ ។ ឯកសារជាងមួយលានទំព័រ ត្រូវបានរក្សាទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ស្លឹករឹត ដែលជាឈ្មោះនៃវិទ្យាស្ថាននេះ មានន័យថា "អំណាចនៃស្លឹកឈើ" គឺសំដៅទៅលើស្លឹកឈើស្ងួត ដែលបញ្ញវន្តខ្មែរធ្លាប់ប្រើដើម្បីចាររាល់រឿងរ៉ាវទាំងឡាយទុកជាឯកសារ និងប្រើប្រាស់ដើម្បីផ្ទេរចំណេះដឹង និងវប្បធម៌ ក្នុងអំឡុងសម័យជិះជាន់ ។

សិទ្ធិមនុស្សនិងប្រវត្តិសាស្ត្រទាក់ទងគ្នាទៅវិញទៅមក ព្រោះយើងមិនអាចយល់ពីបញ្ហាសិទ្ធិមនុស្ស ដោយមិនលើកយកប្រវត្តិសាស្ត្រមកនិយាយបានទេ ហើយក៏មិនអាចនិយាយពីប្រវត្តិសាស្ត្រ ដោយមិនលើកយកបញ្ហាសិទ្ធិមនុស្សមកនិយាយដែរ ។ ដើម្បីធ្វើឲ្យកិច្ចការទប់ស្កាត់អំពើប្រល័យពូជសាសន៍ឲ្យមានស្ថិរភាពពិតប្រាកដ កិច្ចការនេះមិនសុទ្ធតែចាំឲ្យមានការទទួលស្គាល់ជាសាកលក្នុងកម្រិតអន្តរជាតិទេ តែត្រូវតែឲ្យមានការទទួលស្គាល់ក្នុងតំបន់ ។ ការអប់រំត្រូវតែជាដំណើរទៅមុខបន្ទាប់ក្នុងកិច្ចការសមូហភាពរបស់យើងដើម្បីឲ្យយល់ដឹងពីពិភពលោកមួយដែលគ្មានអំពើប្រល័យពូជសាសន៍ និង អំពើហិង្សា ។

**ឆាំង យុ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* . ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ១៨ឆ្នាំ ក្នុងព្យុះសង្ឃ្រានៃមហាចលនាបដិវត្តន៍កម្ពុជា ក្រោមទង់ក្រហមឆ្អិនឆ្អៅមានជ័យជាដរាបរបស់ បក្សកុម្មុយនីស្តកម្ពុជា

***"ឯកសារទង់បដិវត្តន៍លេខ៨ ខែសីហា ឆ្នាំ១៩៧៨ D២១៤៣០"***

*១៨ឆ្នាំ! ១៨ឆ្នាំ ក្នុងព្យុះសង្ឃ្រានៃមហាចលនាបដិវត្តន៍កម្ពុជា ក្រោមទង់ក្រហមឆ្អិនឆ្អៅមានជ័យជាដរាបរបស់បក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាង ប្រជាជនកម្ពុជា៨លាននាក់ក្តាប់អាវុធណែនក្នុងដៃ ធ្វើដំណើរឆ្លងកាត់យ៉ាងរូតរះចេញពីដំណាក់កាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ រលះរលាំងខំស្រូតចូលក្នុងដំណាក់កាលនៃបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ។ ១៨ឆ្នាំ ក៏ពិតមែន តែហាក់ដូចជានៅថ្មីៗនេះសោះ ។ អ្វីៗនៅចាំព្រោះជាដំណើរប្រវត្តិសាស្ត្រក្នុងយុគសម័យថ្មីរបស់ជាតិកម្ពុជា ប្រជាជនកម្ពុជា វណ្ណៈកម្មករ កសិករកម្ពុជា ដែលមានបក្សកុម្មុយនីស្តកម្ពុជានាំមុខ ។*

*យប់នោះ ថ្ងៃ២៨ ខែ៩ ឆ្នាំ១៩៦០ គឺ១៨ឆ្នាំកន្លងមកហើយ បណ្តាសមមិត្តជាតំណាងបក្ស ពីជនបទ និងទីក្រុង បានចូលមកជួប*



*យោធាខ្មែរក្រហមប្រយុទ្ធ នៅសមរភូមិមុខ*

ជុំក្នុងបន្ទប់នៃមហាសន្និបាតបក្ស ដោយស្ងៀមស្ងាត់ ប្រុងប្រយ័ត្ន តែពោរពេញដោយក្តីរីករាយជ្រះថ្លា ជឿជាក់លើជ័យជម្នះរបស់មហាសន្និបាតបក្សខ្លួនយ៉ាងមុតមាំ ។

ភ្នំពេញ ធានីនៃកម្ពុជា ពាក់កណ្តាលអាណានិគម ពាក់កណ្តាលសក្តិភូមិ នាកាលនោះ តើអ្នកណាឡើយនឹកស្មានថា ត្រឹមតែ១៥ឆ្នាំប៉ុណ្ណឹង ភ្នំពេញក្លាយមកជារាជធានីនៃកម្ពុជាប្រជាធិបតេយ្យ ទៅវិញ? ។ ភ្នំពេញនេះហើយ ហើយជាពិសេស គឺមូលដ្ឋានមិត្តកម្មកររថភ្លើងដែលបានទទួលកិត្តិយសបើកមហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជាលើកទី១ ។

ខាងក្រៅបរិវេណ ពួកគិញ ប៉ូលីស ទាហាន ទាំងចំហ ទាំងសម្ងាត់ ដើរខ្វាត់ខ្វែង ស្វះស្វែងរកកម្មុចចលនាខ្មែរក្រហម ។ ខ្មាំងវាធ្វើការវា បដិវត្តន៍ធ្វើការបដិវត្តន៍ ។

មហាសន្និបាត បានប្រព្រឹត្តទៅយ៉ាងឱឡារិក អស់ពេល៣ថ្ងៃក្នុងបរិយាកាសសាមគ្គី ឯកភាព ។ បៀតភ្លឺថ្ងៃ៣០ ខែ៩ មហាសន្និបាតបានបញ្ចប់ដោយជោគជ័យ ដោយឯកភាពគ្នាជាធ្លុងមួយ អំពីមាគ៌ាជាយុទ្ធសាស្ត្រ យុទ្ធវិធី អំពីលក្ខន្តិកៈបក្ស និងចាត់តាំងគណៈមជ្ឈិមបក្សដឹកនាំ ។ មហាសន្និបាត ធ្វើពិធីគោរពទង់បក្សបិទ «ក្រោកឡើងអស់អ្នកខ្ញុំគេទាំងប៉ុន្មាន ក្រោកឡើងអស់អ្នកគោកយ៉ាករាល់ប្រាណ» បានបន្លឺឡើងយ៉ាងគ្រលួចនៅក្នុងបេះដូងយើងម្នាក់ៗ ។ ពន្លឺស្រាងៗចាប់ផ្តើមចែងចាំងពីទិសបូព៌ា ជួយជំរុញទឹកចិត្តអស់អ្នកខ្ញុំគេឲ្យក្រោកឈរឡើងយ៉ាងក្លៀវក្លា ហើយពន្លឺស្រាងៗនេះក៏ជាប្រផ្នូលនៃរស្មីដ៏ត្រចះត្រចង់ នៃមហាសន្និបាតបក្សលើកទី១ ដែលចាប់ផ្តើមរះចែងចាំងចាក់ចូលទៅតាមជនបទ ព្រៃភ្នំ ចុងកាត់មាត់ញកនិងទីក្រុង ដាស់ប្រជាជនកម្ពុជាទាំង៨លាននាក់ ឲ្យភ្ញាក់ក្រោកឈរឡើង តស៊ូបដិវត្តន៍រំដោះជាតិ រំដោះប្រជាជន ។

ប្រជាជនកម្ពុជាមានបក្សបដិវត្តន៍របស់ខ្លួនដឹកនាំហើយ! គឺបក្សកុម្មុយនីស្តកម្ពុជា ។

វិមាន ស របស់ចក្រពត្តិអាមេរិកចាប់ផ្តើមញ័ររំជួយហើយ! របបសក្តិភូមិ ម្ចាស់ដី នាយទុន នៅកម្ពុជាចាប់ផ្តើមរង្គោះរង្គើហើយ! ។ ផែនការ «សហព័ន្ធឥណ្ឌូចិន» របស់ខ្មាំងយួនឈ្លានពានចាប់ផ្តើមរលំរលាយហើយ!

សមមិត្តតំណាងទាំងអស់ម្នីម្នារិលត្រឡប់ទៅកាន់សមរភូមិប្រយុទ្ធរៀងៗខ្លួន ប្រៀបប្រដូចយុទ្ធជនកងវាយពិសេស បោះពួយចេញពីទីតាំង គ្រវីទង់ក្រហមយ៉ាងស្វាហាប់ នាំយករំសេវផ្ទុះរាប់ពាន់តោន ទៅវាយកម្ទេចបុស្តិ៍ប៉ុមខ្មាំង ។ គ្មានកម្លាំងអ្វីមកស្កាត់ទប់កម្លាំងមហាសាមគ្គីឯកភាពផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជាបានឡើយ ។ គ្មានកម្លាំងអ្វីមកស្កាត់កម្លាំងមហាសាមគ្គីរបស់ប្រជាជនកម្ពុជាទាំងមូល ដែលតាំងលើមូលដ្ឋាននៃសម្ព័ន្ធភាពកម្មករ កសិករក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានឡើយ ។

ឆ្នាំ១៩៦០-៦១-៦២-៦៣-៦៤-៦៥-៦៦-១៩៦៧ ចលនាបដិវត្តន៍កម្ពុជារីវត្តឡើងជាលំដាប់ ប្រែក្លាយពីបរិមាណមកគុណភាពកាន់តែខ្ពស់ ។

ទាំងជនបទ ទាំងទីក្រុង ចលនាតស៊ូប្រយុទ្ធរបស់ប្រជាជនស្ថិតក្នុងឋានៈ វាយសម្រុកខ្មាំងជាប់ តាមពាក្យស្លោកប្រជាជាតិប្រជាធិបតេយ្យ និងជីវភាព ។ ទំនាស់រវាងចក្រពត្តិអាមេរិក បរិវារវា និងប្រជាជាតិប្រជាជនចេះតែឡើង ។ ទំនាស់រវាងសក្តិភូមិម្ចាស់ដី និងកសិករចេះតែឡើង ។ ទំនាស់រវាង កម្មករ ប្រជាពលករ និងនាយទុន ចេះតែឡើង ។ ភ្លើងបដិវត្តន៍ដុតឆេះសន្ធោសន្ធៅដោយប្រជាជនខ្លួនឯង ។ ប្រជាជនយល់បដិវត្តន៍ ប្រជាជនជឿបដិវត្តន៍ ប្រជាជនធ្វើបដិវត្តន៍ដោយខ្លួនឯង ។

ឆ្នាំ១៩៦៧ ទំនាស់រវាងចក្រពត្តិអាមេរិក និងប្រជាជាតិកាន់តែឡើងខ្ពស់ ។ ប្រជាជនដែលបំពាក់នូវគោលជំហរហិង្សាបដិវត្តន៍ បំពាក់ឲ្យខ្លួននូវកាំបិត ពូថៅ ផ្គាក់ ដំបង ។ល ។ កងការពារសម្ងាត់របស់បក្ស ដែលបានរៀបចំបម្រុងទទួលសភាពការណ៍តាំងពីឆ្នាំ១៩៦០ មក ចាប់ផ្តើមធ្វើសកម្មភាពយាមល្បាត ការពារកម្មាភិបាល កម្ទេចគិញ ចារបុរស ដែលវាមកបំផ្លាញមូលដ្ឋានបដិវត្តន៍ បំផ្លាញប្រជាជនបំផ្លាញបក្ស ។ ឆ្នាំ១៩៦៧ សភាពការណ៍តស៊ូបដិវត្តន៍ខាងនយោបាយកាន់តែខ្លាំងក្លា ។ នៅជនបទប្រជាជនផ្ទុះហិង្សាអាវុធភ្លាម ។ តស៊ូអាវុធ ទាំងជាមួយចក្រពត្តិអាមេរិក ទាំងបរិវារ ទាំងជាមួយពួកសក្តិភូមិម្ចាស់ដី ដែលឃោរឃៅ ។ ដូច្នេះ សភាពការណ៍ឆ្នាំ១៩៦៧ វាទុំ ទាំងខាងនយោបាយ ទាំងខាងចលនា ទាំងខាងបំពាក់ហិង្សានយោបាយ និងអាវុធ ។

ចលនាខ្លាំងក្លា សតិអារម្មណ៍ ក៏រីកចម្រើនជឿនលឿន ។ សតិអារម្មណ៍វណ្ណៈ និងតស៊ូវណ្ណៈ បានពង្រឹង និងពង្រីកថែមទៀត ទាំង

ក្នុងជួរបក្ស ទាំងក្នុងជួរប្រជាជន។ សតិអារម្មណ៍បដិវត្តន៍ក្តៅគគុក ពុះពោរយ៉ាងនេះ បានជំរុញចលនាប្រយុទ្ធបដិវត្តន៍ឲ្យកាន់តែខ្លាំងក្លា ក្តៅគគុកថែមទៀត។ ដុតដំដាប់ក្នុងចលនាតស៊ូបដិវត្តន៍ជាបន្តបន្ទាប់យ៉ាងនេះ កម្មាភិបាល បក្ខជនកាន់តែជ្រួតជ្រាបមាគ៌ា កាន់តែអនុវត្តមាគ៌ាបានល្អ កាន់តែមានពិសោធធ្វើបដិវត្តន៍។ កម្មាភិបាល បក្ខជនទាំងចាស់ ទាំងថ្មី បានសាកល្បង ហើយធំធាត់ក្នុងចលនាប្រយុទ្ធជាទុនយ៉ាងមានតម្លៃបំផុតរបស់បក្ស។ ជួរបក្សកាន់តែប្រយុទ្ធ កាន់តែស្អាត កាន់តែខ្លាំង។ ជ័យជម្នះថ្មីមួយទៀត ក្នុងចលនាបដិវត្តន៍ឆ្នាំ១៩៦០-១៩៦៧នេះ គឺគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនក្តាប់វាសនាប្រទេសជាតិខ្លួន ដោយខ្លួនឯង បានពង្រឹង និងពង្រីក។ ចលនាបដិវត្តន៍បានបង្ហាញច្បាស់លាស់ថា ប្រជាជនខ្លាំងក្លាមហិមា បក្សមានសមត្ថភាពដឹកនាំប្រជាជន ដឹកនាំចលនាមហាជនធ្វើបដិវត្តន៍បាន ហើយធ្វើឈ្នះទៀត ទាំងជនបទ ទាំងទីក្រុង។ ប្រជាជនតស៊ូដោយហិង្សានយោបាយក៏បាន ដោយហិង្សាអាវុធក៏បាន វាយសម្រុកខ្លាំងជាបន្តបន្ទាប់ ទាំងសម្ងាត់ ទាំងចំហ គឺឈ្នះ។ ចលនាបដិវត្តន៍របស់មហាជនវាយសម្រុកខ្លាំងបានជ័យជម្នះ ការពារកម្លាំងបក្ស កម្លាំងបដិវត្តន៍បាន ហើយពង្រឹង និងពង្រីកកម្លាំងបក្ស កម្លាំងបដិវត្តន៍ បានជំរុញចលនាកាន់តែខ្លាំងក្លាថែមទៀត។ បក្ស និងប្រជាជន បានឯកភាពគ្នាជាធ្លុងមួយឆ្លងចលនាប្រយុទ្ធស្លាប់រស់ជាមួយគ្នាយ៉ាងនេះ កាន់តែជឿទុកចិត្តលើគ្នាទៅវិញទៅមក ហើយឃើញច្បាស់ថា ចលនាតស៊ូដោយអាវុធពិតជាដំណើរការបាន។

ឆ្នាំ១៩៦៨ រួសរាន់ទាន់សភាពការណ៍នៃចលនាប្រយុទ្ធរបស់មហាជន ដែលកំពុងដោរជន់ដូចទឹកជំនន់បាក់ទំនប់ហូរខ្លួលខ្លាញ់ពីជនបទចុងកាត់មាត់ញក ចាក់ត្របាញ់ មកប្រសព្វគ្នានៅទន្លេចតុមុខយ៉ាងនេះ បក្សកុម្មុយនីស្តកម្ពុជា បានសម្រេចថា ត្រូវតស៊ូនយោបាយផង អាវុធផង។ សេចក្តីសម្រេចចិត្តរបស់បក្សលាន់ឮរន្ទឺសព្វទិសទី។

«មិនតស៊ូអាវុធ មានតែស្លាប់»

«មិនតស៊ូអាវុធ មានតែស្លាប់»

នេះជាមតិរបស់កម្មាភិបាល បក្ខជន មហាជន។ មតិមួយជាសំឡេងអបអរទទួលអំណរ សេចក្តីសម្រេចចិត្តដ៏ត្រឹមត្រូវ ភ្លឺស្វាង និងទាន់ពេលវេលារបស់បក្ស។ មតិមួយទៀត ជាសំឡេងស្រែកគំហឹកសង្រ្កក ឲ្យបក្សយួនដែលវាប្រឆាំងនឹងការតស៊ូដោយអាវុធរបស់បក្សយើង។

ឆ្លើយតបយ៉ាងក្លៀវក្លា និងសេចក្តីសម្រេចចិត្តរបស់បក្ស ខែ១ ឆ្នាំ១៩៦៨ ផ្ទុះអាវុធនៅភូមិភាគពាយ័ព្យ។ ខែ២ ផ្ទុះនៅភូមិភាគនិរតី ខែ៣ ផ្ទុះនៅភូមិភាគបូព៌ា ចុងខែ៣ ផ្ទុះនៅឦសាន ខែ៤ ផ្ទុះនៅឧត្តរ។ ស្នូរកាំភ្លើងបដិវត្តន៍ឆ្លើយឆ្លងគ្នាជាបន្តពីភូមិភាគមួយទៅភូមិភាគមួយជាប់រដឹក។

៤ខែប៉ុណ្ណឹង បក្សយើងផ្ទុះអាវុធ១៧ខេត្ត ក្នុង១៩ខេត្ត



យោធាខ្មែរក្រហមប្រយុទ្ធ នៅសមរភូមិមុខ

នៃទូទាំងប្រទេស ។ ចលនាបដិវត្តន៍ យើងខ្លាំងក្លា ដូចព្យុះសង្ឃរា មែន ។ វិមាន ស កាន់តែរង្គោះរង្គើ តែមមាញឹករៀបចំធ្វើរដ្ឋប្រហារ រំលំកម្ពុជា ។

វណ្ណៈកាន់អំណាច វាប្រកាសថា វាយខ្មែរក្រហមឲ្យលៀន អណ្តាត តែក្រឡេកមើលលើកំពូលប្រាសាទ ឃើញលោកខែពណ៌ ខ្មៅរះចំពីលើ ។

ឯយួនភ្លីភ្លើដេកហួច វិនិច្ឆ័យថា ចលនាខ្មែរក្រហមខ្ទេចខ្ទី អស់ហើយ ។ ហ្នឹងហើយ ម្ចាស់ការ ឯករាជ្យ សមមុខទៅចុះ! ។ យួន វាយលេខខុស ព្រោះផែនការ “សហព័ន្ធឥណ្ឌូចិន” វិញទេ ដែលកំពុង



ខ្ទេចខ្ទី ។ បក្សកុម្មុយនីស្តកម្ពុជា និងបដិវត្តន៍កម្ពុជា នៅជ្រៅៗ ហើយ កំពុងបោះជំហានទៅមុខដោយជោគជ័យ ក្នុងចលនាតស៊ូអាវុធ និង នយោបាយរួមផ្សំ ។

ក្នុងរយៈកាល២ឆ្នាំ នៃការតស៊ូដោយអាវុធ រួមផ្សំនយោបាយ បក្សកាន់តែដឹកនាំប្រជាជនដឹកនាំចលនាបានជាប់ស្អិតមាគ៌ាបក្សបានសាកល្បងបញ្ជាក់ច្បាស់នូវសភាពត្រឹមត្រូវខ្លាំងក្លារបស់ មាគ៌ាបក្ស ។ សតិអារម្មណ៍កម្មាភិបាល បក្ខជន កងទ័ព និងប្រជាជន កាន់តែរឹងប៉ឹង ក្នុងភ្លើងប្រយុទ្ធ ។ កម្លាំងបដិវត្តន៍គ្រប់ផ្នែកបានពង្រីង និងពង្រីកជាច្រើន ។ មូលដ្ឋាននយោបាយនៅក្នុងប្រជាជន នៅជនបទ បានរីកធំធាត់ ។ មូលដ្ឋានបផ្អែកទូទាំងប្រទេសបានពង្រឹង និងពង្រីក ថែម ។ ឯកងទ័ពរីកធំធាត់ ។ សភាពការណ៍បដិវត្តន៍កម្ពុជា កំពុងរីក លូតលាស់ល្អប្រសើរយ៉ាងនេះ ស្រាប់តែមានផ្ទុះរដ្ឋប្រហារភ្លាម ។

ថ្ងៃ១៨ ខែ៣ ឆ្នាំ១៩៧០ ចក្រពត្តិអាមេរិក និងពួកក្បត់ លន់ នល់ បានធ្វើរដ្ឋប្រហារ ។ ពេលវាធ្វើរដ្ឋប្រហារភ្លាម សភាពការណ៍ ប្រែប្រួលភ្លាម ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស អំណោយផលល្អ ដល់បដិវត្តន៍កម្ពុជាថែមទៀត ។ ក្នុងសភាពការណ៍ហ្នឹង បក្សកុម្មុយ នីស្តកម្ពុជាវាយសម្រុកភ្លាម ។

កម្លាំងប្រជាជន និងកងទ័ពដែលបានហ៊ឹកហ៊ឺនក្នុងចលនា បដិវត្តន៍នយោបាយ និងអាវុធ បានធ្វើកុប្បកម្មតាមភូមិ ឃុំទូទាំង ប្រទេស ។ ពេលនោះ សូម្បីតែខ្មាំងដែលវានៅតាមប៉ុស្តិ៍ បន្ទាយ មួយអនុសេនាតូច មួយអនុសេនាធំ ក៏ត្រូវបាក់ខ្នាត់ខ្ចាយរលាយ ភ្លាម ។ ប្រជាជនងើបឡើង ធ្វើមហាបាតុកម្ម មហាកុប្បកម្មទូទាំង ប្រទេស ដូច្នោះខាងបដិវត្តន៍វាយសម្រុកទាំងនយោបាយ ទាំង យោធា ធ្វើឲ្យចក្រពត្តិអាមេរិកទាល់ច្រក ហើយអា លន់ នល់ ក៏ទាល់ ច្រកដែរ ។ ប្រជាជនរាប់លានចូលមកភ្នំពេញ ខ្លះដើរ ខ្លះជិះឡាន ខ្លះ ជិះកប៉ាល់ បម្រុងចាប់អា លន់ នល់ កម្ទេចចោល ។ តែ១ខែប៉ុណ្ណឹង បក្សយើងរំដោះភូមិឃុំ និងទូទាំងប្រទេស បានមួយចំនួន៧០ –៧៥ ភាគរយ ។ បើថែមពេលមួយខែទៀត ចលនាបដិវត្តន៍មុខជាបោស សម្អាតពួកអាក្បត់ លន់ នល់ អស់រលីងគ្មានសល់ ។

ចក្រពត្តិអាមេរិក ឃើញសភាពនេះវាចូលមកវាយបដិវត្តន៍ កម្ពុជាផ្ទាល់ ។ វាចូលមកជិតដល់សែននាក់ ទាំងជើងគោក ទាំងជើង អាកាស ។ យួនអាធីវគី ក៏ចូលមករាប់សែននាក់ មកវាយបដិវត្តន៍

កម្ពុជា ដើម្បីស្រោចស្រង់អា លន់ នល់ ផង ហើយដណ្ដើមយកដីកម្ពុជាផង ។

នៅមុខសភាពការណ៍នេះ បក្សយើងបំផុសស្មារតីស្នេហាជាតិឲ្យខ្ពង់ខ្ពស់ វាយចក្រពត្តិអាមេរិក វាយអាខ្មាំងយួនធីវគី វាយអា លន់ នល់ ក្បត់ជាតិ ។ ចលនាបដិវត្តន៍ទូទាំងប្រទេស កាន់តែផុសផុលខ្លាំងក្លា ។ សកលលោកឧបត្ថម្ភបដិវត្តន៍កម្ពុជាយ៉ាងសកម្ម រហូតមានការជួយឧបត្ថម្ភពីប្រជាជនអាមេរិកផង ។ ដល់ឆ្នាំ១៩៧៣ មានកិច្ចព្រមព្រៀងក្រុងប៉ារីស និងកិច្ចព្រមព្រៀងវៀងចន្ទ ផ្អាកសង្រ្គាមនៅយួន និង លាវ ។ កម្ពុជាយើងបន្តធ្វើសង្រ្គាមតែម្នាក់ឯង ។ ពេលនោះចក្រពត្តិអាមេរិក ប្រមូលកម្លាំង មកវាយបដិវត្តន៍កម្ពុជាយើងខ្លាំងមែនទែន តែត្រូវបរាជ័យ ។ សង្រ្គាមអាកាស ២០០ថ្ងៃ ២០០យប់ របស់ចក្រពត្តិអាមេរិកត្រូវបរាជ័យយ៉ាងអាម៉ាស់ ។ ក្នុងឆ្នាំ៧៣នេះដែរ ដែលបក្សយើងលើកគោលការណ៍វាយសម្រុកខ្លាំងជាយុទ្ធសាស្រ្ត វាយរហូត វាយទាំងប្រាំង ទាំងវស្សា ទាំងយប់ ទាំងថ្ងៃ ។ កងទ័ពអាក្បត់ លន់ នល់ ត្រូវខ្ទេចខ្ទី ។ ចក្រពត្តិអាមេរិក គ្មានកម្លាំងមូលដ្ឋានមកជួយទៀត អាក្បត់ លន់ នល់ អស់មនុស្ស អស់សេដ្ឋកិច្ច អស់នយោបាយ អស់រលីងដូចគជ់ នៅក្នុងឆ្នាំ១៩៧៣ នេះដែរ បក្សសម្រេចចាត់តាំងសហករណ៍ទូទាំងប្រទេស ។ ចលនាសហករណ៍ផុលផុសយ៉ាងខ្លាំងក្លា ក្នុងការតស៊ូវណ្ណៈផង វាយសម្រុកខ្មាំងនៅសមរភូមិមុខផង និងបង្កបង្កើនផលសម្រាប់ធ្វើសង្រ្គាមបដិវត្តន៍យូរអង្វែងផង ។ សមរភូមិមុខក៏វាយសម្រុក សមរភូមិក្រោយក៏វាយសម្រុក ។ ចលនាសហករណ៍បានរួមចំណែករំដោះជាតិ រំដោះប្រជាជនយ៉ាងសកម្មបំផុត តាមគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន ខ្លួនក្ដាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង ។ ខែ៦ ឆ្នាំ១៩៧៤ បក្សយើងកំណត់បើកការវាយសម្រុកជាយុទ្ធសាស្រ្ត ដើម្បីផ្ដាច់ព្រ័ត្រ រំដោះភ្នំពេញ រំដោះទូទាំងប្រទេស ។ បក្សកំណត់ដូចតទៅនេះ ៖

◆ វាយមេគង្គក្រោមជាគន្លឹះ ដើម្បីផ្ដាច់ស្បៀង ផ្ដាច់ផ្លូវគមនាគមន៍ខ្មាំង

◆ វាយជុំវិញភ្នំពេញ ដើម្បីវាយផ្ដាច់ភ្នំពេញ

◆ បើកវាយទីរួមខេត្តខ្លះដែលខ្មាំងកាន់កាប់បណ្ដោះអាសន្ន

ថ្ងៃទី១ ខែ១ វេលាម៉ោង១ភ្លឺ ១៩៧៥ គ្រប់អង្គភាពទ័ពទាំងឈូប ស្រុក តំបន់ ភាគ និងទ័ពមជ្ឈិមគ្រប់មុខព្រួញ ត្រូវសម្រុកបុកទំលាយ តាមផែនការបក្សកំណត់ ។

ដល់ពេលកំណត់ គ្រប់មុខព្រួញវាយសម្រុកបុកតែមួយព្រឹប ទ័ពអា លន់ នល់ បាក់រត់ខ្ចាត់ខ្ចាយ ។ វាយតែ៣ខែ កងទ័ពបដិវត្តន៍យកបានអ្នកលឿង ។ អាមេក្បត់ លន់ នល់ លៀនអណ្ដាតចក្រពត្តិអាមេរិកស្វាយមុខ ។ ថ្ងៃទី១ មេសា អាមេក្បត់ លន់ នល់ រត់ចោលស្រុកទៅអាមេរិក ។ ថ្ងៃ១២ មេសា ចក្រពត្តិអាមេរិកទ្រហោយំរត់ឡើងឧទ្ធម្ភាគចក្ររត់ទៅអាមេរិកទៀត ។

ថ្ងៃ១៧ មេសា ១៩៧៥ វេលាម៉ោង៩កន្លះ ស្នូរជួងមហាជ័យលាន់ឮរន្ទឺទូទាំងប្រទេស និងសកលលោក ។ ភ្នំពេញបានរំដោះហើយ! កម្ពុជាបានរំដោះទាំងស្រុងហើយ! ទង់ក្រហមឆ្អិនឆ្អៅ នៃបក្សកុម្មុយនីស្ដកម្ពុជា អណ្ដែតត្រសែតលើអាកាសវេហា បញ្ជាក់ថា បក្សកុម្មុយនីស្ដកម្ពុជាឈ្នះហើយ! ប្រជាជនកម្ពុជាឈ្នះហើយ! វណ្ណៈកម្មករ កសិករកម្ពុជាឈ្នះហើយ! បដិវត្តន៍កម្ពុជាឈ្នះហើយ! «រងើកភ្លើងតូច ដែលប្រៀបប្រដូចនឹងភ្នែកមាន់ព្រៃ គេផ្លុំបន្កាត់ដោយឃ្នាតខ្ទី ឆេះភ្លឺដូចថ្ងៃ អាស្រ័យចលនា» ។

ស្មោះត្រង់ជានិច្ចចំពោះមហាសន្និបាតបក្ស លើកទីមួយកម្មាភិបាល បក្ខជន កងទ័ព ប្រជាជនគ្មានសម្រាកមួយនាទីឡើយ ។ ទាំងអស់គ្នាក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្ដកម្ពុជា ជ្រោងទង់ប្រយុទ្ធបន្តទៅទៀត តាមមាគ៌ានៃមហាចលនាបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម ដើម្បីឈានទៅកុម្មុយនីស្ដនិយម ដោយឯករាជ្យ ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួន ខ្លួនក្ដាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង ។

១៩៧៥ ដល់ ១៩៧៨ មហាចលនាការពារប្រទេសធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម លើកស្ទួយជីវភាពប្រជាជនខ្លាំងក្លាណាស់ ។

ខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍កម្ពុជា លើកទ័ព១៤កងពល ប៉ុនប៉ងវាយសម្រុកយកកម្ពុជាតែមួយព្រឹប តែត្រូវប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជាវាយខ្ទេចខ្ទីបរាជ័យ យ៉ាងអាម៉ាស់ ទាំងនៅកម្ពុជា និងលើឆាកអន្តរជាតិ កាលពីថ្ងៃ៦ មករា ១៩៧៨ ។

ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារផ្កែ

បម្រើយួន និងក្អាក់ង៉ារ កា.ហេរ្យ.បេ ខំត្រដររកខ្យល់ងើបមកដណ្តើមយកអំណាចពីបក្សកុម្មុយនីស្តកម្ពុជា និងពីប្រជាជនកម្ពុជា តែត្រូវប្រជាជនកម្ពុជា វាយកម្ទេចបាក់ទាំងផ្ទាំងៗ ធ្វើឲ្យចក្រពត្តិអាមេរិកក៏បរាជ័យ ផែនការ «សហព័ន្ធឥណ្ឌូចិន» របស់យួនក៏បរាជ័យ ផែនការវាតទីរបស់បក្សពួកសេរីរើមកលើអាស៊ីអាគ្នេយ៍ក៏ត្រូវបរាជ័យ ។

របបឯកជន និងកម្មសិទ្ធិឯកជនកាន់តែរលំរលាយជាបន្តបន្ទាប់ បាត់មុខបាត់មាត់ពីសង្គមកម្ពុជា របបសមូហភាព និងកម្មសិទ្ធិសមូហភាពនៃវណ្ណៈអធនរបស់បក្សកាន់តែបានពង្រឹងពង្រីកក្នុងមហាចលនាប្រយុទ្ធការពារប្រទេស និងកសាងសង្គមនិយម ។

មហាចលនា កសាងប្រទេស លើកស្ទួយជីវភាពប្រជាជនតាមមាគ៌ាកសាងសង្គមនិយមរបស់បក្ស បានទទួលជោគជ័យជាលំដាប់ ដោះស្រាយជីវភាពប្រជាជន ដែលទើបចេញផុតពីសង្គ្រាមវិនាសកម្មរបស់ចក្រពត្តិអាមេរិកបានជាមូលដ្ឋាន ហើយរៀបចំលក្ខណៈសម្បត្តិជាមូលដ្ឋាន ឈានទៅវាយសម្រុកខ្លាំងក្លាទៀតខាងកសិកម្ម និងឧស្សាហកម្ម ។

ចលនាឧបត្ថម្ភគាំទ្របដិវត្តន៍សង្គមនិយមកម្ពុជារបស់មិត្តភក្តិលើសកលលោក កាន់តែច្រើន ក្លៀវក្លាស្វាហាប់ ដាក់ជំនឿជឿជាក់លើអនាគតដ៏ត្រចះត្រចង់នៃបដិវត្តន៍សង្គមនិយមកម្ពុជា ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាតែមួយគត់ ។

១៨ឆ្នាំ ក្រោមទង់ប្រយុទ្ធវាយសម្រុកយ៉ាងខ្លាំងក្លា របស់បក្សកុម្មុយនីស្តកម្ពុជា ក្រោមការដឹកនាំរបស់មជ្ឈិមបក្សដែលមានសមមិត្ត ប៉ុល ពត ជាលេខា វាយសម្រុកទាំងក្នុងដំណាក់កាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ វាយសម្រុកទាំងក្នុងដំណាក់កាលបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម បក្សសន្និដ្ឋានថា ៖

«បក្សត្រូវមានមាគ៌ានយោបាយជាយុទ្ធសាស្ត្រ យុទ្ធវិធីត្រឹមត្រូវ មានសតិអារម្មណ៍បដិវត្តន៍ខ្លាំងក្លា មានការចាត់តាំងរឹងប៉ឹង ។ ត្រូវមានកម្មាភិបាលស្នូល ដែលមានគោលជំហរលះបង់ខ្ពស់ មានស្មារតីប្រយុទ្ធវាយសម្រុកខ្លាំងក្លា មិនខ្លាចលំបាកវេទនា មិនខ្លាចស្លាប់រស់ ហើយមានទស្សនៈមហាជនត្រឹមត្រូវ នាំយកមាគ៌ានយោបាយសតិអារម្មណ៍ និងចាត់តាំងរបស់បក្ស ទៅឃោសនាអប់រំចាត់ តាំងប្រជាជន បំផុសប្រជាជន មហាជន ធ្វើការតស៊ូបដិវត្តន៍ទាំងវាយខ្នាំង ទាំងតស៊ូវណ្ណៈ ទាំងប្រយុទ្ធដោះស្រាយជីវភាពប្រជាជន ។ ចលនាតស៊ូបដិវត្តន៍របស់មហាជន ត្រូវបំផុសជាបន្តបន្ទាប់ ។ កាលបើមានចលនាមហាជនផុសផុល តាមមាគ៌ានយោបាយរបស់បក្សហើយ ចលនានេះ វាពង្រឹងពង្រីកមាគ៌ានយោបាយសតិអារម្មណ៍ ចាត់តាំងរបស់បក្សថែម ។ ចលនានេះកសាងពង្រឹងពង្រីកកម្មាភិបាលបក្ខជនថែម ។ ចលនានេះ កសាងពង្រឹងពង្រីកកម្លាំងមហាជន ប្រមូលមហាជនកាន់តែចូលរួមធ្វើបដិវត្តន៍កុះករខ្លាំងក្លាថែមទៀត ។ វិលវង់ចុះឡើងយ៉ាងនេះជាច្រើនលើក ច្រើនគ្រា ច្រើនឆ្នាំ ចលនាបដិវត្តន៍កាន់តែបានរីកចម្រើនខ្លាំងក្លា ។ រីកចម្រើនខ្លាំងក្លាខាងកម្លាំងប្រជាជន មហាជន ។ រីកចម្រើនខាងចំនួន និងគុណភាពរបស់កម្មាភិបាលគ្រប់ថ្នាក់ ។

បើបក្សមានមាគ៌ានយោបាយ សតិអារម្មណ៍ ចាត់តាំងឯកភាពត្រឹមត្រូវ ។ មានកម្មាភិបាលស្នូល មានប្រជាជនមហាជនធំទូលាយ ដោយមានសម្ព័ន្ធភាព កម្មករ កសិករ ជាមូលដ្ឋាន ។ មានចលនាប្រយុទ្ធក្តៅជាបន្តបន្ទាប់ ហើយបក្សនេះនឹងមានកងទ័ពមួយយ៉ាងខ្លាំងក្លា ទាំងនយោបាយ សតិអារម្មណ៍ ចាត់តាំង មានពិសោធន៍បដិវត្តន៍ច្រើន មានសេដ្ឋកិច្ច និងមានអ្វីៗទាំងអស់ ។ដូច្នោះ បក្សនេះប្រជាជននេះ ពិតជាធ្វើបដិវត្តន៍បានជ័យជម្នះដាច់ខាត ជ័យជម្នះដែលបានមកដោយម្ចាស់ការ ឯករាជ្យ ខ្លួនឧបត្ថម្ភខ្លួន ខ្លួនក្តាប់វាសនាខ្លួនដោយខ្លួនឯង» ។

សមមិត្តជាទីស្នេហា! ក្នុងសេចក្តីថ្លែងការណ៍របស់សមមិត្ត ប៉ុល ពត លេខាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ក្នុងឱកាសអបអរសាទរខួបទី១៧ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា និងក្នុងឱកាសដែលបក្សប្រកាសចេញចំហជាផ្លូវការក្នុងប្រទេស និងលើឆាកអន្តរជាតិ សមមិត្តបានថ្លែងជាទីបញ្ចប់ថា «ដំណើររបស់យើងបានវែងឆ្ងាយហើយ បើប្រៀបធៀបនឹងចលនាបដិវត្តន៍នៅក្នុងប្រទេសយើង ។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ យើងត្រូវរាបសាបដិវត្តន៍ ត្រូវឃើញនូវជ័យជម្នះមហាជ័យជម្នះរបស់យើង ហើយក៏យើងត្រូវឃើញថា ភារកិច្ចរបស់យើងនៅច្រើន ហើយធ្ងន់ក្នុងការការពារប្រទេស ការពារកម្ពុជាប្រជាធិបតេយ្យ ការពារបដិវត្តន៍កម្ពុជា ការពាររដ្ឋអំណាច ប្រជាជន កម្មករ កសិករ ហើយនឹងភារកិច្ចដ៏ធ្ងន់ធ្ងរមួយទៀត គឺខាងកសាងប្រទេសឲ្យចម្រុង

ចម្រើនរុងរឿងឆាប់រហ័ស ដើម្បីលើកស្ទួយជីវភាពប្រជាជនយើងឲ្យបានថ្កុំថ្កើងរុងរឿងឆាប់រហ័ស ហើយរួមវិភាគទានជាមួយប្រជាជនសកលលោកឲ្យបានរីកចម្រើនឆាប់រហ័សដែរ» ។

ដូច្នោះហើយ កម្មាភិបាលយើង បក្ខជនយើង កងទ័ពបដិវត្តន៍យើង ដើម្បីបំពេញភារកិច្ចវាយឈ្នះខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី បំបាត់ពូជសាសន៍កម្ពុជា បន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យជ្រាលជ្រៅ និងកសាងសង្គមនិយម លើកតម្កើងជីវភាពប្រជាជន ចាំបាច់បន្តការកសាងគោលជំហរនយោបាយ សតិអារម្មណ៍ចាត់តាំងឲ្យខ្លាំងក្លាគ្រប់ផ្នែកដោយ ៖

១) ដុតដំជាប់ក្នុងចលនាប្រយុទ្ធ

២) សុភាពរាបសា ដាក់ខ្លួនឲ្យមហាជន ឲ្យសមូហភាពកសាង

៣) កសាងគោលជំហរ រស់នៅស្អាតស្អំតាមបែបបទបដិវត្តន៍

៤) ខិតខំរៀនសូត្រជានិច្ច ខាងនយោបាយ សតិអារម្មណ៍ចាត់តាំង និងបច្ចេកទេសវិទ្យាសាស្ត្របដិវត្តន៍ ។

យើងកសាងគោលជំហរនយោបាយ សតិអារម្មណ៍ចាត់តាំងឲ្យរឹងប៉ឹងខ្លាំងក្លា តាមគោលជំហរនៃវណ្ណៈអធនរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ដើម្បីធ្វើឲ្យបក្សយើងខ្លាំង ដើម្បីប្រមូលកម្លាំងប្រជាជនយើងទាំង៨លាននាក់ធ្វើបដិវត្តន៍ ដើម្បីបំផ្លិចបំផ្លាញចលនាវាយសម្រុកកម្ទេចខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ឲ្យបានជ័យជម្នះ ដើម្បីធ្វើបដិវត្តន៍សង្គមនិយមឲ្យកាន់តែជ្រាលជ្រៅ ហើយដើម្បីកសាងសង្គមនិយម និងលើកតម្កើងជីវភាពប្រជាជនឲ្យបានឆាប់រហ័ស ។

*ជយោ បុណ្យខួបទី១៨ នៃកំណើតបក្សកុម្មុយនីស្តកម្ពុជា!*

*ជយោ បក្សកុម្មុយនីស្តដ៏ត្រឹមត្រូវ និងភ្លឺស្វាង មហាអស្ចារ្យ!*

*ជយោ បដិវត្តន៍កម្ពុជា ដ៏ខ្លាំងក្លា មហាអស្ចារ្យ!*

*ជយោ កងទ័ពបដិវត្តន៍កម្ពុជា ដ៏ខ្លាំងពូកែ និងអង់អាចក្លាហាន មហាអស្ចារ្យ!*

*ជយោ កម្ពុជាប្រជាធិបតេយ្យ ដ៏រុងរឿង!*

*ជយោ លទ្ធិ ម៉ាក្ស លេនីន ដ៏ភ្លឺស្វាង មហាអស្ចារ្យ!*

**ឆាយ សារៈមុនិន្ទ**



*(រូបខាងស្ដាំ) នារីនៅក្នុងកងសិល្បៈខ្មែរក្រហម មកលេងឪពុកម្ដាយ និងប្អូនៗនៅផ្ទះ*

# សេចក្តីប្រកាសព័ត៌មាន
# ឯកសារបានមកពីប្រភពចំហរបស់សាលាក្តីខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកិត្តិយស សូមប្រកាសជូនដំណឹងដល់សាធារណជនជ្រាបអំពីឯកសារបានមកពីប្រភពចំហរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលហៅកាត់ថា **អ.វ.ត.ក** ។ ចាប់តាំងពីថ្ងៃទី១ នៃប្រតិបត្តិការរបស់ **អ.វ.ត.ក** មជ្ឈមណ្ឌលឯកសារកម្ពុជារកឯកសារពីប្រភពចំហរបស់ **អ.វ.ត.ក** បានដោយរក្សាទុក និងរៀបចំឯកសារទាំងនោះ សម្រាប់សាធារណជនទូទៅប្រើប្រាស់តាមតម្រូវការ ។ ផែនការត្រៀមទុកនេះសំដៅធានាថា សាធារណជនទូទៅអាចស្វែងរកឯកសាររបស់ **អ.វ.ត.ក** បាន បើទោះបីជាតុលាការនេះបញ្ចប់ប្រតិបត្តិការរបស់ខ្លួនហើយក៏ដោយ ។ កិច្ចការដែលទាក់ទងនឹងឯកសារនេះ គឺមជ្ឈមណ្ឌលឯកសារកម្ពុជា ៖

◆ ព្រីនសំណៅឯកសារសាធារណៈរបស់ **អ.វ.ត.ក** ចេញទាំងអស់ពីគេហទំព័ររបស់តុលាការ (ភាសាខ្មែរ អង់គ្លេស និងបារាំង) និងចង ក្រងវាសម្រាប់សាធារណជនទូទៅអាចប្រើប្រាស់បាន ។

◆ ចម្លងទុក និងរក្សាទុកដាក់ក្នុងអង្គចងចាំខាងក្រៅកុំព្យូទ័រនូវសំណៅឯកសារអេឡិចត្រូនិច ដែលជាឯកសារសារធារណៈផ្សព្វផ្សាយលើគេហទំព័ររបស់តុលាការ (ភាសាខ្មែរ អង់គ្លេស និងបារាំង) រួច ហើយចងក្រងឯកសារទាំងនោះសម្រាប់សាធារណជនទូទៅអាចប្រើប្រាស់បាន ។

◆ ផ្តិតយករូបភាពវីដេអូសវនាការទាំងអស់ រាប់ទាំងសវនាការដោយអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលផ្ទាល់ពីបន្ទប់សវនាការរបស់ **អ.វ.ត.ក** រួចហើយរក្សាទុក និងចងក្រងសម្រាប់សាធារណជនទូទៅអាចប្រើប្រាស់បាន ។

ឯកសារដែលរៀបរាប់ទាំងអម្បាលម៉ានខាងលើ បូករួមទាំងឯកសារខ្មែរក្រហមរាប់សែនទំព័រផង ត្រូវបានដាក់ឲ្យប្រើប្រាស់ដោយឥតគិតថ្លៃ នៅសាលអានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមពេលវេលា និងម៉ោងធ្វើការដូចខាងក្រោម ៖

◆ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ (លើកលែងបុណ្យទាន និងឈប់សម្រាក)

◆ ចាប់ពីម៉ោង ៧និង១៥ នាទីដល់ម៉ោង ៥ និង១៥ នាទីល្ងាច ។

មជ្ឈមណ្ឌលឯកសារកម្ពុជាសូមលើកទឹកចិត្តសាធារណជនឲ្យស្វែងរកឯកសារខាងលើលើគេហទំព័រ **អ.វ.ត.ក** ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមសម្តែងនូវការដឹងគុណដល់អ្នកគាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការជួយថែរក្សាឯកសារដែលប្រើប្រាស់បានពីបណ្តុំឯកសារតាមប្រភពចំហរបស់ **អ.វ.ត.ក** ដែលក្នុងនោះមាន *J.B and M.K. Pritzker Family Foundation, Illinois Holocaust Museum & Education Center, Northwestern University School of Law's Center for International Human Rights, Robert Bosch Stiftung* និងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ហៅកាត់ថា *USAID* ។

សាលអានសាធារណៈ

អគារ ៦៦ ផ្លូវព្រះសីហនុ

ប្រអប់សំបុត្រ ១១១០ ភ្នំពេញ

ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារ ០២៣ ២១០ ៣៥៨

អ៊ីម៉ែល : *dccam@online.com.kh*

គេហទំព័រ : *www.dccam.org; www.cambodiasri.org; www.cambodiatribunal.org; and www.cambodialpj.org* ឬទាក់ទងមកលោក វ៉ាន់ថាន់ ពោដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា លេខទូរស័ព្ទ ០ ១២ ៨៤៦ ៥២៦ អ៊ីម៉ែល truthpdara@dccam.org

# ខ្មែរសុរិន្ទក្នុងចលនាបដិវត្តន៍

*លឹម វុធឌី អាយុ៧០ឆ្នាំ ជាខ្មែរសុរិន្ទ កើតនៅភូមិទម្លាប់ ឃុំសង្កែ ស្រុកសទឹក ខេត្តបុរីរាំ ប្រទេសថៃ។ វុធឌី បានចាកចេញពីផ្ទះក្នុងខេត្តបុរីរាំ តាំងពីគាត់មានអាយុ៧ឆ្នាំ មករស់នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជាវិញ ដោយសារនៅកន្លែងដែលគ្រួសារគាត់រស់នៅបានជួបប្រទះ គ្រោះរាំងស្ងួត និងទឹកជំនន់ ធ្វើស្រែមិនបាន។ វុធឌី រៀបរាប់ថា ខ្មែរសុរិន្ទដែលចាកចេញពីផ្ទះ មករស់នៅស្រុកខ្មែរជាមួយគ្រួសារគាត់ មានប្រមាណ៨០គ្រួសារ ដោយបររទេះចំនួន ៨០ ព្រមទាំង គោ-ក្របីជាច្រើនក្បាលទៀត។ វុធឌី បន្តថា ខ្មែរសុរិន្ទនៅពេលនោះអាចផ្លាស់ប្តូរទីកន្លែង ដោយមិនមានការបង្ខិតបង្ខំពីអាជ្ញាធរឡើយ ។*

*ពេលមកដល់ស្រុកខ្មែរ វុធឌី រស់នៅភូមិក្បាលទន្សោង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ដោយប្រកបរបរធ្វើស្រែចម្ការ ។ ក្រៅពីការងារនេះ ឪពុកម្តាយរបស់គាត់បានប្រកបរបរបន្ថែមទៀតគឺ ចិញ្ចឹមគោមេចំនួន៣៨០ក្បាល និងក្របីចំនួន៨០ក្បាល ។ នៅសម័យនោះ វុធឌី បានចូលរៀននៅសាលាវត្តបន្ទាយឆ្មាររហូតដល់ថ្នាក់ទី៩ ។ ក្រោយមក គាត់ក៏ឈប់រៀនដោយសារផ្លូវពិបាកបររទេះមិនរួច និងត្រូវឡើងទៅរៀនបន្តនៅស្រុកថ្មពួកទៀត ។*

*នៅអំឡុងឆ្នាំ១៩៦៨ វុធឌី បានចូលរួមក្នុងចលនាខ្មែរសេរីជាមួយយុវជនផ្សេងទៀតតាមការឃោសនា ដែលមាន ឡឹក សំអឿន ហៅ ផ្កាយព្រឹក ជាអ្នកដឹកនាំ ។ ប៉ុន្តែចលនានេះ បានលម្អៀងទៅរកខ្មែរក្រហម ។ មួយរយៈក្រោយមក លោក សឹង តូ ទាហានពាក់សក្តិ៥ បានទៅឃោសនា និង អូសទាញ ឡឹក សំអឿន រួមទាំង វុធឌី និងកម្លាំងខ្មែរសេរីប្រមាណ ១.០០០នាក់ មកចូលរួមជា មួយ លន់ នល់ វិញ ។*

*បន្ទាប់ពីចូលបម្រើក្នុងកងទ័ព លន់ នល់ វុធឌី ត្រូវបានចាត់តាំងឲ្យចេញទៅឈរជើងនៅ អូរស្មាច់, ភ្នំស្រុក និងកន្លែងជាច្រើនទៀត ។ ក្រោយមក វុធឌី និងមិត្តភក្តិម្នាក់ទៀតឈ្មោះ ឡម វឿង ត្រូវយោធាខ្មែរក្រហមឃាត់ខ្លួនបាននៅក្តាន់រុន (ស្ថិតនៅម្តុំក្រុងសៀមរាប) ពេលគាត់ទាំងពីរ នាក់ជិះម៉ូតូទៅបើកប្រាក់ខែ នៅខេត្តសៀមរាប ។ ខ្មែរក្រហមបាននាំ វុធឌី និង ឡម វឿង ទៅឃុំនៅតំបន់ដែលខ្លួនរំដោះអស់រយៈពេលបីខែ និងបានស្នើគាត់ និងមិត្តភក្តិឲ្យទៅស៊ើបយកព័ត៌មានដើម្បីវាយយកបន្ទាយទាហាន លន់ នល់ នៅក្នុងស្រុកភ្នំស្រុក ។ វុធឌី និង មិត្តរបស់គាត់បានយល់ព្រមតាមការស្នើនេះ ប៉ុន្តែពេលខ្មែរក្រហមដោះលែង វុធឌី និងមិត្តរបស់គាត់បាននាំដំណឹងនោះទៅប្រាប់ សឹង តូ មេបញ្ជាទ័ព លន់ នល់ និងសូមឲ្យ សឹង តូ ជូនមកផ្ទះវិញ ព្រោះក្រុមគ្រួសារគិតថា គាត់ទាំងពីរនាក់ត្រូវខ្មែរក្រហមសម្លាប់ចោលហើយ ។ ចាប់តាំងពីពេលនោះមក វុធឌី បានត្រឡប់មករស់នៅផ្ទះ នៅភូមិក្បាលទន្សោងវិញ ។*

*នៅមុនពេលយោធាខ្មែរក្រហម វាយរំដោះភូមិរបស់គាត់ វុធឌី បានលួចជូនព្រះអង្គម្ចាស់ ច័ន្ទ រង្សី មេបញ្ជាការកងទ័ព លន់ នល់, ឈៀង វេង ពាក់សក្តិ៥ , នង ហ៊ាន និងមេៗមួយចំនួន រួមទាំងរថយន្តចំនួន៥ គ្រឿង ចូលទៅក្នុងប្រទេសថៃតាមច្រកសម្ងាត់ ព្រោះគាត់ខស្ទាប់ចេញចូលរកស៊ីជាមួយថៃតាមផ្លូវនេះ និងចេះនិយាយភាសាថៃ ។ ប៉ុន្តែទាហានថៃ បានដកយកអាវុធ និង រថយន្តទាំងអស់ មុននឹងអនុញ្ញាតឲ្យមនុស្សចូលទៅក្នុងទឹកដីរបស់ខ្លួន ។ ចំណែក ព្រះអង្គម្ចាស់ ច័ន្ទរង្សី ក៏បានទៅបួសនៅវត្តភ្នំដែក ក្នុងខេត្តសុរិន្ទ ប្រទេសថៃ ។*

*បន្ទាប់ពីត្រឡប់មកភូមិវិញបានមួយរយៈ នៅពាក់កណ្តាលឆ្នាំ១៩៧៥ វុធឌី ត្រូវខ្មែរក្រហមជ្រើសរើសឲ្យធ្វើជាឈ្លបឃុំ និងត្រូវបានចាត់តាំងឲ្យដឹកនាំយុវជន យុវនារី ទៅជីកប្រឡាយ លើកប្រព័ន្ធភ្លឺស្រែ និងលើកដីចាក់បំពេញផ្លូវថ្នល់ដែលដាច់ និងខូចខាតដោយសង្គ្រាម ។*

*ស្របពេលនោះដែរ ខ្មែរក្រហមក៏បានចាត់តាំងឲ្យចាស់ៗ នៅក្នុងភូមិច្រៀកគល់ឫស្សី បិតជាចម្រូង ដាក់ធ្វើជារបងដើម្បីការពារកុំឲ្យប្រជាជនរត់ចេញពីភូមិ ។*

រហូតដល់ចុងឆ្នាំ១៩៧៥ វុធឌី បាននាំកម្លាំង៣នាក់ជាមួយនឹងកាំភ្លើងបីដើម និងគ្រាប់បែកមួយចំនួនរត់ភៀសខ្លួនទៅថៃ ប៉ុន្តែត្រូវប៉ះចំប៉ុស្តិ៍យាមរបស់ខ្មែរក្រហម ។ វុធឌី បានបាញ់តបតជាមួយខ្មែរក្រហម និងបានដើរឆ្លងកាត់រណ្តៅចម្រូងជាច្រើនកន្លែងទៀត ។ វុធឌី បានទៅជួបជាមួយនឹង តាឡូត ដែលរត់ទៅប្រទេសថៃមុន និងបានបង្កើតកម្លាំងប៉ារ៉ាដែលដំបូងឡើយមានចំនួនតែ១២នាក់ប៉ុណ្ណោះ ។ វុធឌី ចូលធ្វើការក្នុងកងទ័ពប៉ារ៉ាមួយរយៈគាត់ក៏ទទួលភារកិច្ចចូលមកស៊ើបការណ៍នៅស្រុកខ្មែរ ដោយបន្ទំស្លៀកពាក់ខោអាវពណ៌គគីរ ស្បែកជើង កងឡាន និងមួកកន្តិបដូចកម្មាភិបាលខ្មែរក្រហម ។ វុធឌី បានចូលទៅតាមភូមិឆ្ងាយៗ និងតាមសហករណ៍ផ្សេងៗដែលមិនស្គាល់ពីប្រវត្តិរបស់គាត់ដើម្បីស្នើសុំ ត្រីងៀត អង្ករ និងស្បៀងសម្រាប់ហូប ។

ក្រោយមក វុធឌី បានទៅរស់នៅជំរំសាយធូ ជាមួយ សឺនសាន ហើយបានបន្តធ្វើការវាយប្រយុទ្ធជាមួយយោធាខ្មែរក្រហម និងកងទ័ពវៀតណាម ។ វុធឌី បានចូលមកវាយតទល់ជាមួយកងទ័ពវៀតណាម នៅបន្ទាយឆ្មារ និងបានចូលទៅធ្វើសកម្មភាពដល់ខេត្តកំពង់ធំ និងខេត្តកំពង់ចាម ។ វុធឌី បានបម្រើក្នុងកងទ័ពប៉ារ៉ារហូតដល់ឆ្នាំ១៩៩៤ ទើបគាត់លាឈប់ដោយពេលនោះគាត់មានឋានន្តរសក្តិផ្កាយមួយ រួចហើយក៏ត្រឡប់មកចិញ្ចឹមគោ និងធ្វើស្រែចម្ការជាមួយក្រុមគ្រួសារនៅឃុំបន្ទាយឆ្មារ រហូតដល់សព្វថ្ងៃ ។

**សោម ប៊ុនថន**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ ៖ ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល ៖ *truthfatily.s@dccam.org* គេហទំព័រ ៖ *www.ariverchangescourse.com*





# ប្រាក់ សុខា ៖ អង្គការដកសេចក្តីទុកចិត្ត ព្រោះឪពុកជាខ្មាំង

ការសម្លាប់រង្គាលជាទ្រង់ទ្រាយធំបានចាប់ផ្តើម មិនថាលើកម្មាភិបាលខ្លួនឯង និងប្រជាជនសាមញ្ញទេ គឺខ្មែរក្រហមអនុវត្តទៅលើមនុស្សទាំងអស់ ។ ទាំងនេះ មិនដូចពីដំបូងនៃការឃោសនារបស់ខ្លួនឡើយ ពេលនោះខ្មែរក្រហមទទួលអ្នកដែលស្ម័គ្រចិត្តចូលរួមចលនាបដិវត្តន៍របស់ខ្លួន ដោយមិនគិតពីអតីតភាពរបស់អ្នកទាំងនោះទេ ។ បន្ទាប់ពីខ្លួនបានគ្រប់គ្រងប្រទេសហើយ អ្នកដែលអង្គការចាត់ទុកថា ជាអ្នកបដិវត្តន៍ស្អាតស្អំបំផុតនោះគឺកសិករក្រីក្រ ដែលមិនមានជាប់និន្នាការនឹងរបបចាស់ ហើយខ្មែរក្រហម ក៏មិនទុកចិត្តអ្នកផ្សេងក្រៅពីកសិករក្រទាំងនេះដែរ ។ ហេតុនេះ អ្នកតស៊ូក្នុងបដិវត្តន៍របស់ខ្លួន ដែលមានបងប្អូនសាច់ញាតិដែលធ្លាប់បម្រើឲ្យរបប លន់ នល់ និងសង្គមចាស់ ក៏អង្គការចាត់ទុកចូលទៅក្នុងជនដែលមានជាប់និន្នាការខ្មាំងដែរ ។ អ្នកទាំងនោះ អាចត្រូវអង្គការទម្លាក់ពីតំណែង ឬយកទៅរៀនសូត្រជាដើម ។

ជាក់ស្តែង ប្រាក់ សុខា គឺជាអតីតយុទ្ធជនដែលចូលរួមចលនាតស៊ូជាមួយបដិវត្តន៍តាំងពីឆ្នាំ ១៩៧០ មកម្ល៉េះ ប៉ុន្តែ នៅឆ្នាំ១៩៧៧ សុខា ត្រូវអង្គការដកសេចក្តីទុកចិត្ត ហើយដកពីយុទ្ធជនកងពល ១៦៤ ឲ្យមកធ្វើការនៅតាមកងចល័តវិញ មូលហេតុដោយសារឪពុករបស់គាត់ពីមុនមានជាប់និន្នាការខ្មាំង លន់ នល់ ។ សុខា ទើបតែដឹងរឿងនេះ បន្ទាប់ពីអង្គការដកគាត់មកចល័ត ហើយក៏ស្ទើរតែមិនគួរឲ្យជឿដែរថា ឪពុករបស់គាត់ត្រូវអង្គការកម្ទេចតាំងពីឆ្នាំ ១៩៧៣មកម្ល៉េះ អំឡុងពេលដែលគាត់កំពុងតស៊ូយ៉ាងលំបាកយកជីវិតទៅប្តូរដើម្បីបដិវត្តន៍មួយនេះ ។ សុខា មានឪពុកឈ្មោះ ញ៉ែម ហ៊ាន និងម្តាយ អែម យិន និងមានបងប្អូនបង្កើតប្រាំនាក់ ។ សុខា មានស្រុកកំណើតនៅភូមិព្រៃ ឈើទាលក្រោម ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ។

កាលពីតូច សុខា បានរៀនសូត្រត្រឹមថ្នាក់ទី៩ចាស់ប៉ុណ្ណោះ ដោយសារតែស្រុកកើតសង្គ្រាមនៅអំឡុងឆ្នាំ១៩៧០ ។ នៅឆ្នាំ ១៩៧១ គ្រួសាររបស់ សុខា ទាំងអស់បានចាកចេញពីផ្ទះដែលមានទីតាំងនៅក្បែរបន្ទាយទាហាន ចូលទៅរស់នៅតំបន់រំដោះខាងខ្មែរក្រហមវិញ នៅភូមិទ្រវង់ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ដោយពេលនោះ សុខា បានចូលធ្វើជាឈ្លបឃុំ ។ នៅឆ្នាំ១៩៧២ សុខា បាន ចូលធ្វើជាកងទ័ពស្រុក ហើយការចូលនេះ គឺគាត់ធ្វើទៅតាមការអំពាវនាវរបស់សម្តេច សីហនុ ឲ្យកូនចៅទាំងអស់ចូលព្រៃម៉ាកគីតស៊ូប្រឆាំងនឹង លន់ នល់ ។ បន្ទាប់ពីធ្វើជាកងទ័ពស្រុកបានមួយរយៈ សុខា បាន ផ្លាស់ទៅធ្វើជាកងតំបន់ គឺតំបន់១៣ ។ នៅតំបន់១៣ នេះមានឈ្មោះ បូ (ឬហៅ បូ ស្រែអំបិល) ជាមេបញ្ជាការវរសេនាធំ ។ នៅពេលនោះ គាត់បានច្បាំងជាមួយទាហាន លន់ នល់ តែម្តង ។ គាត់រំពឹកថា ទាហានខ្មែរក្រហមគឺមានគ្រប់កន្លែងក្នុងតំបន់ ។ ការធ្វើជាទាហាន មិនសូវជាលំបាកខ្លាំងទេសម្រាប់ សុខា ព្រោះកាលពីនៅធ្វើឈ្លបឃុំ គឺគាត់លំបាកជាងនេះទៅទៀត ។ គាត់យល់ថា ការប្រយុទ្ធគ្នាជាមួយទាហាន លន់ នល់ គឺធម្មតាគ្មានអ្វីឲ្យគាត់តក់ស្លុតនោះទេ ។ ការប្រយុទ្ធរវាងកងទ័ពទាំងពីរចេះតែបន្ត ហើយយោធាខ្មែរក្រហមវាយបណ្តើរ រំកិលចូលបណ្តើរ ។ កងរបស់ សុខា វាយតាមមុខសញ្ញាខាងលិចភ្នំពេញ ចូលមកខាងកំបូល ហើយឈរជើងនៅទីនោះតែម្តង ដោយមិនបានចូលមកដល់ទីក្រុងភ្នំពេញទេ ។

បន្ទាប់ពីរំដោះភ្នំពេញ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ កងពលលេខ៣ របស់ សុខា ត្រូវអង្គការចាត់តាំងឲ្យទៅកំពង់សោម ហើយផ្លាស់ឈ្មោះពីកងពលលេខ៣ ទៅជាកងពល១៦៤វិញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត ។

ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ សុខា ធ្វើនៅកងពល ១៦៤ ទ័ពការពារជើងគោក ដែលកាលនោះ កងពល១៦៤ នេះបែងចែកជាពីរ គឺទ័ពជើងទឹក និងទ័ពជើងគោក ។ នៅកងពល ១៦៤ នេះ គឺមានទាំងយុទ្ធជន និងយុទ្ធនារី តែមិនដែលបានទំនាក់

ទំនងខាងមនោសញ្ចេតនាទេ ។ សុខា បាននិយាយថា “គឺគិតតែពីរឿងការងារ ព្រលឹមឡើងយើងធ្វើការងារ អត់ដែលបាននិយាយអ្វីទេ ហើយការងារយើងផ្សេង មុខសញ្ញាយើងផ្សេង ដូច្នេះការទៅទំនាក់ទំនងនិយាយលេង គឺគឺងតែង” ។ កងជើងគោករបស់គាត់មានគ្នាប្រហែល១០០នាក់ប៉ុណ្ណោះ ។ សុខា នៅខាងកងកាំភ្លើងធំ១០៥មីលីម៉ែត្រ តែមិនធ្លាប់បាញ់ ឬប្រយុទ្ធជាមួយអ្នកណាទេ ព្រោះអំឡុងពេលនោះ មិនទាន់មានការប៉ះទង្គិចអ្វីជាមួយអ្នកណាឡើយ ។ សុខា បានឲ្យដឹងថា រយៈពេលនោះ គាត់ជាកូនទាហានតូចតាចមិនសូវដឹងរឿងថ្នាក់លើទេ ហើយក៏មិនដែលបានប្រជុំអ្វីដែរ ។ សុខា បានឲ្យដឹងថា “ធ្វើការងាររាល់ថ្ងៃ ប្រសិនបើយើងមានកំហុសអ្វីមួយនោះ គឺអង្គការដកទៅកងចល័ត ឬយកទៅរៀនសូត្រនៅទឹកសាប ដាក់គុកនៅក្បាលស្ពានទឹកសាប” ។

ដោយជាប់និន្នាការ សុខា ត្រូវអង្គការដកមកខាងកងចល័តដែលជាកន្លែងលត់ដំមួយ ។ នៅឆ្នាំ១៩៧៧ ទើប សុខា បានដឹងថាឪពុករបស់គាត់ត្រូវអង្គការកម្ទេចតាំងពីឆ្នាំ១៩៧៣មកម្ល៉េះ ។ សុខា ធ្វើការនៅកងចល័តជាច្រើនកន្លែងដូចជា នៅកងកេង ហើយក្រោយមក អង្គការដកឲ្យមកសាងសង់ដៃ, វាយថ្ម និងធ្វើទំនប់នៅស្ទឹងហាវ ។ ការកសាងនេះ មិនទាន់ហើយស្រួលបួលផង ក៏វៀតណាមចូលតែម្តង ។ ប្រធានវរសេនាធំនៅពេលនោះមានឈ្មោះ ឈន ជាប្រធាន និង ថន ជាប្រធានវរសេនាតូច ។ អ្នកដែលប្រព្រឹត្តកំហុសនៅពេលនោះ ក៏មិនត្រូវធ្វើបាបអ្វីធ្ងន់ធ្ងរដែរ គឺគ្រាន់តែប្រជុំកសាងតែប៉ុណ្ណោះ ហើយការហូបចុកក៏មិនលំបាកដែរ លើកលែងខែខ្វះមានការខ្វះខាតគឺហូបបបរ ។

សុខា ធ្វើការនៅកងចល័តនៅស្ទឹងហាវនេះ រហូតដល់ឆ្នាំ១៩៧៩ ពេលវៀតណាមចូលតែម្តង ។ ពេលនោះ គាត់បានរត់ទៅតាមអង្គភាព ដោយមិនហ៊ានត្រឡប់មកភូមិកំណើតទេ ព្រោះឮថាវៀតណាមចាប់បាននឹងយកខ្សែដោតចង ។ សុខា រត់មកដល់ថ្មដា ខេត្តកោះកុង ក៏ត្រូវវៀតណាមស្ទាក់ជាប់ ហើយប្រមូលឲ្យនៅម្តុំ ដោយមិនអនុញ្ញាតឲ្យឆ្លងទឹកទៅខាងថៃទេ គឺឲ្យត្រឡប់ទៅស្រុកកំណើតវិញ ។ ទ័ពវៀតណាមបានបញ្ជូនក្រុមរបស់គាត់មកខាងកោះកុងវិញ ហើយពីរខែក្រោយមក បញ្ជូនបន្តមកខាងកំពង់សោម រួចហើយទើបបញ្ជូនទៅស្រុកកំណើត ។ នៅឆ្នាំ១៩៨០ សុខា បានទៅដល់ស្រុកកំណើត នៅតាកែវ ។ នៅឆ្នាំ១៩៨១ គាត់បានត្រឡប់មករស់នៅស្រុកបាណន់ ខេត្តបាត់ដំបង ដោយនៅធ្វើស្រែចម្ការជាមួយបងប្អូននៅទីនោះ ។ បន្ទាប់ពីប្រពន្ធរបស់គាត់បានស្លាប់ សុខា បានផ្លាស់មកនៅកោះកុង បានបួនឆ្នាំ ហើយក៏ធ្វើដំណើរបន្តមករស់នៅភូមិប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលជាតំបន់ខ្មែរក្រហមគ្រប់គ្រង ។ សុខា សម្រេចចិត្តរស់នៅស្រុកវាលវែងនេះ ព្រោះមានអ្នកនៅអង្គភាពចាស់ជាមួយគាត់ហៅមក ព្រោះមានដីធ្លីសម្រាប់គាត់ ។ ចំណែកប្រធានកងពលនៅស្រុកវាលវែងនេះ មានឈ្មោះ គីម ពៅ ។ សុខា បានរំឭកថា មកដល់វាលវែងដំបូង គឺតំបន់នេះសម្បូរព្រៃឈើ និងសត្វណាស់ដូចជា ដំរី ទន្សោង ខ្ទីង និងសត្វជាច្រើនប្រភេទទៀត ។ តែប្រហែលជា ១០ឆ្នាំក្រោយ លែងសម្បូរសត្វដូចពីមុនហើយ ដោយមានក្រុមហ៊ុនទិញព្រៃ និងម៉ាស៊ីនកាត់ព្រៃ ។

ការហូបចុកនៅអំឡុងពេល សុខា រស់នៅទីនោះ មិនសូវមានការលំបាកទេ ព្រោះគាត់ធ្វើចំការផ្គត់ផ្គង់ជីវភាពខ្លួនឯង ។ នៅឆ្នាំ១៩៩៤ ក៏មានការប្រយុទ្ធគ្នាម្តងទៀតរវាងកងទ័ពរដ្ឋាភិបាល និងខ្មែរក្រហម ហើយក្រុមរបស់ សុខា ភៀសខ្លួនបន្តទៅនៅដំរី ។ ក្រោយសមាហរណកម្ម អំឡុងឆ្នាំ១៩៩៨ សុខា បានត្រឡប់មករស់នៅលើទីតាំងចាស់វិញ ហើយបានបង្កើតជាភូមិ តែមិនទាន់មានប្រជាជនរស់នៅច្រើនទេ ។

នៅអំឡុងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ សម្រាប់ សុខា ផ្ទាល់ គឺមិនបានដឹងទាល់តែសោះថា មានការកាប់សម្លាប់ និងបង្អត់បាយប្រជាជន ។ គាត់យល់ថា នេះមកពីអ្នកគ្រប់គ្រង និងនៅតំបន់ខុសៗគ្នា ។ ចំណែកការសម្លាប់ប្រជាជនបង្អត់អាហារ គឺថ្នាក់លើអត់មានមកបញ្ជាទេ មកពីថ្នាក់ក្រោមមានគំនុំតៗគ្នាមក ។ សុខា បានបន្តថា មិនមែនអ្នកតស៊ូអត់មានបងប្អូនស្លាប់ទេ គឺខ្មែរក្រហមយកទៅសម្លាប់ចោលដូចតែគ្នា ជាក់ស្តែង ដូចជា ឪពុក, ពូ និងអ៊ំរបស់គាត់ក៏ស្លាប់ក្នុងអំឡុងពេលនោះដែរ ។

សុខា បានរៀបការប្រពន្ធក្រោយម្នាក់ទៀត ព្រមទាំងមានកូនប្រុសស្រីប្រាំនាក់ ។ សព្វថ្ងៃនេះ សុខា និងគ្រួសាររស់នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ និងប្រកបរបរធ្វើស្រែចម្ការ ។

**ផាន សារះមុនិន្ទ**

# អ៊ុង វ៉ែន អតីតប្រធានវរសេនាធំ៨២ នៅខេត្តរតនគិរី

អ៊ុង វ៉ែន កើតនៅភូមិ៨មុំ ឃុំតាំងពោធិ៍ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ វ៉ែន ជាកូនទី៣ ក្នុងចំណោមបងប្អូនប្រុសស្រី៥នាក់ ដែលមានឪពុកម្តាយជាកសិករ ។ កាលពីតូច វ៉ែន រៀនបានត្រឹមថ្នាក់ទី៩“ចាស់” ប៉ុណ្ណោះ នៅសាលាតាំងពោធិ៍ ។ ដោយសារតែការស្រឡាញ់ការសិក្សា វ៉ែន បានសម្រេចចិត្តបួសជាសង្ឃ ដើម្បីបន្តការសិក្សា ។ គាត់បួសជាសង្ឃនៅវត្តតាំងពោធិ៍បាន៥វស្សា ក៏សឹកមកជួយធ្វើស្រែឪពុកម្តាយវិញ ដោយសារតែស្ថានភាពគ្រួសារមានការលំបាក ។

នៅឆ្នាំ១៩៦៨ វ៉ែន បានចូលព្រៃដើម្បីតស៊ូ ដែលកាលនោះចាស់ៗនៅក្នុងភូមិជាអ្នកហៅឲ្យចូលតស៊ូ នៅព្រៃម្តុំភ្នំឪរ៉ាល់ ហើយនៅពេលនោះ វ៉ែន មាននាទីជាអ្នកដឹកជញ្ជូនគ្រាប់ ។ ដោយសារតែស្ថានភាពរស់នៅក្នុងព្រៃមានការលំបាកខ្លាំង ហើយពេលខ្លះត្រូវដាច់បាយ ដាច់ទឹក វ៉ែន ទ្រាំទ្រនឹងស្ថានភាពបែបនោះមិនបានក៏ត្រឡប់មកផ្ទះវិញ ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ និងមានការអំពាវនាវរបស់ព្រះអង្គឲ្យកូនចៅទាំងអស់ចូលព្រៃម៉ាគី ដើម្បីតស៊ូប្រឆាំងលន់ នល់ វ៉ែន ក៏បានសម្រេចចិត្តចូលព្រៃតស៊ូម្តងទៀត ។ វ៉ែន ចូលធ្វើជាទ័ពព្រៃ ដោយនៅជាមួយតា ចេង អន រហូតដល់ឆ្នាំ១៩៧៤ ទើបគាត់បែកពីតា ចេង អន ។ វ៉ែន ធ្វើកងទ័ពនៅក្នុងកងពល១៤ ដែលភាគច្រើនទ័ពទាំងអស់នេះ មកពីខាងខេត្តកំពង់ស្ពឺ និងមានមកពីភូមិភាគឧត្តរមួយវរសេនាធំដែរ ។ កងពល១៤ កាលនោះ មាន តា សារឿន ហៅ ០៥ និងកងមកពីភូមិភាគឧត្តរ គ្រប់គ្រងដោយ តា សាន ហៅ ០៦ ។ នៅក្នុងកងពល១៤ មាន៣វរសេនាធំ គឺ វរសេនាធំ៨១ គ្រប់គ្រងដោយ កែវ សារឿន, វរសេនាធំ ៨២ គ្រប់គ្រងដោយ វ៉ែន និង វរសេនាធំ៨៣ គ្រប់គ្រងដោយ ឌី ធិន និង ឡី ។ កងពល១៤នេះ ឈរជើងនៅម្តុំទួលលាភខាងលិចផ្លូវរថភ្លើង ។ ពេលដែលវាយចូលទីក្រុងភ្នំពេញ មកដល់វត្តតាំងក្រសាំង វ៉ែន ក៏ត្រូវរបួសគ្រាប់ស្នា និងជើង ហើយសម្រាកព្យាបាលរហូតដល់ថ្ងៃជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៥ តែម្តង ។

ក្រោយពីបានរំដោះទីក្រុងភ្នំពេញ វរសេនាធំរបស់ វ៉ែន ឈរជើងចាប់ពីពហុកីឡាដ្ឋានអូឡាំពិក រហូតដល់ពេទ្យលោកសង្ឃ ហើយកម្លាំងមួយចំនួនទៀតទៅបង្កបង្កើនផលនៅវត្តពូនភ្នំ ម្តុំអន្លង់ក្ងាន ។ ក្រោយមកកងពល១៤ បានប្តូរទៅជាកងពល៨០១វិញ ដោយប្រកាសជាផ្លូវការ នៅស្តាតអូឡាំពិក ដែលមាន ប៉ុល ពត និង អៀង សារី ចូលរួមក្នុងពិធីនោះដែរ ។ កងពល៨០១នេះ មានទិសដៅឈរជើងការពារព្រំដែនរតនគិរី ។

នៅរតនគិរី វរសេនាធំទាំងបីដែលចំណុះឲ្យកងពល៨០១ គឺឈរជើងនៅទីតាំងខុសៗគ្នា ដោយវរសេនាធំ៨១ ឈរជើងនៅសាលាក្រោង, វរសេនាធំ៨២ ឈរជើងនៅព្រំដែនលាវ សាលាសេសាន និងវរសេនាធំ៨៣ ឈរជើងនៅអូរតាម៉ោក ។

ឆ្នាំ១៩៧៧ ប៉ុល ពត បានហៅកងពល៨០១ ប្រធានវរសេនាធំ មករៀនសូត្រ ហើយក៏រកគ្រួសារឲ្យ វ៉ែន ប៉ុន្តែ រកមិនទាន់ត្រូវចិត្តក៏ស្នាក់នៅអគ្គសេនាធិការជាមួយ សុន សេន សិន ។ ក្រោយពេលរៀបគ្រួសារហើយ វ៉ែន ក៏ត្រឡប់ទៅនៅបានលុង ជាមួយប្រពន្ធ ហើយរស់នៅទីនោះ រហូតដល់ពេលវៀតណាមវាយចូលមកតាមព្រំដែន គាត់ក៏បែកពីប្រពន្ធចាប់ពីពេលនោះមក ។ បន្ទាប់ពីវៀតណាមវាយចូល វ៉ែន និងកម្លាំងមួយចំនួនទៀត បានភៀសខ្លួនទៅភ្នំ១០០១ ដើម្បីទៅជួប តា០៥ ។ ក្រោយមក វ៉ែន ត្រូវបានថ្នាក់លើតែងតាំងជាប្រធានកងពល៦០៧ ដែលមានឈ្មោះ ញ៉ាន់ ជាអនុរបស់គាត់ ។ កងពលរបស់ វ៉ែនគឺចុះធ្វើការនៅខាងស្រុកសាលាវិស័យ ខេត្តកំពង់ធំ គឺដើរបញ្ចុះបញ្ចូលប្រជាជនឲ្យចូលរួម និងឧបត្ថម្ភខ្មែរក្រហម ដើម្បីប្រឆាំងជាមួយវៀតណាម ។

មិនយូរប៉ុន្មាន បន្ទាប់ពីមានការចាប់ខ្លួន តាសារឿន និងតាសាន កម្លាំងនៅខាងអន្លង់វែង និងត្រពាំងប្រាសាទបានសម្រេចចិត្តចុះចូលជាមួយរដ្ឋាភិបាល ។ វ៉ែន ក៏ទទួលតំណែងជាអភិបាលរងស្រុកត្រពាំងប្រាសាទ ។ សព្វថ្ងៃនេះ វ៉ែន និងគ្រួសាររស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ **រី លក្ខិណា**

# ចាប់ពីរបបខ្មែរក្រហម ដល់ឧបទ្ទវហេតុ ហាំ បាលី ៖ អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

***(តពីលេខមុន)***

***ជំពូក២៖ ទិដ្ឋភាពទូទៅនៃជាតិពន្ធុចាម***

ជំពូកនេះនឹងពិភាក្សាលម្អិតអំពីប្រវត្តិសហគមន៍ចាម រួមមាន ចំនួន និងរបាយប្រជាជន មុខរបរ ភាសា សម្លៀកបំពាក់ ការរៀបការឆ្លងសាសន៍ ការប្រណិប័តន៍សាសនា និងពិធីដែលទាក់ទងនឹងវដ្តជីវិត ដែលទាំងអស់នេះបង្កើតបានជាអត្តសញ្ញាណស្នូល និងជាយរបស់ជនជាតិចាម ហើយដែលផ្ដាច់ជនជាតិចាមចេញពីក្រុមជាតិពន្ធុដទៃទៀតនៅក្នុងប្រទេសកម្ពុជា ។ ជំពូកនេះគឺជាចំណុចចាប់ផ្ដើមដែលនាំទៅដល់ការពិភាក្សាអំពីប្រវត្តិសាស្ត្រចាម និងបទពិសោធជនជាតិចាមនៅក្រោមរបបខ្មែរក្រហម និងក្នុងសង្គមបច្ចុប្បន្ន ។ ជំពូកនេះ ចាប់ផ្ដើមដោយពិភាក្សាទៅលើចំនួនជនជាតិចាមនៅក្នុងប្រទេសកម្ពុជា របាយប្រជាជនចាមនៅតាមតំបន់នានាក្នុងប្រទេស មុខរបរ ពិធីផ្សេងៗជុំវិញការវិវត្តនៃជីវិត ការធ្វើធម្មយាត្រាទៅកាន់ទីក្រុងម៉ាកាស និងសម្លៀកបំពាក់ចាម ។ ជំពូកនេះនឹងបញ្ចប់ទៅវិញដោយពិភាក្សាទៅលើការរៀបការឆ្លងសាសន៍ ។

**១) ចំនួនប្រជាជនចាម**

អ្នកកាន់សាសនាម៉ូស្លីមបង្កើតបានជាក្រុមជនជាតិភាគតិចធំជាងគេនៅក្នុងប្រទេសកម្ពុជា ហើយជនជាតិចាម គឺជាក្រុមជនជាតិដែលកាន់សាសនាអ៊ីស្លាមធំជាងគេបង្អស់ ។ សារព័ត៌មានតែងដកស្រង់ចំនួនប្រជាជនម៉ូស្លីមនៅក្នុងប្រទេសកម្ពុជាថា មានចំនួនពី៤សែនទៅ៦សែននាក់ ។ នៅឆ្នាំ២០០៦ របាយការណ៍ស្ដីអំពីអំពើភេរវកម្មនៅអាស៊ីអាគ្នេយ៍ បានដកស្រង់ថា ប្រជាជនម៉ូស្លីមនៅប្រទេសកម្ពុជាមានចំនួនប្រមាណ៥សែននាក់ ។ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឯកឧត្តម មិន ឃិន បាននិយាយនៅឆ្នាំ២០០៩ថា ប្រជាជនម៉ូស្លីមនៅកម្ពុជាមានប្រមាណ៤សែន៦ម៉ឺននាក់ ។

របាយការណ៍អំពីចំនួនប្រជាជនម៉ូស្លីមនៅប្រទេសកម្ពុជាច្រើនលើសពីចំនួនពិតជាក់ស្ដែង ។ នៅមិនទាន់មានការអះអាងច្បាស់លាស់នៅឡើយ អំពីមូលហេតុដែលបណ្ដាលឲ្យមានរបាយការណ៍បែបនេះ ប៉ុន្តែបញ្ហានេះប្រហែលជាទាក់ទងនឹងការផ្ដល់ឲ្យសហគមន៍ម៉ូស្លីមនូវតួនាទីសំខាន់ជាងមុន នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងសហគមន៍ម៉ូស្លីមសកលលោក ។ មូលហេតុផ្សេងទៀតនោះ អាចជាការទាក់ទាញអ្នកផ្ដល់ជំនួយ និងក្រុមអ្នកនយោបាយឲ្យមានចំណាប់អារម្មណ៍កាន់តែខ្លាំងទៅលើសហគមន៍នេះ ។

***ស្ថិតិជំរឿនប្រជាជនកម្ពុជា***

ជំរឿនដែលធ្វើដោយក្រសួងផែនការពីថ្ងៃទី៣ ដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ បង្ហាញឲ្យឃើញថា ប្រជាជនកម្ពុជាមានចំនួនសរុបប្រមាណ១៣លាន៤សែននាក់ ក្នុងនោះ៤៨.៦ភាគរយជាបុរស ដែលមានអត្រាកំណើនប្រចាំឆ្នាំប្រមាណជា ១.៥៤ភាគរយពីឆ្នាំ១៩៩៨ ដល់២០០៨ ។ ស្ថិតិនេះបង្ហាញពីកំណើនចំនួនប្រជាជនប្រមាណជា៤៨ភាគរយនៅក្នុងរយៈពេល៤៦ឆ្នាំ ប្រៀបធៀបនឹងស្ថិតិជំរឿនដំបូងដែលធ្វើឡើងនៅឆ្នាំ១៩៦២ ដោយរដ្ឋាភិបាល បន្ទាប់ពីកម្ពុជាទទួលបានឯករាជ្យពីបារាំង ។ កាលនោះប្រជាជនកម្ពុជាមានចំនួនតែ៥លាន៧សែននាក់ប៉ុណ្ណោះ ។

ជំរឿនឆ្នាំ២០០៨រកឃើញថា ខេត្តកំពង់ចាម ដែលមានប្រជាជនចាមរស់នៅច្រើន គឺជាខេត្តដែលមានចំនួនប្រជាជនច្រើនជាងគេបំផុតគឺ ១២.៥៤ភាគរយនៃចំនួនប្រជាជនសរុប ។ ផ្ទុយទៅវិញ ខេត្តបាត់ដំបង មានចំនួនប្រជាជនចាមរស់នៅមិនច្រើនប៉ុន្មាន ដែលខេត្តនេះត្រូវបានចាត់ទុកថា ជាជង្រុកស្រូវនៃប្រទេសកម្ពុជា មានប្រជាជនប្រមាណតែ៧.៦ភាគរយនៃចំនួនប្រជាជនសរុប ។ ខេត្តដែលមានប្រជាជនរស់នៅតិចជាងគេបំផុតគឺខេត្តកែប ដែលទើបបង្កើតថ្មីនៅតំបន់ឆ្នេរសមុទ្រ ។ ខេត្តនេះមានចំនួនប្រជាជនប្រមាណតែ០.៣ភាគរយនៃប្រជាជនសរុប ។ ខេត្តកែប មានប្រជាជនចាម និង ជ្វា តិចជាង១ពាន់នាក់ ។

តំបន់ដែលមានប្រជាជនរស់នៅផ្ដុំគ្នាច្រើនជាងគេបំផុត គឺ

ខេត្តនៅតំបន់ទំនាបប៉ែកខាងត្បូងដែលស្ថិតនៅភាគអាគ្នេយ៍ និង និរតីនៃទីក្រុងភ្នំពេញ ។ តំបន់នេះមានដង់ស៊ីតេប្រជាជនរស់នៅជាមធ្យមពី១០០ទៅ១៩៩នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា ។ ទីតាំងនេះគឺជាតំបន់ដែលមានជនជាតិចាមរស់នៅច្រើនជាងគេបង្អស់ (សូមមើលផែនទី១) ។ ខេត្តដែលមានប្រជាជនរស់នៅផ្ដុំគ្នាតិចជាងគេបំផុត គឺខេត្តដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាបភាគឦសាន ។ តំបន់នេះមានដង់ស៊ីតេប្រជាជនទាប មុនពេលព្រះបាទនរោត្តមសីហនុបង្កើតខេត្តរតនគីរីក្នុងឆ្នាំ១៩៦២ និងខេត្តមណ្ឌលគីរីក្នុងឆ្នាំ១៩៦៤ ដើម្បីឲ្យប្រជាជនទៅតាំងទីលំនៅ ។

យោងតាមស្ថិតិជំរឿនឆ្នាំ២០០៨ ប្រជាជនដែលកើតរវាងឆ្នាំ១៩៨០ និង២០០៨ មានចំនួន៦៣.៨៦ភាគរយនៃចំនួនប្រជាជនសរុប ។ អ្នកដែលកើតរវាងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មាន៥.៥៨ភាគរយ ។ ក្នុងពេលខ្មែរក្រហមឡើងកាន់អំណាចប្រជាជនកម្ពុជាដែលមានអាយុចាប់ពី៧ឆ្នាំឡើងទៅ មានចំនួន២៣.៣១ភាគរយនៃប្រជាជនសរុបសព្វថ្ងៃ ។ ប្រជាជនទាំងអស់នេះជាអ្នកដែលអាចផ្ទេរបទពិសោធ និងរឿងរ៉ាវជីវិតនៅក្នុងរបបខ្មែរក្រហមទៅកាន់ក្មេងជំនាន់ក្រោយ ។ ប្រសិនបើខ្មែរក្រហមមិនបានចូលកាន់កាប់អំណាចនោះ ប្រជាជនដែលកើតមុន និងក្នុងឆ្នាំ១៩៦៨ នឹងក្លាយជាចំនួនប្រជាជនដែលមានភាគរយខ្ពស់បំផុត ។ ដោយមូលហេតុថា ទិន្នន័យនេះមានរួមបញ្ចូលទាំងជនជាតិចាម ហើយភាគរយដែលបានលើកឡើងខាងលើក៏តំណាងឲ្យក្រុមអាយុរបស់ជនជាតិចាមដែរ ។

ជំរឿនប្រជាជនឆ្នាំ២០០៨ ផ្ដល់នូវតួលេខប្រជាជនតាមប្រភេទសាសនា ។ អ្នកកាន់សាសនាព្រះពុទ្ធមាន ៩៦.៩ភាគរយនៃប្រជាជនសរុប រីឯគ្រិស្តសាសនិកមាន ០.៣៧ភាគរយ ។ មូស្លីមមានចំនួន១.៩២ភាគរយនៃចំនួនប្រជាជនសរុប ។ តួលេខនេះ មានកម្រិតទាបគួរឲ្យមន្ទិលសង្ស័យ ។ នេះអាចបណ្ដាលមកពីបញ្ហាមួយចំនួនទាក់ទងទៅនឹងរបៀបសួរប្រជាជនឲ្យរាយការណ៍ពីសាសនារបស់ខ្លួន ។ អ្នកដែលរស់នៅ និងធ្វើការលាយឡំគ្នា និងអ្នកកាន់ព្រះពុទ្ធសាសនាច្រើនតែឆ្លើយថាខ្លួនជាពុទ្ធសាសនិក ជាជាងឆ្លើយថាខ្លួនកាន់សាសនាអ៊ីស្លាម ឬសាសនាគ្រិស្ត ។ បើសន្មតថា មូស្លីមមាន ១.៩២ភាគរយនៃចំនួនប្រជាជនសរុប នោះតួលេខប្រជាជនមូស្លីមមានតែ២សែន៦ម៉ឺននាក់ ។ ចំនួននេះមានកម្រិតទាប ប្រសិនបើប្រៀបធៀបជាមួយទិន្នន័យបានមកពីប្រភពផ្សេង ។ ភាពខុសគ្នានេះបណ្ដាលឲ្យអ្នកនិពន្ធសម្រេចចិត្តធ្វើការស្រង់ស្ថិតិជាមួយប្រជាជនចាម និងមូស្លីមនៅក្នុងប្រទេសកម្ពុជាដោយខ្លួនឯង ។

**ការស្រង់ស្ថិតិប្រជាជន**

អ្នកនិពន្ធបានធ្វើការស្រង់ស្ថិតិប្រជាជននៅខែតុលា ឆ្នាំ២០១០ ដោយមានជំនួយពីនិស្សិតស្ម័គ្រចិត្ត១០នាក់ ។ គោលបំណងនៃការស្រង់ស្ថិតិនេះ គឺដើម្បីស្វែងរកនូវព័ត៌មានត្រឹមត្រូវជាងមុន អំពីចំនួនប្រជាជន និងទីកន្លែងដែលប្រជាជនមូស្លីម និងប្រជាជនចាមរស់នៅ ។ គណៈចាងហ្វាងដឹកនាំជាន់ខ្ពស់នៃសាសនាអ៊ីស្លាមកម្ពុជា ឬហៅថាការិយាល័យ មូហ្វទី មានតួនាទីក្នុងការគ្រប់គ្រងកិច្ចការក្រុមមូស្លីមនៅកម្ពុជាបានរៀបចំនូវបញ្ជីឈ្មោះភូមិមូស្លីមនៅទូទាំងប្រទេស ប៉ុន្តែការិយាល័យនេះគ្មានតួលេខគ្រួសារ និងប្រជាជននៅក្នុងភូមិនីមួយៗទេ ។ បញ្ជីឈ្មោះភូមិបានមកពីក្រុមប្រឹក្សានេះបង្ហាញថា មានភូមិមូស្លីមទាំងអស់៤៥៤ភូមិនៅទូទាំងប្រទេស ។ ទោះជាយ៉ាងនេះក្ដី បញ្ជីនេះមិនបានបញ្ចូលខេត្តស្វាយរៀង និងព្រៃវែងទេ ។ មន្ត្រីនៅក្នុងក្រុមប្រឹក្សានេះបានបញ្ជាក់ថា ខេត្តទាំងពីរនេះមានជនជាតិមូស្លីមរស់នៅតិចតួចជាងគេនៅក្នុងប្រទេស ហើយភូមិមូស្លីមនៅខេត្តនោះក៏មិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីនៅឡើយ ។

យោងតាមឧកញ៉ា សុះ កាំរី ដែលជាចាងហ្វាង មូហ្វទី បានបញ្ជាក់ថា បញ្ជីនេះមានបញ្ហាមួយទៀត គឺថា បញ្ជីនេះបញ្ចូលតែភូមិដែលមានប្រជាជនរស់នៅចាប់ពី២០គ្រួសារឡើងទៅ ។ នៅក្នុងការគណនាចំនួនជនជាតិមូស្លីម អ្នកនិពន្ធត្រូវបញ្ចូលចំនួនជាមធ្យមរបស់គ្រួសារដែលមិនទាន់បានបញ្ចូលនៅក្នុងបញ្ជីដើម ។ ចំនួនភូមិដែលមានតិចជាង២០គ្រួសារ ដែលមិនបានរាប់បញ្ចូលក្នុងបញ្ជីនោះ គួរតែមានមិនច្រើននោះទេ ។ ចំណុចសំខាន់ដែលគួរឲ្យកត់សម្គាល់នោះគឺថា ជនជាតិមូស្លីមច្រើនតែរស់នៅក្នុងភូមិដាច់ដោយឡែកពីក្រុមជាតិពន្ធុផ្សេងៗទៀត ។ ហេតុនេះ ភូមិមូស្លីមដែលមាននៅក្នុងបញ្ជីភាគច្រើន មានតែជនជាតិមូស្លីមសុទ្ធ ។ ទោះជានៅក្នុងករណីដែលគ្រួសារមូស្លីមរស់នៅភូមិខ្មែរដែលស្ថិតនៅក្បែរភូមិមូស្លីម គ្រួសារមូស្លីមទាំងនេះត្រូវបានរាប់

បញ្ចូលថាជាសមាជិកភូមិមូស្លីម ។ ករណីនេះឃើញមាននៅភូមិស្វាយឃ្លាំង និងភូមិដទៃទៀតក្នុងឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

ករណីមួយទៀតដែលត្រូវពិចារណានៅពេលរាប់ជនជាតិមូស្លីមគឺថា សព្វថ្ងៃជនជាតិមូស្លីមកាន់តែច្រើនបានផ្លាស់ទីលំនៅចេញពីភូមិរបស់ខ្លួនទៅរស់នៅលាយឡំនឹងជនជាតិខ្មែរ និងក្រុមជនជាតិផ្សេងៗទៀត ។ ករណីនេះកើតមាននៅក្នុងតំបន់មួយចំនួនដូចជារាជធានីភ្នំពេញ នៅតាមព្រំដែនក្រុងប៉ោយប៉ែត ស្រុកបាទី ខេត្តតាកែវ និងតំបន់ផ្សេងៗទៀត ។ ក្នុងស្ថានភាពបែបនេះ ស្ថិតិសរុបដែលទទួលបាន ត្រូវបានលៃតម្រូវទៅតាមភាពមិនប្រក្រតីនេះ ។

វិធីសាស្ត្រដែលអ្នកនិពន្ធប្រើប្រាស់ក្នុងការប្រមូលស្ថិតិប្រជាជន គឺសួរមេភូមិ មេឃុំ អភិបាលស្រុក និងហាកិម របស់សហគមន៍មូស្លីមទូទាំងប្រទេស ដោយប្រើប្រាស់បញ្ជីឈ្មោះភូមិដែលទទួលបានខាងលើ ។ ដើម្បីបានលេខទូរស័ព្ទរបស់មេភូមិមូស្លីម គឺត្រូវការការសហការពីប្រធានភូមិជាច្រើននាក់ ។ បីសប្តាហ៍បន្ទាប់មក អ្នកនិពន្ធទទួលបានតួលេខពេញលេញអំពីចំនួនប្រជាជនមូស្លីមពីទូទាំងប្រទេស ។ ចំនួនប្រជាជនមូស្លីមសរុបដែលអ្នកនិពន្ធបានរាប់គឺ ៣៣០.៤៥០នាក់ រាប់បញ្ចូលទាំងជនជាតិមូស្លីមនៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ។ ដូចដែលការសន្មត ប្រជាជនចំនួន ១ម៉ឺននាក់ ថែមទៀតត្រូវបានបូកបញ្ចូលទៅក្នុងតួលេខខាងលើ ដើម្បីគិតបញ្ចូលជនជាតិមូស្លីមដែលបានផ្លាស់ទីលំនៅ និងប្រជាជននៅភូមិដែលមានតិចជាង២០គ្រួសារ ហើយដែលមិនបានរាប់បញ្ចូលទៅក្នុងបញ្ជី ។ ទាំងអស់នេះនាំឲ្យតួលេខសរុបប្រជាជនមូស្លីមមានដល់៣៤០.៤៥០នាក់ក្នុងឆ្នាំ២០១០ ដែលត្រូវជា ២.៥ភាគរយនៃតួលេខប្រជាជនកម្ពុជាសរុប ។

គ្មានទិន្នន័យជាក់លាក់ណាមួយដែលប្រមូលបានទាក់ទងនឹងការបែងចែកចំនួនប្រជាជនចាម និង ជ្វា ទេ ។ យោងតាម អ៊ីសា ខុស្មាន ជាជនជាតិចាម និងអ្នកស្រាវជ្រាវអំពីបទពិសោធជនជាតិចាមក្រោមរបបខ្មែរក្រហម ចំនួនជនជាតិជ្វាមានប្រមាណជា ២០ភាគរយនៃចំនួនប្រជាជនមូស្លីមសរុបនៅក្នុងប្រទេសកម្ពុជា ។ ហេតុនេះ តួលេខមូស្លីមសរុប ៣៤០.៤៥០នាក់ កាត់ចេញនូវជនជាតិជ្វា២០ភាគរយ យើងនឹងឃើញតួលេខជនជាតិចាម ។ លទ្ធផលគឺថាប្រជាជនចាម សរុបមានចំនួន ២៧២.៣៦០នាក់ ក្នុងឆ្នាំ ២០១០ ។ បើធ្វើការទូទាត់ជាមួយអត្រាកំណើន១.៥៤ភាគរយ លទ្ធផលសរុបចំនួនប្រជាជនចាមគឺ ២៧៦.៥៥៤នាក់ ក្នុងឆ្នាំ ២០១១ ដែលត្រូវជា២ភាគរយនៃចំនួនប្រជាជនសរុប ។

ស្ថិតិប្រជាជននេះបង្ហាញថា ជាក្រុមជាតិពន្ធុ ជនជាតិចាម មានចំនួនតិចណាស់ ប្រៀបធៀបនឹងចំនួនប្រជាជនសរុបនៅប្រទេសកម្ពុជា ។ ហេតុផលនេះអាចពន្យល់ពីរបៀបដែលជនជាតិចាមកសាងអត្តសញ្ញាណសេដ្ឋកិច្ច និងនយោបាយ នៅក្នុងប្រទេសកម្ពុជា ហើយក៏អាចពន្យល់ពីអត្តសញ្ញាណនយោបាយ របស់ជនជាតិចាមទាក់ទងនឹងជនជាតិខ្មែរ និងជ្វា ។

## ៣) ទីតាំងភូមិសាស្ត្រជនជាតិចាម

លទ្ធផលពីការស្រង់ស្ថិតិនេះ អាចឲ្យយើងដឹងអំពីទីតាំងដែលជនជាតិចាមតាំងទីលំនៅក្នុងប្រទេសកម្ពុជា ។ ការយល់ដឹងអំពីទីកន្លែងដែលជនជាតិចាមរស់នៅនាំឲ្យយើងមានឱកាសយល់ដឹងអំពីបម្រែបម្រួលផ្សេងទៀត របស់ជនជាតិចាម ដូចជា មុខរបរ ប្រវត្តិសាស្ត្រ និងវប្បធម៌ ។ ស្ថិតិនេះបានបង្ហាញឲ្យឃើញថា ខេត្តកំពង់ចាម មានប្រជាជនចាមរស់នៅច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ។ ខេត្តនេះមានជនជាតិចាមរស់នៅប្រមាណ ១៣៨.១៧៧ នាក់ ត្រូវជា៤២ភាគរយ នៃចំនួនប្រជាជនមូស្លីមសរុប ។ ខេត្តដែលមានប្រជាជនចាម រស់នៅច្រើនជាងគេទីពីរគឺខេត្តកំពង់ឆ្នាំង ដែលមានចំនួនសរុប ២៦.៧៤៨នាក់ និងទីបីគឺខេត្តកំពត ដែលមានជនជាតិចាម និង ជ្វា សរុប ២០.០៩៩នាក់ ។ តារាងទី១ បង្ហាញអំពីរបាយការណ៍ប្រជាជនចាមដែលបែងចែកតាមខេត្ត រួមជាមួយនឹងជនជាតិជ្វា គិតជាភាគរយ ៖

**តារាងទី១ ប្រជាជនមូស្លីមបែងចែកតាមខេត្ត**

| ល.រ | ខេត្ត | ជ្វា | ចំនួន |
|---|---|---|---|
| ១ | កំពង់ចាម | ០% | ១៣៨.១៧៧<br>(៤២%នៃចំនួនប្រជាជន មូស្លីមសរុប) |

| | | | |
|---|---|---|---|
| ២ | កំពង់ឆ្នាំង | ០% | ២៦.៧៤៨ |
| ៣ | ភ្នំពេញ | ១០% | ២៤.៥៤៩ |
| ៤ | កំពត | ៧០% | ២០.០៩៩ |
| ៥ | ក្រចេះ | ០% | ១៩.៣៨០ |
| ៦ | កណ្តាល | ១៥% | ១៦.១៣២ |
| ៧ | បាត់ដំបង | ៧០% | ១៥.៥៦៣ |
| ៨ | ពោធិ៍សាត់ | ០% | ១៤.៧៦៧ |
| ៩ | ព្រះសីហនុ | ៨០% | ១១.៧៣៦ |
| ១០ | មណ្ឌលគិរី | ១០% | ១១.២៦៧ |
| ១១ | កោះកុង | ១៥% | ៧.៨៥៣ |
| ១២ | តាកែវ | ៧០% | ៦.០១៩ |
| ១៣ | បន្ទាយមានជ័យ | ០% | ៤.២៩០ |
| ១៤ | កំពង់ធំ | ០% | ៤.២៦១ |
| ១៥ | សៀមរាប | ០% | ៣.១៩០ |
| ១៦ | រតនគិរី | ១០% | ២.៥៣២ |
| ១៧ | ព្រៃវែង | ០% | ២.០១២ |
| ១៨ | ប៉ៃលិន | ០% | ៩៩៤ |
| ១៩ | កែប | ៨០% | ៨៥០ |
| ២០ | ព្រះវិហារ | ០% | ៥៨៤ |
| ២១ | កំពង់ស្ពឺ | ០% | ៤៤១ |
| | **សរុប** | ២០% (ជាមធ្យម) | ៣៣០.៤៥០នាក់ |

តារាងទី២ បង្ហាញអំពីស្រុកដែលមានជនជាតិចាមរស់នៅច្រើនជាងគេ។ ខេត្តកំពត និងស្រុកព្រៃទប់ មានជនជាតិជ្វារស់នៅច្រើនជាងគេ។ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម គឺជាស្រុកដែលមានជនជាតិចាមរស់នៅច្រើនជាងគេនៅក្នុងប្រទេសកម្ពុជាគឺ៤៣.០៧៥នាក់។ ក្នុងចំណោមស្រុកធំៗដប់ស្រុក ប្រាំមួយស្ថិតនៅក្នុងខេត្តកំពង់ចាម ដែលមានសុទ្ធតែប្រជាជនចាមរស់នៅ។ ស្រុក៤ទៀតស្ថិតក្នុងខេត្តកំពង់ឆ្នាំង កំពត ក្រចេះ និងព្រះសីហនុ។ ប្រជាជនមូស្លីមនៅក្នុងតំបន់រាជធានីភ្នំពេញមានប្រហែល២៤.៥៤៩នាក់។

**តារាងទី២ ស្រុកប្រាំបីដែលមានជនជាតិចាមរស់នៅច្រើនជាងគេ**

| **ល.រ** | **ឈ្មោះស្រុក** | **ខេត្ត** | **ចំនួន** |
|---|---|---|---|
| ១ | ត្បូងឃ្មុំ | កំពង់ចាម | ៤៣.០៧៥នាក់ |
| ២ | ក្រូចឆ្មារ | កំពង់ចាម | ៣៣.២៨៧នាក់ |
| ៣ | កំពង់ត្រឡាច | កំពង់ឆ្នាំង | ១៨.០០៤នាក់ |
| ៤ | តំបែរ | កំពង់ចាម | ១៦.៦៨៩នាក់ |
| | កំពត | កំពត (ចាម២០%) | ១៥.៩៤០នាក់ |

| | | | |
|---|---|---|---|
| ៥ | ឆ្លូង | ក្រចេះ | ១៨.០២៦នាក់ |
| | ព្រែនប់ | ព្រះសីហនុ (ចាម២០%) | ១០.៧៨៦នាក់ |
| ៦ | ស្ទឹងត្រង់ | កំពង់ចាម | ១០.២៥៣នាក់ |
| ៧ | ពញាក្រែក | កំពង់ចាម | ៩.៩២៥នាក់ |
| ៨ | មេមត់ | កំពង់ចាម | ៩.៤៤៤នាក់ |

ស្ថិតិរបស់អ្នកនិពន្ធបង្ហាញថា ជនជាតិចាមច្រើនតែតាំងទីលំនៅក្បែរទឹក ។ ចាមរស់នៅតាមដងទន្លេមេគង្គ ចាប់ពីស្រុកឆ្លូង ខេត្តក្រចេះ នៅភាគខាងជើង កាត់ទៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម និងស្រុកផ្សេងៗទៀតដែលមានជនជាតិចាមរស់នៅច្រើន ចុះទៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលស្ថិតនៅភាគកណ្តាលប៉ែកខាងត្បូងប្រទេស ។ ទោះបីជាស្រុកខ្សាច់កណ្ដាលគឺជាទីតាំងពិសិដ្ឋសម្រាប់ក្រុមអ៊ីស្លាមអ៊ីម៉ាំសាន់ ស្រុកនេះគ្មានភូមិចាមនោះទេ ។ ឆ្លងកាត់ស្រុកខ្សាច់កណ្ដាលឆ្ពោះទៅទិសខាងត្បូង ចំនួនប្រជាជនចាមចាប់កើនឡើងនៅស្រុកមុខកំពូល ខេត្តកណ្ដាល ហើយនៅខាងត្បូងទៅទៀត ស្រុកកោះធំក៏មានប្រជាជនចាមរស់នៅច្រើន ។ ជនជាតិចាមខ្លះរស់នៅតាមតំបន់ឆ្នេរសមុទ្រ ខេត្តព្រះសីហនុ កំពត និងកោះកុង ។ នៅខេត្តកំពត ជនជាតិម៉ូស្លីម៣០ភាគរយ គឺជាជនជាតិចាម ។

ប្រជាជនចាមមួយចំនួនរស់នៅតាមព្រំដែនវៀតណាម និងមួយចំនួនតូចរស់នៅតាមព្រំដែនថៃ ។ នៅតាមព្រំដែនខាងកើត ស្រុកមេមត់ មានជនជាតិចាមចំនួន ៩.៤៤៤នាក់ ស្រុកស្នួលមាន ៤.៧៣៤នាក់ ស្រុកកែវសីមា មានប្រមាណ ៦.០០០នាក់ និងស្រុកពេជចិន្ដាមាន ៥.២៦៧នាក់ ។ ផែនទីខាងក្រោមបង្ហាញស្រុកដែលមានជនជាតិចាម និង ជ្វារស់នៅច្រើនជាង ៣.០០០នាក់ និងស្រុកប្រាំបីទៀត ដែលមានជនជាតិចាមរស់នៅច្រើនបំផុត ។ ផែនទីទី១ ទីតាំងជនជាតិចាម និង ជ្វា នៅប្រទេសកម្ពុជា

កំណត់ចំណាំៈ

- ◆ ពណ៌ប្រផេះក្រាស់បង្ហាញទីលំនៅជនជាតិចាម
- ◆ ពណ៌ប្រផេះស្លេកបង្ហាញទីលំនៅជនជាតិជ្វា
- ◆ ស្រុកដែលមានប្រជាជនចាប់ពីពាន់នាក់ឡើងទៅជាពណ៌ស្រមោល

ទីតាំងដែលម៉ូស្លីមនៅប្រទេសកម្ពុជារស់នៅសព្វថ្ងៃត្រូវគ្នានឹងទីតាំងភូមិសាស្ត្ររបស់ខ្មែរក្រហមតំបន់២១ នៃភូមិភាគបូព៌ា ផ្នែកខាងលិចតំបន់២២ នៃភូមិភាគបូព៌ា តំបន់៤២ និង៤១ នៃភូមិភាគកណ្ដាល និងខុត្តរ និងតំបន់៣១ នៃភូមិភាគបស្ចិម ។ ផ្អែកទៅលើតួលេខដែលយើងមាននាពេលបច្ចុប្បន្ន ភូមិភាគបូព៌ាតែឯង មានជនជាតិចាមរស់នៅរហូតដល់ទៅ៦០ភាគរយនៃចំនួនជនជាតិចាមនៅប្រទេសកម្ពុជាទាំងអស់ ។ ព័ត៌មាននេះមានសារសំខាន់នៅពេលធ្វើការគណនាចំនួនជនជាតិចាមដែលស្លាប់នៅក្នុងរបបខ្មែរក្រហម (ជំពូកបួន) ។

## ៣) មុខរបរជនជាតិចាម

ជនជាតិចាមច្រើនប្រកបមុខរបរជាអ្នកនេសាទ និងអ្នកកាប់គោ ។ ណូ ហាលីម៉ះ (No Halimah) និយាយថា «នៅទសវត្សរ៍ឆ្នាំ៥០ និង៦០ ឪពុកខ្ញុំគឺជាអ្នកនេសាទត្រី ។ នៅឆ្នាំ១៩៦៤ ខ្ញុំទៅខេត្តតាកែវ ទៅធ្វើជាអ្នកកាប់គោលក់» ។ ខេត្តសៀមរាបដែលមានប្រជាជនចាមរស់នៅមិនច្រើនប៉ុន្មាន ជនជាតិចាមភាគច្រើនប្រកបរបរជាអ្នកកាប់គោលក់ ។ នៅតាមបណ្ដោយដងទន្លេមេគង្គ និងជុំវិញបឹងទន្លេសាប ជនជាតិចាមច្រើនតែប្រកបរបរជាអ្នកនេសាទ ប៉ុន្តែជនជាតិចាមនៅតំបន់នោះមិនមែនធ្វើជាអ្នកនេសាទតែមួយមុខដើម្បីចិញ្ចឹមជីវិតនោះទេ ។ បើយោងតាមប្រធានសហគមន៍ចាមម្នាក់ នៅខេត្តកំពត ជនជាតិចាមប្រមាណ ៦០ភាគរយ ប្រកបរបរនេសាទសមុទ្រ ៣០ភាគរយធ្វើស្រែចម្ការ និង១០ភាគរយ ជាអ្នកកាប់គោ និងអ្នកជំនួញ ។ នៅខេត្តកំពង់ធំ ជនជាតិចាមភាគច្រើនប្រកបរបរធ្វើស្រែចម្ការ ។ ហ៊ីម លី (Him Ly) និយាយថា «មុនរបបខ្មែរក្រហម ឪពុកខ្ញុំធ្វើជាជាងដែក និងធ្វើស្រែ ។ ខ្ញុំធ្វើតាមទម្លាប់គ្រួសារ ហើយមិនពាក់ព័ន្ធនឹងការធ្វើជំនួញរកស៊ីទេ» ។

រដូវនេសាទចាប់ផ្ដើមជាផ្លូវការនៅថ្ងៃទី១ ខែតុលា ហើយបញ្ចប់ទៅវិញនៅថ្ងៃទី៣០ ខែឧសភា ដែលផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការធ្វើស្រែ និងដំណាំផ្សេងៗទៀតក្នុងអំឡុងរដូវ

វស្សា ។ បន្ទាប់ពីរដូវនេសាទបញ្ចប់ទៅ អ្នកនេសាទជនជាតិចាមនៅស្រុកក្រូចឆ្មារ ដាំដំណាំផ្សេងៗដូចជា ថ្នាំជក់ បន្លែ និងស្រូវ ។ ប៉ុន្តែ ចំពោះចាមមួយចំនួននៅក្នុងតំបន់នេះ ការនេសាទមិនមែនជាមុខរបរចម្បងនោះទេ ។ នៅតំបន់ទំនាបមេគង្គខាងក្រោម ដូចជាខេត្តកណ្តាល ជនជាតិចាមក៏ដាំដំណាំនៅតំបន់លិចទឹកនៅរដូវទឹកឡើងដែរ ។ ជាធម្មតា ដំណាំនៅតំបន់នេះមិនសូវត្រូវការជីគីមីបន្ថែមទេ ។ នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចាមមួយចំនួនធំធ្វើស្រែម្តង ឬពីរដងក្នុងមួយឆ្នាំ ។

ជនជាតិចាមមួយចំនួនតូច ដូចជាចាមដែលរស់នៅក្រុងភ្នំពេញ រកស៊ីដោះដូរជាមួយនឹងថៃខាងត្បូង និងប្រទេសម៉ាឡេស៊ី ដូចជានាំចូលហែហ្ជាប់ (Hijabs) ពីប្រទេសម៉ាឡេស៊ី និងនាំចេញផលិតផលក្នុងស្រុក ដូចជា ត្រីងៀត ប្រហុក ព្រមទាំងផលិតផលសិប្បកម្ម ដែលចាមរស់នៅក្រៅស្រុកជឿថា ជាផលិតផលដែលមានគុណភាពខ្ពស់ ។

មុខរបរកាប់គោ គឺជាអាជីពដែលជនជាតិចាមចាប់យកដោយងាយ ។ ក្នុងសហគមន៍ដែលមានក្រុមជាតិពន្ធុចម្រុះ អ្នកកាប់គោលក់នៅទីផ្សារច្រើនតែជាជនជាតិចាម ។ មុខរបរនេះមិនសូវមានការប្រកួតប្រជែងពីជនជាតិខ្មែរ និងចិននោះទេ ។ ជនជាតិចិនធ្វើជំនួញជាមួយសាច់ជ្រូក និងផលិតផលដែលធ្វើពីសាច់ជ្រូក ឯជនជាតិខ្មែរលក់បន្លែ និងផលិតផលកំប៉ុង និងកញ្ចប់ ។ រៀងរាល់ចូលឆ្នាំចាម ដែលភាសាចាមហៅថា ហារី រ៉ាយ៉ា (Hari Raya) ជនជាតិចាមបូជាសត្វគោដែលមានសុខភាពល្អបីបួនពាន់ក្បាលនៅទូទាំងប្រទេស ។ ការប្រតិបត្តិបែបនេះធ្វើឲ្យជនជាតិចាមមានជំនាញ និងធនធានដើម្បីប្រកបរបររកស៊ីទាក់ទងនឹងសាច់គោ និងផលិតផលធ្វើពីសាច់គោ ។ ក្រៅពីធ្វើជាអ្នកលក់សាច់ នេសាទ និងដាំដំណាំ ជនជាតិចាមមួយចំនួនតូចប្រកបរបរលក់គ្រឿងទេស ធ្វើជាងម៉ាស៊ីន និងជួលម៉ាស៊ីនកិនស្រូវ ។

នៅទីក្រុងភ្នំពេញ ចាមមួយភាគធំនៅតែប្រកបរបរកាប់គោលក់ តែក៏មានចាមមួយចំនួនទៀត ប្រកបរបរផ្សេងទៀត ដូចជាធ្វើការនៅក្នុងរដ្ឋាភិបាល និងក្នុងអង្គការក្រៅរដ្ឋាភិបាល ។ ដោយសារចាមច្រើនតែរស់នៅជុំគ្នានៅតំបន់ព្រែកប្រា ប៉ែកអាគ្នេយ៍ទីក្រុងភ្នំពេញ ជ្រោយចង្វារ នៅខាងត្បូងសាន និងតំបន់ច្រាំងចម្រេះនៅខាងជើង តំបន់ទាំងនោះមានផ្សារសម្រាប់ជនជាតិចាម ដែលលក់ទំនិញត្រូវនឹងតម្រូវការរបស់ជនជាតិចាម ដូចជាសម្លៀកបំពាក់ និងរបស់របរអ៊ីស្លាម និងផលិតផលធ្វើពីសាច់គោ ។

សហគមន៍ចាមតែងតែមាន ហាគិម (Hakem) និង ទួន (Tuon) បីបួននាក់ ដើម្បីមើលការខុសត្រូវ និងរៀបចំពិធីសាសនា ព្រមទាំងបង្រៀនសាសនាអ៊ីស្លាមទៅអ្នកភូមិ ។ អ្នកទាំងនេះមិន



ជនជាតិចាមលក់ដូរក្រណាត់ និងសម្លៀកបំពាក់ នៅឃុំត្រា ស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ

បានទទួលប្រាក់ខែពីរដ្ឋាភិបាល ឬពីការិយាល័យ មូហ្វទី (Mufti) នៅភ្នំពេញ ។ ការងាររបស់អ្នកទាំងអស់នេះ ត្រូវបានទទួលស្គាល់ថាបានជួយទៅដល់សង្គម ។ ហេតុនេះ ហាគិម និងទួនច្រើនតែទទួលបានការគោរពពីសហគមន៍ ។ ហាគិម ក៏ដើរតួជាអ្នកទំនាក់ទំនងជាមួយម្ចាស់ផ្តល់ជំនួយមកពីខាងក្រៅ និងជាមួយអ្នកដែលចង់ជួយទៅដល់សហគមន៍ ។ ទោះជាយ៉ាងនេះក៏ដោយ ពេលខ្លះ

ហាកិម សុំឲ្យម្ចាស់ជំនួយ ទៅសុំការអនុញ្ញាតពីប្រធានភូមិ និងឃុំ ដើម្បីធ្វើសកម្មភាពនៅក្នុងសហគមន៍ ដូចជា ការសាងសង់វិហារ ការចែកចាយម្ហូបអាហារ និងកម្មវិធីបណ្តុះបណ្តាល និងរៀនសូត្រផ្សេងៗ ។ ហាកិម ត្រូវស្ថិតនៅក្រោមបង្គាប់ការិយាល័យ មូហ្វទីនៅភ្នំពេញ រីឯប្រធានភូមិគឺជាមន្ត្រីដែលស្ថិតនៅក្រោមបង្គាប់រដ្ឋាភិបាល ។ ទោះជា ហាកិម មានតួនាទីដឹកនាំសហគមន៍សំខាន់



ប៉ុណ្ណោះ ក៏គាត់នៅតែត្រូវការការអនុញ្ញាតពីប្រធានភូមិដើម្បីធ្វើសកម្មភាពនៅក្នុងភូមិដែរ ដើម្បីឲ្យស្របទៅតាមច្បាប់ទម្លាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។ ការអនុវត្តបែបនេះមានករណីលើកលែងមួយ ។ នៅភូមិទ្រា២ ដែលជាទីតាំងមូលដ្ឋានរបស់ ក្រុមតាប្លីហ្គ ចាមាត់ ទាបលិងហិ *(Jamaat)* ហាកិម ហាក់ដូចជា មានអំណាចលើប្រធានភូមិឃុំ ។

## ៤) ការប្រណិប័តន៍សាសនា

ជនជាតិចាមស្ទើរតែទាំងអស់កាន់សាសនាអ៊ីស្លាម ។ អ្នកនិពន្ធរកឃើញថា មានចាមមួយចំនួនតូចប៉ុណ្ណោះដែលកាន់សាសនាព្រះពុទ្ធ ។ “អ៊ីស្លាម” ជាពាក្យអារ៉ាប់មានន័យថា ការព្រមចុះចាញ់ ឬការគោរពប្រណិប័តន៍ រីឯ “អល់ឡោះ” *(Allah)* ជាពាក្យអារ៉ាប់មានន័យថា ព្រះ ។ ខុសពីព្រះពុទ្ធសាសនា និងជំនឿខ្មែរ អ៊ីស្លាមជាសាសនាដែលមានព្រះតែមួយគត់ ។ ទ្រឹស្តីសំខាន់នៅក្នុងសាសនានេះត្រូវបានហៅថា តាហ៊ីត *(Tawhid)* ជាភាសាអារ៉ាប់ មានន័យថា អាទិទេពមានតែមួយគត់គឺ ព្រះអល់ឡោះ ។ អល់ឡោះ គឺជាអាទិទេពនៃសកលលោក ជាទេពបង្កើតលោក ជាទេពនៃចំណេះដឹង ជាទេពបង្កើតច្បាប់ ជាចៅក្រម និងជាទេពដែលស្រោចស្រង់ជីវិត និងសេចក្តីស្លាប់ ។ ព្រះអល់ឡោះ បង្គាប់ឲ្យមូស្លីមទាំងអស់ ស្តាប់តាមការទូន្មានរបស់ព្រះអង្គ ដែលផ្សាយបន្តតាមរយៈ ទេព ហ្គេព្រីល *(Gabriel)* ទៅកាន់មហាម៉ាត់ *(Mohammad)* នៅឆ្នាំ៦១០នៃគ.ស នៅទីក្រុងម៉ាកាស ដែលកាលនោះ មហាម៉ាត់ មានអាយុប្រហែល ៤០ឆ្នាំ ។ ចំពោះពុទ្ធសាសនិកវិញ ការសាងអំពើល្អមិនមែនជាការធ្វើតាមបង្គាប់ព្រះពុទ្ធនោះទេ តែជាជម្រើសរបស់បុគ្គលនោះ បន្ទាប់ពីស្តាប់ការទូន្មានរបស់ព្រះពុទ្ធ ហើយយល់ថាអំពើល្អនឹងនាំទៅដល់បុណ្យ និងការសម្រេចព្រះនិព្វាន ។

ការផ្សព្វផ្សាយរបស់ទេព ហ្គេព្រីល *(Gabriel)* បានបន្តរហូតដល់រយៈពេល២២ឆ្នាំ ក្រោយមក ។ ពាក្យទូន្មានរបស់ព្រះអល់ឡោះ ត្រូវបានប្រមូលផ្តុំបង្កើតបានជាគម្ពីរគួរអាន (ឈុរាន) ។ មហាម៉ាត់គឺជាអ្នកបកស្រាយគម្ពីរគួរអានជូនគេ ដើម្បីឲ្យស្របគ្នានឹងស្ថានភាពរស់នៅ និងសង្គមរបស់គាត់នាសម័យនោះ ។ ការប្រណិប័តន៍ និងការបកស្រាយរបស់មហាម៉ាត់ត្រូវបានប្រមូលចងក្រងបានជាគម្ពីរ មួយហៅថា ស៊ុនណា *(Sunna)* ។ ជាលទ្ធផលមូស្លីមពឹងផ្អែកទៅលើគម្ពីរគួរអាន និង ស៊ុនណា ក្នុងការស្វែងយល់ពីសាសនាអ៊ីស្លាម និងធ្វើសកម្មភាពផ្សេងៗ នៅក្នុងសង្គមបច្ចុប្បន្ន ។ ទោះជាយ៉ាងនេះក៏ដោយ ការបកស្រាយគម្ពីរទាំងពីរនេះមានភាពប្លែកគ្នាពីប្រទេសកាន់សាសនាអ៊ីស្លាមមួយទៅប្រទេសមួយទៀត នៅទូទាំងពិភពលោក ។ ក្រុមគេរវិករអ៊ីស្លាម និងក្រុមជ្រុលនិយមមួយចំនួនជឿជាក់ថា សកម្មភាពហិង្សារបស់ក្រុមខ្លួនគឺ ជាការដាក់

ទណ្ឌកម្មរបស់ព្រះអល់ឡោះ ផ្ទុយទៅវិញ ជនជាតិចាម ជឿថា អ៊ីស្លាម គឺជាសាសនាសន្តិភាព ហើយព្រះអល់ឡោះនឹងដាក់ទោសទៅលើអ្នកដែលសម្លាប់មនុស្សស្លូតត្រង់ ។ ចាមអ៊ីមាំសាន់ ជឿថា អ៊ីមាំសាន់ គឺជាអ្នកដឹកនាំសាសនាដែលគួរជាទីគោរពបូជា ដូចគ្នានឹងមហាម៉ាត់ដែរ ។

គម្ពីរគួរអាន កត់ត្រាថា ព្យាការីសាសនាអ៊ីស្លាម Prophets មាន២៥នាក់ គឺរាប់ចាប់ពី អាដាម (Adam) ហើយបញ្ចប់ទៅវិញដោយ មហាម៉ាត់ ។ ព្យាការីផ្សេងទៀតមានដូចជា អាប្រាហាម (Abraham) ម៉ូសេ ( Mose) ដេវីដ (David) និងយេស៊ូ (Jesus) ។ ដូចនៅក្នុងសាសនាព្រះពុទ្ធដែរ មូស្លីមជឿទៅលើឋាននរក និងឋានសួគ៌ កន្លែងដែលព្រលឹងទៅទទួលផលពីអំពើដែលបានសាងកាលនៅជាមនុស្ស ។ សាសនានេះខុសពីព្រះពុទ្ធសាសនាត្រង់ថា ក្នុងព្រះពុទ្ធសាសនា សីលបានមកពីការត្រាស់ដឹងរបស់ព្រះពុទ្ធ និងការសម្រេចការយល់ដឹងពីពិភពមនុស្សលោកតាមរយៈការបួស ការធ្វើសម្មាធិ និងការបង្អត់អាហារ ។ សាសនាអ៊ីស្លាម ពឹងផ្អែកទាំងស្រុងទៅលើសារពីព្រះអល់ឡោះទៅមហាម៉ាត់ និងការបកស្រាយសារទាំងនោះរបស់មហាម៉ាត់ ។ មូស្លីម មិនចង់ឲ្យគេហៅថា មហាម៉ាត់ដាន (Mahammadans) ដោយសារតែខ្លួនជឿថា មហាម៉ាត់មិនមែនជានីរសាររបស់ព្រះតែម្នាក់នោះទេ ។

ជនជាតិចាមគោរពប្រណិប័តន៍លើគោលការណ៍ទាំង៥ នៅក្នុងសាសនាអ៊ីស្លាម៖ សាហាដា (Shahada) សឡាត់ (Salat) ហ្សាកាត់ (Zakat) ការបួសបង្អត់អាហារ និងការធ្វើធម្មយាត្រា ។ សាហាដាមានន័យថា ការធ្វើជាសាក្សីចំពោះមុខព្រះ (Bearing Witness) ។ មូស្លីម សូត្រឃ្លានេះក្នុងពេលខ្លួនថ្វាយបង្គំ ។ "ខ្ញុំធ្វើជាសាក្សីថា គ្មានព្រះណាផ្សេងក្រៅពីព្រះអល់ឡោះ" និង "ខ្ញុំធ្វើជាសាក្សីថា មហាម៉ាត់គឺជាអ្នកនាំសាររបស់ព្រះអល់ឡោះ" ដោយសារមូស្លីមភាគច្រើនគោរពតាម ស៊ុនណា (Sunna) ពេលខ្លះមូស្លីមបញ្ចូលឃ្លាដែលបញ្ជាក់ថា ខ្លួនជឿលើការបកស្រាយសាសនាអ៊ីស្លាមរបស់មហាម៉ាត់ ។

សឡាត់ មានន័យថាសំយ៉ាំង (ការថ្វាយបង្គំ) ។ មូស្លីមតម្រូវឲ្យធ្វើសំយ៉ាំងប្រាំដងក្នុងមួយថ្ងៃ ឆ្ពោះទៅរកទិសនៃទីក្រុងម៉ាកាស ដែលត្រូវបានហៅថា គីប្លា (Qibla) ។ ការថ្វាយបង្គំត្រូវធ្វើនៅពេលព្រឹកព្រលឹម ពេលថ្ងៃត្រង់ ពេលរសៀល មុនពេលថ្ងៃលិច និងពេលយប់ ។ ប៉ុន្តែក្រុម អ៊ីមាំសាន់នៅប្រទេសកម្ពុជា គឺជាក្រុមសាសនាអ៊ីស្លាមដ៏កម្រមួយ ដែលអ្នកប្រណិប័តន៍ថ្វាយបង្គំមួយដងប៉ុណ្ណោះក្នុងមួយអាទិត្យគឺនៅពេលថ្ងៃត្រង់រាល់ថ្ងៃសុក្រ ។ មុនពេលធ្វើ សឡាត់ មូស្លីមត្រូវសម្អាតដៃ មុខ ក្បាល និងជើង ។ ការថ្វាយបង្គំគឺធ្វើឡើងដោយការឱនទៅមុខ ឈរ និងលត់ជង្គង់ ហើយសូត្រធម៌ ។ ឃ្លាដែលត្រូវបានសូត្រញឹកញាប់ជាងគេគឺ "ព្រះអល់ឡោះជាព្រះដ៏អស្ចារ្យជាងគេ" ។

ដើម្បីអប់រំក្មេងជំនាន់ក្រោយឲ្យធ្វើការថ្វាយបង្គំឲ្យបានត្រឹមត្រូវនោះ ការិយាល័យ មូហ្វទី (Mufti) នៅកម្ពុជាបានបោះពុម្ពសៀវភៅបីបួនលេខដែលណែនាំពីរបៀបថ្វាយបង្គំ ។ សព្វថ្ងៃយុវជនចាមជំនាន់ក្រោយដែលគោរពប្រណិប័តន៍សាសនាបានជាប់លាប់ ប្រើប្រាស់កម្មវិធីនៅក្នុងទូរស័ព្ទទំនើបដើម្បីរំឭកពេលវេលា និងរបៀបនៅក្នុងការថ្វាយបង្គំ ។ កម្មវិធីទូរស័ព្ទសម្បូរបែប បែបនេះ អាចធ្វើការគណនាដំណើរព្រះអាទិត្យ និងព្រះចន្ទដើម្បីកំណត់ពេលវេលាច្បាស់លាស់ក្នុងការថ្វាយបង្គំ និងកំណត់ទិសទៅកាន់ក្រុងម៉ាកាស ។

ជនជាតិចាមបានទទួលឥទ្ធិពលកាន់តែច្រើនឡើងពីការអនុវត្តសាសនាអ៊ីស្លាមនៅលើពិភពលោក ។ នៅប្រទេសកម្ពុជា អ្នកប្រាជ្ញ និងអ្នកនយោបាយចាម ហ្សាការីយ៉ា អាដាម (Zakarya Adam) មានតួនាទីជាអ្នកកំណត់ពេលវេលាក្នុងការថ្វាយបង្គំ និងធ្វើពិធីសាសនាផ្សេងៗ សម្រាប់ក្រុម តាប្លីហ្គី ចាម៉ាត់ (Tablighi Jamaat) ក្រុមមូស្លីមមួយក្រុមដែលផ្តល់អាទិភាពទៅលើការផ្សព្វផ្សាយសាសនា ដោយមូស្លីម សម្រាប់មូស្លីមដទៃទៀត និងចម្លងការប្រណិប័តន៍របស់ មហាម៉ាត់ មកអនុវត្ត ។ រីឯអ្នកប្រាជ្ញចាមឈ្មោះ ស្លេះ ស៊ូគ្រី (Sles Soukry) វិញ ប្រើប្រាស់វិធីសាស្ត្រទំនើបក្នុងការកំណត់ពេលវេលាសម្រាប់អ្នកដើរតាម សាឡាហ្វី (Salafi) ក្រុមមូស្លីមមួយក្រុមទៀតផ្តោតលើការបង្រៀនសាសនាអ៊ីស្លាមតាមបែបទំនើបស្របទៅតាមការអប់រំតាមបែបវិទ្យាសាស្ត្រ ហើយក្រុមនេះមិនយល់ស្របជាមួយក្រុមមូស្លីមដើរផ្សព្វផ្សាយសាសនាទេ ។ ការខ្វែងគំនិតនៃក្រុមទាំងពីរនេះ នាំឲ្យការកំណត់ពេលវេលាសំយ៉ាំងសម្រាប់ក្រុមទាំងពីរមានភាពខុសគ្នា ។

មុនពេលសំយ៉ាំង មនុស្សម្នាក់ មូស្ស៊ីន (muezzin) ប្រកាសទៅដល់អ្នកសំយ៉ាំង ទាំងអស់ពីលើ ស៊ឺន (minaret) ។ នៅប្រទេសកម្ពុជា ការប្រកាសនេះធ្វើឡើងជាភាសាអារ៉ាប់ និងភាសាម៉ាឡេ ។ ស៊ឺន មាននៅតាមសហគមន៍ចាមជាច្រើននៅក្នុងប្រទេសកម្ពុជា ។ ស៊ឺន ដែលចាស់ជាងគេស្ថិតនៅភូមិស្វាយឃ្លាំង ខេត្តកំពង់ចាម ។ សំឡេងប្រកាសឲ្យទៅសំយ៉ាំង ឮសូរវែងអន្លាយ ដែលពេលខ្លះសំឡេងនេះធ្វើឲ្យរំខានដល់ខ្មែរដែលរស់នៅភូមិក្បែរខាង ។ ជនជាតិខ្មែរខ្លះនិយាយថា ចាម កំពុងតែ "លូ" ជាពិសេស នៅពេលសំឡេងប្រកាសនេះធ្វើឡើងនៅពេលទៀបភ្លឺ ។ ពង្សាវតាខ្មែរបានកត់ត្រាថា ពេលវេលានេះជា "រដូវកាលពេលដែលម៉ាឡេលូ" ។ ហ្សាកាត់ (Zakat) ជាពាក្យអារ៉ាប់មានន័យថា ការធ្វើឲ្យបរិសុទ្ធ ។ ហ្សាកាត់ គឺជាវិធីជួយមនុស្ស តាមរយៈការឲ្យទាន ។ មូស្លីមធ្វើឲ្យខ្លួន និងទ្រព្យសម្បត្តិខ្លួនបរិសុទ្ធតាមរយៈការឲ្យទានមួយឆ្នាំម្តងទៅកាន់អ្នកក្រីក្រ វិហារអ៊ីស្លាម មជ្ឈមណ្ឌលអ៊ីស្លាម ឬក៏អង្គការមនុស្សធម៌ផ្សេងៗ ។ ជនជាតិចាមភាគច្រើនមិនសូវសម្បូរធនធានទេ ប៉ុន្តែអង្គការមនុស្សធម៌ផ្សេងៗបានបង្កើតឡើងដើម្បីបម្រើដល់គោលបំណងនេះ ។

ជនជាតិចាម ធ្វើពិធីបួសបង្អត់អាហារម្តងក្នុងមួយឆ្នាំ ក្នុងអំឡុងខែទី៩នៃប្រក្រតីទិនអ៊ីស្លាម ។ ខែទី៩នេះហៅថា រ៉ាម៉ាដាន (Ramadan) ។ ពេលបុណ្យ រ៉ាម៉ាដាន ជនជាតិចាម មិនទទួលទានអាហារ មិនផឹកទឹក ជក់បារី ឬ រួមដំណេក ពីអំឡុងពេលថ្ងៃរះរហូតដល់ថ្ងៃលិច ។ ការបួសបង្អត់អាហារ ត្រូវតែធ្វើការអនុវត្តយ៉ាងតឹងរ៉ឹងបំផុត ។ នៅមានករណីលើកលែងខ្លះចំពោះមនុស្សចាស់ ឈឺ រឬស ស្ត្រីមានគភ៌ និងបំបៅកូន ។ មូស្លីមជឿជាក់ថា មហាម៉ាត់ស្តាប់ឮដំបូងពីគម្ពីរគួរអាន ពីទេព ហ្គេប្រ៊ីល នៅខែរ៉ាម៉ាដាន ឆ្នាំ ៦១០ នៃគ.ស. ។ ហេតុនេះហើយ ទើបមូស្លីមកំណត់ធ្វើពិធីបួសបង្អត់អាហារនៅពេលនេះ ដើម្បីកំណត់ចំណាំពិធីសាសនា ហាត់ពត់ការគ្រប់គ្រងខ្លួនឯង និងបង្ហាញពីការគោរពប្រណិប័តន៍ទៅដល់ព្រះអល់ឡោះ ។ ចំពោះការអនុវត្តជាក់ស្តែងវិញ ការបួសគឺជាកិច្ចការមួយដ៏លំបាក ជាពិសេសចំពោះជនជាតិចាម ដែលរស់នៅក្រៅទីក្រុងភ្នំពេញ ហើយត្រូវធ្វើការនៅក្នុងរោងចក្រកាត់ដេរពី ៨ទៅ១០ ម៉ោងក្នុងមួយថ្ងៃ ។

គម្ពីរគួរអានណែនាំថា មូស្លីមត្រូវធ្វើ ហាជ្ជ (hajj) ពាក្យអារ៉ាប់ដែលមានន័យថា ការធ្វើធម្មយាត្រាទៅទីកន្លែងសក្តិសិទ្ធទៅទីក្រុងពិសិដ្ឋម៉ាកាស នៅប្រទេសអារ៉ាប់ យ៉ាងហោចណាស់ឲ្យបានម្តងក្នុងមួយជីវិត ។ មូស្លីមគួរតែធ្វើ ហាជ្ជ នេះ នៅពេលដែលខ្លួនមានសុខភាពល្អបរិបូរណ៍ និងធនធានគ្រប់គ្រាន់ អាចធ្វើដំណើរទៅឆ្ងាយបាន ។

ហាជ្ជ ប្រព្រឹត្តឡើងនៅថ្ងៃដំបូងៗនៃខែទី១២នៃប្រក្រតីទិនអ៊ីស្លាម ហៅថា ឌូ អាល់ហ៊ីចា (Dhu al-Hijja) ។ ហាជ្ជ ប្រារព្ធឡើងដើម្បីឧទ្ទិសដល់ការបូជារបស់ អាប្រាហាម (Abraham) ប្រពន្ធ ហាហ្គា (Hagar) និងកូនប្រុស អ៊ីស្មាអែល (Ishmael) ។ នៅទីក្រុងម៉ាកាស បុរស មូស្លីមស្លៀកសម្លៀកបំពាក់ពណ៌ស ហៅថា អ៊ីរ៉ាម (ihram) ដែលមានន័យថា សម្លៀកបំពាក់ដែលឧទ្ទិសទៅដល់ព្រះអល់ឡោះ និងភាពបរិសុទ្ធរបស់សាសនាអ៊ីស្លាម ។ ស្ត្រីមូស្លីមស្លៀករ៉ូបសវែង និងពាក់កន្សែងលើក្បាល ។ ដូចទៅនឹងព្រះសង្ឃព្រះពុទ្ធសាសនាដែរ ក្នុងពេលធ្វើ ហាជ្ជ មូស្លីមត្រូវបានហាមប្រាមមិនឲ្យសម្លាប់សត្វ និងមិនឲ្យរួមដំណេក ។

នៅទីក្រុងម៉ាកាស ជនជាតិចាមត្រូវអនុវត្តដូចតទៅ

◆ ដើរជុំវិញ កាបា (Kaaba) នៅកណ្តាលវិហារអ៊ីស្លាមធំ (the Great Mosque) ចំនួន៧ដង បញ្ច្រាសទិសនាឡិកា ។ អ្នកធ្វើធម្មយាត្រានេះអាចដើរតាមច្រករបៀងនៃវិហារធំ ហើយយកទឹកពីអណ្តូងដែលមានឈ្មោះថា ហ្សាមហ្សាម (Zamzam) កន្លែងដែល ហាហ្គា រកឃើញទឹកឲ្យកូនផឹក ។

◆ នៅថ្ងៃទី៩នៃ ឌូ អាល់ហ៊ីចា (Dhu al-Hijja) មូស្លីមត្រូវឈរនៅទំនាប អារ៉ាហ្វាត់ (Arafat) ដើម្បីស្តាប់ការសូត្រធម៌ដោយអ៊ីម៉ាំ ពីភ្នំអារ៉ាហ្វាត់ ដែលឈរនៅជាយទំនាប ។

◆ នៅថ្ងៃបន្ទាប់ អ្នកចូលរួមពិធីចោលដុំថ្មទៅលើសសរបី ហើយធ្វើការសម្លាប់សត្វចៀមឬពពែដើម្បីជាការបូជាទៅដល់ អាប្រាហាម ដែលសុខចិត្តលះបង់កូនប្រុស ។

◆ ចុងក្រោយ មូស្លីមដែលទៅ ហាជ្ជ ត្រូវដើរជុំវិញ កាបា ចំនួន៧ដង ។

**(នៅមានត)**

**អេង កុកថាយ**

# របាយការណ៍សន្និដ្ឋានស្តីពីបទពិសោធសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងសំណុំរឿង០០២/០១

## *សេចក្តីផ្តើម*

*ខុសពីរបាយការណ៍សង្កេតការណ៍ដែលបានបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រមុនៗ ដែលផ្តោតជាសំខាន់លើកិច្ចដំណើរការនីតិវិធីសវនាការ និងការវិភាគលើបញ្ហាច្បាប់នានា របាយការណ៍ដែលបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រលេខនេះ នឹងរៀបរាប់អំពីបទពិសោធផ្ទាល់ និងលទ្ធផលដែលសមាជិកក្រុមនៃគម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមសម្រេចបានក្នុងអំឡុងពេលជាង២ឆ្នាំកន្លងទៅ និងទស្សនៈយល់ឃើញជុំវិញកេរដំណែលនៃសាលាក្តីខ្មែរក្រហមដែលបន្សល់ទុកសម្រាប់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុក រួមជាមួយនឹងបញ្ហាប្រឈមនានាដែលសាលាក្តីខ្មែរក្រហមកំពុងជួបប្រទះ ។*

*នៅក្នុងរបាយការណ៍សន្និដ្ឋានស្តីពីបទពិសោធសង្កេតការណ៍លើដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងសំណុំរឿង ០០២ ដំណាក់កាលទី១នេះ ត្រូវបានបែងចែកចេញជា៥ផ្នែកសំខាន់ៗ ផ្នែកទី១ ពិពណ៌នាអំពីគោលបំណងនៃការបង្កើតគម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ផ្នែកទី២ រៀបរាប់អំពីសមិទ្ធផលដែលសមាជិកគម្រោងសម្រេចបាន ចាប់តាំងពីការចាប់ផ្តើមរហូតដល់ការចេញសាលក្រមលើសំណុំរឿង ០០២ ដំណាក់កាលទី១ ដោយអង្គជំនុំជម្រះសាលាដំបូង ។ ផ្នែកទី៣ នឹងលើកឡើងអំពីបញ្ហាប្រឈមមួយចំនួននៅក្នុងកិច្ចការសង្កេតការណ៍ និងតាមដាននីតិវិធីសវនាការនៅសាលាក្តីខ្មែរក្រហម ។ រីផ្នែកទី៤ ផ្តោតជាចម្បងលើការកត់សម្គាល់ទាក់ទងនឹងកេរដំណែល*



*ជនរងគ្រោះចូលរួមសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម សំណុំរឿងរឿង០០២ ដំណាក់ទី១ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

នៃសាលាក្តីខ្មែរក្រហម សម្រាប់ប្រព័ន្ធតុលាការក្នុងស្រុក នៅក្រោយពេលសាលាក្តីខ្មែរក្រហមបិទបញ្ចប់បេសកកម្មរបស់ខ្លួន ក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ និងប្រជាជនកម្ពុជា ។ នៅខណៈពេលដែលមានមតិជាច្រើនយល់ថា សាលាក្តីខ្មែរក្រហមនឹងក្លាយជាតុលាការគំរូសម្រាប់ប្រព័ន្ធតុលាការក្នុងស្រុក ក៏មានមតិមួយចំនួនយល់ថា តុលាការនេះពុំទាន់អាចក្លាយជាតុលាការគំរូនៅឡើយទេ ។ ផ្នែកទី៥ នឹងបរិយាយទាក់ទងនឹងបញ្ហាប្រឈមចម្បងៗដែលសាលាក្តីខ្មែរក្រហមកំពុងជួបប្រទះ ហើយបញ្ហាប្រឈមនេះអាចនឹងប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ។

### ១) គោលបំណង

ដោយមើលឃើញអំពីការចាប់ផ្តើម និងសារសំខាន់ដែលមានអត្ថន័យជាប្រវត្តិសាស្ត្រនៃសំណុំរឿង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងមួយដែលមានឈ្មោះថា គម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម ។ គម្រោងនេះ ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ២០១០ ក្នុងគោលបំណងសំខាន់ៗមួយចំនួនដូចជា៖

◆ សរសេររបាយការណ៍ជាក់លាក់ស្តីអំពីបញ្ហានានាដែលពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយធ្វើការវាយតម្លៃ និងពិចារណាពិស្តារដើម្បីផ្តល់ជាមតិចូលរួមក្នុងការធ្វើឲ្យមានកិច្ចដំណើរការសវនាការមួយប្រកបដោយអត្ថន័យ និងយុត្តិធម៌ ដោយគោរពតាមបទដ្ឋានជំនុំជម្រះកម្រិតអន្តរជាតិ ។

◆ ដើម្បីផ្តល់ជាព័ត៌មាន និងចំណេះដឹងជូនដល់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈឲ្យបានយល់ដឹងបន្ថែមអំពីកិច្ចដំណើរការនីតិវិធី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមរយៈព្រឹត្តិបត្រសង្កេតការណ៍ប្រចាំខែ បោះផ្សាយជាភាសាខ្មែរដោយប្រើប្រាស់នូវពាក្យពេចន៍សាមញ្ញ ងាយស្រួលយល់ និងងាយស្រួលក្នុងការអាន ។

◆ ដើម្បីផ្តល់ និងចែករំលែកនូវបទពិសោធដល់និស្សិតច្បាប់កម្ពុជាស្តីពីជំនាញសង្កេតការណ៍ និងវិភាគចំពោះកិច្ចដំណើរការនីតិវិធីសវនាការ ។

គោលបំណងសំខាន់ គឺធ្វើយ៉ាងណាដើម្បីចូលរួមចំណែកក្នុងការលើកស្ទួយឲ្យមាននីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា ដោយជំរុញឲ្យមានការយល់ដឹងអំពីសមត្ថកិច្ច ឯករាជភាព និងភាពមិនលម្អៀងនៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងប្រព័ន្ធយុត្តិធម៌ទៅដល់ប្រជាជនសាមញ្ញ និងជំរុញឲ្យមានវប្បធម៌សិក្សាស្រាវជ្រាវស៊ីជម្រៅផ្នែកច្បាប់ក្នុងស្រទាប់យុវជនដែលកំពុងសិក្សាជំនាញផ្នែកច្បាប់ ។

ដើម្បីសម្រេចគោលបំណងខាងលើសមាជិកនៃគម្រោងក្រុមសង្កេតការណ៍នេះបានអនុវត្តសកម្មភាពសំខាន់ៗដូចជា៖

១) ត្រូវចូលរួមតាមដាន និងសង្កេតការណ៍ដោយផ្ទាល់នៅគ្រប់សវនាការជំនុំជម្រះសេចក្តីក្នុងសំណុំរឿង០០២នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

២) បោះផ្សាយព្រឹត្តិបត្រសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមជាភាសាខ្មែរ ដោយប្រើប្រាស់របាយការណ៍ដែលទទួលបានពីការតាមដាន និងសង្កេតលើកិច្ចដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការ ។

៣) ធ្វើបទបង្ហាញទាក់ទងនឹងការវិវឌ្ឍថ្មីៗ និងបញ្ហាច្បាប់នានាដែលកើតឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅដល់សិស្ស និស្សិត នៅតាមបណ្តាសាកលវិទ្យាល័យនានានៅទូទាំងប្រទេស ជាពិសេសមហាវិទ្យាល័យច្បាប់ ។

៤) បង្កើតឲ្យមានព្រឹត្តិបត្រស្រាវជ្រាវស្តីពីច្បាប់ និងគោលនយោបាយកម្ពុជា (Cambodia Law and Policy Journal) ។

### ២) លទ្ធផលសម្រេចបាន

ចាប់តាំងពីសំណុំរឿង០០២នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចាប់ផ្តើមបើកកិច្ចដំណើរការនីតិវិធីសវនាការជាផ្លូវការនៅខែមិថុនា ឆ្នាំ២០១១ គម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម បានបោះផ្សាយព្រឹត្តិបត្រសង្កេតការណ៍ស្តីពីដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមបានចំនួន២៩លេខ ដោយមួយលេខៗមានចំនួន១.០០០ច្បាប់ ។ ជាសរុប ព្រឹត្តិបត្រចំនួន២៩.០០០ច្បាប់ ត្រូវបានបោះពុម្ពផ្សាយ និងចែកចាយទៅដល់ប្រជាជន សិស្ស និស្សិត អ្នកអនុវត្តច្បាប់ មន្ត្រីតុលាការ រួមទាំងស្ថាប័ន និងគ្រឹះស្ថានអប់រំនៅទូទាំងប្រទេស ។ បន្ថែមពីលើនេះ សមាជិកនៃគម្រោងនេះ បានចុះធ្វើបទបង្ហាញទាក់ទងនឹងការវិវឌ្ឍថ្មីៗ និងបញ្ហាច្បាប់នានាដែលកើតឡើងនៅអង្គជំនុំជម្រះវិសាមញ្ញ

ក្នុងតុលាការកម្ពុជាទៅដល់សាស្ត្រាចារ្យ សិស្ស និស្សិត ប្រមាណ ៨.០០០នាក់ នៅតាមបណ្តាសាកលវិទ្យាល័យចំនួនប្រមាណ ៤០នៅទូទាំងប្រទេស ។ ស្របពេលជាមួយគ្នានេះដែរ ព្រឹត្តិបត្រស្រាវជ្រាវស្តីពីច្បាប់ និងគោលនយោបាយកម្ពុជា ត្រូវបានបង្កើតឡើងជាផ្លូវការដើម្បីជំរុញឲ្យមានវប្បធម៌សិក្សាស្រាវជ្រាវស៊ីជម្រៅផ្នែកច្បាប់ក្នុងស្រទាប់យុវជនដែលកំពុងសិក្សាជំនាញផ្នែកច្បាប់ ។ មានអត្ថបទស្រាវជ្រាវ និងវិភាគជាច្រើនរបស់អ្នកជំនាញផ្នែកច្បាប់ និងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ត្រូវបានយកមកចងក្រង និងបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រស្រាវជ្រាវស្តីពីច្បាប់ និងគោលនយោបាយកម្ពុជានេះ ។ ព្រឹត្តិបត្រស្រាវជ្រាវស្តីពីច្បាប់ និងគោលនយោបាយកម្ពុជាចំនួនជាង១.០០០ក្បាល ត្រូវបានបោះពុម្ពផ្សាយ និងផ្តល់ជូនស្ថាប័នតុលាការ អ្នកស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងសាកលវិទ្យាល័យនានានៅក្នុងប្រទេសកម្ពុជា ។

នាពេលអនាគត ឯកសារទាំងអស់នេះនឹងក្លាយជាប្រភពធនធានយ៉ាងសំខាន់សម្រាប់កិច្ចការស្រាវជ្រាវ និងការសិក្សាក្រោយពេលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបិទបញ្ចប់កិច្ចការងាររបស់ខ្លួន ។

### ៣) បញ្ហាប្រឈមនៃកិច្ចការសង្កេតសវនាការ

នៅដើមឆ្នាំ២០១១ គម្រោងសង្កេតការណ៍ដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម មានសមាជិកចំនួន៤រូប បានចាប់ផ្តើមដំណើរការជាផ្លូវការ ហើយសមាជិកគម្រោងទាំងបួនរូបបានចូលរួមតាមដាន និងសង្កេតគ្រប់សវនាការទាំង២១២ថ្ងៃ នៃសំណុំរឿង ០០២ ដំណាក់កាលទី១ រួមទាំងសវនាការបឋម និងសវនាការប្រកាសសាលក្រម ។

នៅពេលចាប់ផ្តើម សមាជិកគម្រោងសង្កេតការណ៍ទាំង៤រូបដែលជានិស្សិតច្បាប់ទើបបញ្ចប់ការសិក្សា និងនៅពុំទាន់មានបទពិសោធក្នុងការតាមដានសវនាការជំនុំជម្រះបទឧក្រិដ្ឋដែលមានលក្ខណៈជាអន្តរជាតិ បានជួបប្រទះនូវផលលំបាកមួយចំនួន រាប់ចាប់តាំងពីកម្រិតនៃចំណេះដឹងពាក់ព័ន្ធនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ រហូតដល់វិធីសាស្ត្រក្នុងការសរសេររបាយការណ៍សង្កេតការណ៍ ។ នេះពុំទាន់រាប់បញ្ចូលឧបសគ្គទាក់ទងនឹងពេលវេលានៅក្នុងការសរសេររបាយការណ៍ឲ្យទាន់កាលកំណត់ទេ ។

ទោះបីជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ប៉ុន្តែ ការធ្វើដំណើរជាក់ស្តែងដើម្បីទៅចូលរួមតាមដាន និងសង្កេតសវនាការ ត្រូវចំណាយពេលជាង២ម៉ោង ដើម្បីធ្វើដំណើរទៅមក ។ ការចេញដំណើរដើម្បីទៅចូលរួមតាមដានសវនាការធ្វើឡើងនៅម៉ោង៧ព្រឹក និងត្រឡប់មកដល់ការិយាល័យនៅម៉ោង៥ ទៅ៦ល្ងាច ។ ជាធម្មតា សវនាការនៅសាលាក្តីខ្មែរក្រហម ប្រព្រឹត្តធ្វើនៅវេលាម៉ោង៩ព្រឹក រហូតដល់ម៉ោង៤រសៀល ចាប់ពីថ្ងៃចន្ទ រហូតដល់ថ្ងៃព្រហស្បតិ៍ និងមានពេលខ្លះសវនាការត្រូវបន្តធ្វើរហូតដល់ថ្ងៃសុក្រ ។ ក្នុងរយៈកាលដំបូង ការសង្កេតអំពីកិច្ចដំណើរការ នីតិវិធីសវនាការត្រូវកត់ត្រាដោយដៃ បន្ទាប់មកទើបសរសេរកំណត់ត្រាទាំងអស់នោះចូលក្នុងកុំព្យូទ័រ ដែលកិច្ចការទាំងអស់នេះត្រូវចំណាយពេលវេលាបន្ថែម ។ ក្នុងរយៈកាលបន្ទាប់ ទើបការកត់ត្រាអំពីកិច្ចដំណើរការនីតិវិធីអាចធ្វើឡើងតាមរយៈកុំព្យូទ័រ ប៉ុន្តែកុំព្យូទ័រពុំត្រូវបានអនុញ្ញាតឲ្យយកចូលក្នុងបន្ទប់សវនាការឡើយ ហេតុដូច្នេះការកត់ត្រាត្រូវធ្វើឡើងពីបន្ទប់សារព័ត៌មាននៅខាងក្រោមសាលសវនាការ ។ ការតាមដាននីតិវិធីសវនាការពីបន្ទប់សារព័ត៌មានធ្វើឡើងតាមរយៈប្រព័ន្ធសោតទស្សន៍ដែលផ្សាយផ្ទាល់ចេញពីបន្ទប់សវនាការ ។ ដោយសារសមាជិកក្រុមសង្កេតការណ៍មានចំនួន៤រូប ដូច្នេះសមាជិក២រូបត្រូវតាមដាន និងសង្កេតកិច្ចដំណើរការនីតិវិធីដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដើម្បីពិនិត្យមើលទិដ្ឋភាពជាក់ស្តែង និងប្រតិកម្មរបស់អ្នកចូលរួមចំពោះការជជែកដេញដោលរបស់ភាគី និងសមាជិកពីររូបទៀត ត្រូវកត់ត្រាកិច្ចដំណើរការនីតិវិធីតាមរយៈកុំព្យូទ័រពីបន្ទប់សារព័ត៌មាន ។ ការអនុវត្តបែបនេះត្រូវបានផ្លាស់ប្តូរនៅពេលក្រោយមក ដោយសារទំហំនៃការងារមានការកើនឡើង ដោយតម្រូវឲ្យមានតែសមាជិក២រូបប៉ុណ្ណោះត្រូវទៅតាមដាន និងសង្កេតនៅសាលាក្តីខ្មែរក្រហម ។ រីឯសមាជិក២រូបទៀត ត្រូវសរសេររបាយការណ៍ស្តីពីកិច្ចដំណើរការនីតិវិធីសវនាការដែលបានចូលរួមរួចហើយនៅការិយាល័យ ដើម្បីបោះផ្សាយជាព្រឹត្តិបត្រសង្កេតការណ៍ប្រចាំខែ ។

គួរកត់សម្គាល់ថា ភាសាដែលប្រើប្រាស់ជាផ្លូវការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានចំនួនបីភាសា គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។ នៅអំឡុងពេលនៃកិច្ចដំណើរការ

នីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះ ភាសាទាំងបីខាងលើត្រូវបានបកប្រែផ្ទាល់មាត់នៅក្នុងពេលតែមួយព្រមគ្នា ស្របពេលដែលភាគីនីមួយៗកំពុងធ្វើសេចក្តីថ្លែងការណ៍ ។ នៅក្នុងកាលៈទេសៈបែបនេះ ទោះបីតិច ឬច្រើន វាពិតជាបានបង្កនូវការលំបាកដល់បុគ្គលិកបកប្រែភាសាក្នុងការបកប្រែឲ្យបានគ្រប់ជ្រុងជ្រោយនូវអត្ថន័យនៃពាក្យសម្ដីដែលភាគីនីមួយៗបានលើកឡើង ។ ការណ៍នេះបានបង្កការលំបាកមួយចំនួនសម្រាប់អ្នកចូលរួមតាមដានសវនាការដើម្បីស្វែងយល់អំពីអំណះអំណាងរបស់ភាគី ជាពិសេស ប្រជាជនសាមញ្ញ ដែលពុំសូវយល់ដឹងអំពីកិច្ចដំណើរការនីតិវិធីសវនាការស្រាប់ ។

ការអានឯកសារអនុស្សរណៈ កាលវិភាគ ឯកសាររបស់គូភាគី និងសេចក្តីសម្រេចផ្សេងៗរបស់អង្គជំនុំជម្រះ គឺជាកិច្ចការសំខាន់ និងចាំបាច់ ដែលត្រូវធ្វើជាប្រចាំក្នុងនាមជាអ្នកសង្កេត និងតាមដានកិច្ចដំណើរការនីតិវិធី ដើម្បីដឹងអំពីការវិវឌ្ឍថ្មីៗ និងបញ្ហាដែលកើតមានក្នុងសំណុំរឿងក្រៅពីអ្វីដែលកើតមាន និងលើកឡើងនៅក្នុងអំឡុងពេលសវនាការ ។ មានឯកសារក្នុងសំណុំរឿង ០០២ រាប់ម៉ឺនទំព័រត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដើម្បីអាចឲ្យសាធារណជនបានដឹងអំពីដំណើរវិវឌ្ឍនៃសំណុំរឿង ។ សមាជិកនៃគម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមបានរំលែកពេលវេលាមួយផ្នែកពីការសរសេររបាយការណ៍ និងតាមដានសវនាការដើម្បីអានឯកសារសំខាន់ៗទាំងនោះ ។ ផ្តើមចេញពីការអានឯកសារតុលាការទាំងអស់នេះ សមាជិកក្រុមសង្កេតការណ៍បានសរសេរអត្ថបទវិភាគខ្លីៗលើប្រធានបទនានាស្តីអំពីបញ្ហានីតិវិធី និងសម្រេចនានារបស់អង្គជំនុំជម្រះលើសំណើសុំរបស់ភាគី ដោយប្រើប្រាស់វិធីសាស្ត្រពន្យល់តាមរបៀបជាលក្ខណៈសម្រាយ ដើម្បីចុះផ្សាយនៅក្នុងព្រឹត្តិបត្រសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម ទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងនៅក្នុងទំព័រកាសែត និងគេហទំព័រព័ត៌មានក្នុងស្រុកមួយចំនួនទៀត ។

### ៤) កំណត់សម្គាល់ជុំវិញកេរដំណែលនៃសាលាក្តីខ្មែរក្រហម

ចាប់តាំងពីការចាប់ផ្តើមនៃគម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងខែមេសា ឆ្នាំ២០១១ សមាជិកក្រុមនៃគម្រោងនេះ បានចូលរួមសង្កេតការណ៍នៅគ្រប់សវនាការនៃសំណុំរឿង០០២ដំណាក់កាលទី១ ទាំង២១២ថ្ងៃ រហូតដល់ថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមផ្តន្ទាទោសអតីតមេដឹកនាំខ្មែរក្រហម នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ។ បទពិសោធដែលទទួលបានពីការសង្កេត និងតាមដានសវនាការជំនុំជម្រះក្តីលើបទឧក្រិដ្ឋកម្មអន្តរជាតិ ដែលមានការចូលរួមពីសំណាក់អ្នកច្បាប់ជាតិ និងអន្តរជាតិ បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពខុសប្លែកគ្នាទាក់ទងនឹងការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីក្នុងសវនាការ និងយុទ្ធសាស្ត្ររបស់គូភាគីដែលប្រើប្រាស់ក្នុងការលើកឡើងនូវអំណះអំណាងនៅចំពោះមុខតុលាការ ដែលកម្រឃើញមានអនុវត្តនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជា ។ សាលាក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមជាតុលាការចម្រុះ ដែលមានសមាសភាពមន្ត្រីអ្នកអនុវត្តច្បាប់មកពីប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ផ្សេងគ្នា ពោលគឺប្រព័ន្ធច្បាប់ស៊ីវិល (Civil Law System) ដែលផ្តោតលើមូលដ្ឋានច្បាប់របស់ប្រទេសបារាំង និងប្រព័ន្ធច្បាប់ខំមិន (Common Law System) ដែលផ្អែកលើការអនុវត្តតាមបែបបទនៃប្រទេសអង់គ្លេស ។ ទោះបីជាយ៉ាងណាក្តី ការអនុវត្តនីតិវិធីជាក់ស្តែងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ក្នុងស្រុករបស់កម្ពុជាដែលទទួលរងឥទ្ធិពលពីប្រព័ន្ធច្បាប់ស៊ីវិលរបស់បារាំង ។ មន្ត្រីច្បាប់ និងភាគីនៃរឿងក្តី ដែលមកពីប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ខំមិន (Common Law System) ធ្លាប់បានលើកឡើងអំពីបញ្ហាលំបាក និងភាពស្មុគស្មាញក្នុងការអនុវត្តប្រព័ន្ធច្បាប់ផ្សេងគ្នាក្នុងអំឡុងពេលនៃការជជែកដេញដោលក្នុងសវនាការ ។

អ្នកជំនាញ អ្នកច្បាប់ អ្នកឃ្លាំមើលដំណើរការសវនាការទាំងជាតិ និងអន្តរជាតិជាច្រើនរូប បានបង្ហាញពីមតិយោបល់ជុំវិញកេរដំណែលនៃសាលាក្តីខ្មែរក្រហម ដោយខ្លះយល់ឃើញថាសាលាក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនឹងក្លាយទៅជាតុលាការគំរូមួយសម្រាប់តុលាការជាតិកម្ពុជា និងខ្លះទៀតយល់ថាតុលាការចម្រុះមួយនេះពុំទាន់អាចធ្វើជាតុលាការគំរូសម្រាប់ប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជាបាននៅឡើយទេ ។

យោងតាមបទពិសោធផ្ទាល់នៃការសង្កេតជាក់ស្តែងរបស់ក្រុមសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម ទោះបីជាសាលាក្តីខ្មែរក្រហមពុំបានជះឥទ្ធិពលគ្របដណ្តប់លើការផ្លាស់ប្តូរទម្លាប់អនុវត្តច្បាប់ទាំងស្រុងនៅក្នុងប្រព័ន្ធច្បាប់របស់កម្ពុជាក៏ដោយ ប៉ុន្តែវាពិតជាបានផ្តល់នូវផលវិជ្ជមានដល់បុគ្គលិកខាងភាគីជាតិ ដោយពុំអាចប្រកែកបាន ។ សាលាក្តីខ្មែរក្រហមបានផ្តល់នូវបទពិសោធ និងគំរូនៃការអនុវត្តដល់មន្ត្រីអនុវត្តច្បាប់ និងបុគ្គលិកបម្រើការសម្រាប់ភាគីជាតិ ទាំងផ្នែកបច្ចេកទេស និងផ្នែកនីតិវិធី ហើយប្រភពធនធានទាំងនេះនឹងក្លាយជាទុនយ៉ាងសំខាន់សម្រាប់ប្រើប្រាស់នៅក្នុងប្រព័ន្ធតុលាការជាតិ ទោះបីជាតុលាការនេះធ្លាប់ទទួលរងការរិះគន់អំពីបញ្ហាពុករលួយ នៅក្នុងការគ្រប់គ្រងនាពេលកន្លងទៅយ៉ាងណាក្តី ។ ចំណុចខាងក្រោមនឹងពិភាក្សាអំពីតួនាទីរបស់សាលាក្តីខ្មែរក្រហមក្នុងឋានៈជាតុលាការគំរូសម្រាប់តុលាការជាតិ ។

### ៤.១) សាលាក្តីខ្មែរក្រហមនឹងក្លាយជាតុលាការគំរូ?

នៅស្របពេលដែលប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្នត្រូវបានសាធារណជនទូទៅមើលឃើញថា នៅមានសភាពអន់ខ្សោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានរំពឹងថានឹងអាចក្លាយទៅជាតុលាការគំរូមួយសម្រាប់តុលាការក្នុងស្រុក ក្នុងការចូលរួមចំណែកធ្វើឲ្យមានការផ្លាស់ប្តូរមួយក្នុងរយៈពេលវែងទាក់ទងនឹងការលើកកម្ពស់សមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ និងទទួលបាននូវចំណេះដឹង និងជំនាញបន្ថែមពីសំណាក់សហគមន៍អន្តរជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ ធ្លាប់បានថ្លែងនៅអំឡុងពេលនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយព្យាករណ៍ទុកជាមុនថា សាលាក្តីខ្មែរក្រហមនឹងបន្សល់ទុកនូវកេរដំណែលដ៏មានតម្លៃមួយសម្រាប់ប្រទេសកម្ពុជា ហើយជំនាញ និងចំណេះដឹងដែលកើតចេញពីសាលាក្តីនេះនឹងត្រូវផ្ទេរទៅបុគ្គលិកជាតិ និងអ្នកពាក់ព័ន្ធ៖

> យើងមានក្តីសង្ឃឹមថា ការបង្កើតឡើងនូវដំណើរការច្បាស់លាស់មួយដែលគោរពតាមបទដ្ឋានអន្តរជាតិ និងជះឥទ្ធិពលផ្នែកអប់រំទៅលើស្ថាប័នដែលកំពុងដំណើរការផ្លូវការបច្ចុប្បន្ន និងបណ្តុះស្មារតីក្នុងចំណោមប្រជាជនទូទៅឲ្យយល់ដឹងពីការពិតពាក់ព័ន្ធនឹងអតីតកាលដែលពោរពេញដោយភាពវិនាសអន្តរាយរបស់កម្ពុជា និងការទាមទារបន្ថែមទៀតឲ្យមានប្រព័ន្ធតុលាការមួយ ដែលនឹងបំពេញមុខនាទីត្រឹមត្រូវ ។

អង្គជំនុំជម្រះសាលាដំបូង ក៏ធ្លាប់បានទទួលស្គាល់អំពីសារសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះចំណុចនេះ ដោយបានកត់សម្គាល់ថា “ក្នុងនាមជាតុលាការគំរូ...អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដើរតួនាទីក្នុងការជំរុញ និងសង្កត់ធ្ងន់លើសារសំខាន់នៃការការពារឯករាជភាព និងសុចរិតភាពនៃប្រព័ន្ធតុលាការ ។ បន្ថែមពីលើនេះ មន្ត្រីជាន់ខ្ពស់នៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ជាច្រើនលើកច្រើនសាថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការគំរូ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញពីគោលបំណងរបស់ខ្លួនក្នុងការប្រើប្រាស់លទ្ធភាព ដើម្បីបង្កើតការយល់ដឹងរបស់តុលាការក្នុងស្រុកពាក់ព័ន្ធនឹងបទដ្ឋានអន្តរជាតិ និងការប្រព្រឹត្តទៅនៃការជំនុំជម្រះក្តីដោយយោងតាមគោលការណ៍យុត្តិធម៌អន្តរជាតិ ។

ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃសាលាក្តីខ្មែរក្រហម លោក ក្រាញ់ តូនី ធ្លាប់បានបញ្ជាក់ថា បុគ្គលិកជាតិដែលកំពុងធ្វើការនៅសាលាក្តីខ្មែរក្រហមនឹងក្លាយទៅជាធនធានដ៏មានតម្លៃសម្រាប់ប្រព័ន្ធច្បាប់កម្ពុជា នៅពេលដែលអ្នកទាំងនោះត្រឡប់ទៅបម្រើការងារនៅក្នុងស្ថាប័នក្នុងស្រុករបស់ខ្លួនវិញ ។ ចំណែកឯ លោក ចៅក្រម យូ ប៊ុនឡេង ដែលមានតួនាទីជាសហចៅក្រមស៊ើបអង្កេតជាតិនៃសាលាក្តីខ្មែរក្រហម និងមានតួនាទីជាប្រធានតុលាការសាលាឧទ្ធរណ៍នៃតុលាការជាតិកម្ពុជា ធ្លាប់បានលើកឡើងទាក់ទងនឹងបន្ទប់សម្រាប់សាក្សី និងប្រព័ន្ធគ្រប់គ្រងសំណុំរឿងតាមរយៈកុំព្យូទ័រ នៅសាលាក្តីខ្មែរក្រហម ដែលរៀបចំឡើងដើម្បីជាការការពារដល់សិទ្ធិរបស់ជនរងគ្រោះ សាក្សី និង ជនជាប់ចោទ និងមន្ត្រីតុលាការដែលទទួលបន្ទុកគ្រប់គ្រងកិច្ចការផ្នែករដ្ឋបាល រួមជាមួយនឹងការបោះពុម្ពផ្សាយសេចក្តីសម្រេចរបស់តុលាការតាមរយៈប្រព័ន្ធអ៊ីនធឺណែត ។

អ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហមមួយរូបបានកត់សម្គាល់ថា យុទ្ធវិធីការពារក្តីរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលព្យាយាម

រិះគន់រដ្ឋាភិបាល គឺជាយុទ្ធវិធីដែលពុំធ្លាប់មានពីមុនមកនៅក្នុងប្រទេសកម្ពុជា ។ អ្នកឃ្លាំមើលរូបនោះបាននិយាយថា ប្រសិនបើយុទ្ធវិធីការពារក្តីបែបដូច្នេះ កើតមាននៅក្នុងតុលាការជាតិវិញ មេធាវីការពារក្តីរូបនោះនឹងត្រូវដកហូតសិទ្ធិធ្វើជាមេធាវីភ្លាម ។ កិច្ចដំណើរការនីតិវិធីនៅសាលាក្តីខ្មែរក្រហមបានបង្រៀនអំពីវិជ្ជាជីវៈក្នុងការអនុវត្តច្បាប់ និងផ្តល់នូវគំរូក្នុងការរៀបចំឥរិយាបថនៅក្នុងសវនាការថាតើចៅក្រមគួរមានអាកប្បកិរិយាបែបណា ។ ប្រធានអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហម លោកចៅក្រម និល ណុន ត្រូវបានមើលឃើញថា បានអនុវត្តយ៉ាងល្អប្រសើរនៅក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធីសវនាការ ទាំងការប្រើប្រាស់សូរស័ព្ទ និងឥរិយាបថ ។ ប៉ុន្តែមានពេលខ្លះ លោកចៅក្រមបានប្រើប្រាស់សម្តីខ្លាំងៗ និងបង្ហាញអំពីអាកប្បកិរិយាខឹងសម្បារចំពោះមេធាវីការពារក្តី ឬភាគីផ្សេងទៀត នៅពេលមានការជំទាស់ខ្លាំងៗពីសំណាក់ភាគីដែលមានវត្តមានក្នុងបន្ទប់សវនាការ ។ ការប្រើប្រាស់ភាសា ឬពាក្យសម្តីពុំសមរម្យចំពោះជនជាប់ចោទ សាក្សី ឬជនរងគ្រោះពីសំណាក់ចៅក្រមជំនុំជម្រះ ត្រូវបានមើលឃើញថា បានកើតឡើងជាញឹកញាប់នៅអំឡុងពេលនៃការជំនុំជម្រះក្តីរបស់តុលាការក្នុងស្រុក ។ ដូច្នេះ គំរូក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធីសវនាការនៅសាលាក្តីខ្មែរក្រហមពីសំណាក់ចៅក្រមដែលមានវិជ្ជាជីវៈ នឹងអាចក្លាយជាបទពិសោធល្អសម្រាប់តុលាការក្នុងស្រុករៀនសូត្រ និងអនុវត្តតាមនៅពេលជំនុំជម្រះក្តី ទាំងការរៀបចំឥរិយាបថ និងការប្រើប្រាស់ពាក្យសម្តីក្នុងការសួរដេញដោលចំពោះភាគី ។

### ៤.២) គំរូអនុវត្តកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ

ពាក់ព័ន្ធនឹងការអនុវត្តនីតិវិធី សាលាក្តីខ្មែរក្រហមបានប្រើប្រាស់វិធានផ្ទៃក្នុងដែលបង្កើតឡើង ដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ដើម្បីដំណើរការនីតិវិធីសំណុំរឿងក្តី ។ ការអនុវត្តជាទូទៅ បានធ្វើឡើងដោយអនុលោមតាមនីតិវិធីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងមានលក្ខណៈល្អប្រសើរ ទោះបីជាមានការចោទប្រកាន់ពីសំណាក់ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទក្នុងសំណុំរឿង០០២ ទាក់ទងនឹងនីតិវិធីស៊ើបអង្កេតនៅអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេតដោយការិយាល័យសហចៅក្រមស៊ើបអង្កេតក៏ដោយ ។ ដូច្នេះ នាពេលអនាគត បទពិសោធដែលទទួលបានពីការអនុវត្តនីតិវិធីព្រហ្មទណ្ឌនៅសាលាក្តីខ្មែរក្រហម នឹងបង្កភាពងាយស្រួលសម្រាប់មន្ត្រីច្បាប់នៃតុលាការក្នុងស្រុកក្នុងការដំណើរការនីតិវិធីសំណុំរឿងក្តីប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ។ ម្យ៉ាងវិញទៀត ការប្រើប្រាស់ភាសាខ្មែរជាភាសាផ្លូវការនៅសាលាក្តីខ្មែរក្រហម បានផ្តល់នូវអត្ថប្រយោជន៍យ៉ាងធំធេងនៅក្នុងវិស័យអប់រំដែលទាក់ទងនឹងវិជ្ជាជីវៈផ្នែកច្បាប់ និងអ្នកអនុវត្តច្បាប់នៅកម្ពុជា ដោយសារវាបានជួយកាត់បន្ថយឧបសគ្គក្នុងការស្រាវជ្រាវឯកសារច្បាប់ជាភាសាបរទេស ។

កិច្ចដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហម បានផ្តោតជាសំខាន់ទៅលើគោលការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលក្នុងនោះមានដូចជា គោលការណ៍សន្មតថា គ្មានទោស ដរាបណាពុំត្រូវបានផ្តន្ទាទោស គោលការណ៍ទទួលបានសិទ្ធិស្មើភាពគ្នាក្នុងការតទល់ក្តី ការតម្រូវឲ្យមានតម្លាភាពនៅក្នុងកិច្ចដំណើរការនីតិវិធី និងជាពិសេស ការតម្រូវឲ្យមានការផ្តល់សំអាងហេតុផលគ្រប់គ្រាន់ និងច្បាស់លាស់នៅក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងការសម្រេចផ្តន្ទាទោស ។ ការអនុវត្តគោលការណ៍ទាំងអស់នេះនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក ត្រូវបានមើលឃើញថា មានកម្រិតនៅឡើយ ដូច្នេះ ការអនុវត្តគោលការណ៍ទាំងនេះនៅសាលាក្តីខ្មែរក្រហម អាចជាគំរូល្អប្រសើរសម្រាប់ប្រព័ន្ធតុលាការក្នុងស្រុក ជាពិសេស ការអនុវត្តពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។

បន្ថែមពីលើនេះ សេចក្តីសម្រេច និងការអនុវត្តសំខាន់ៗមួយចំនួនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងត្រូវបានយកមកប្រើប្រាស់ ដើម្បីលើកកម្ពស់សុចរិតភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុក និងពង្រឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។ សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌គឺជា "ធាតុសំខាន់" ក្នុងការធ្វើឲ្យមាននីតិរដ្ឋ ដែលរួមបញ្ចូលនូវគោលការណ៍ដែលមនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់ និងស្ថិតនៅក្រោមច្បាប់ និងគោរពតាមច្បាប់ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញឲ្យឃើញនូវសមត្ថភាពក្នុងការបកស្រាយ និងអនុវត្តបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះក្តី

ប្រកបដោយយុត្តិធម៌ ជាពិសេស ពាក់ព័ន្ធនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ធ្វើជាកេរដំណែលរបស់ខ្លួន ។

**៨.៣) យុត្តិសាស្ត្រពាក់ព័ន្ធនឹងសេចក្តីសម្រេចលើការសុំនៅក្រៅឃុំបណ្តោះអាសន្ន**

នៅក្នុងដំណាក់កាលមុនសវនាការ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពីបញ្ហាពាក់ព័ន្ធនឹងការសុំនៅក្រៅឃុំ និងលក្ខណៈវិនិច្ឆ័យសំខាន់ៗ ដើម្បីធ្វើយុត្តិកម្ម ចំពោះការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយយោងតាមសិទ្ធិក្នុងការទទួលបានសេរីភាពដូចមានចែងនៅក្នុងមាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាគោលការណ៍ណែនាំសម្រាប់តុលាការក្នុងស្រុក ។ ឧទាហរណ៍ នៅក្នុងសំណុំរឿង០០១ អង្គបុរេជំនុំជម្រះបានបញ្ជាក់លើបណ្តឹងឧទ្ធរណ៍ថា ការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើរូបជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច មានសារសំខាន់ពាក់ព័ន្ធនឹងមាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងវិធានផ្ទៃក្នុង ក្រោយពីធ្វើការពិចារណាយ៉ាងល្អិតល្អន់លើយុត្តិកម្មដែលបានប្រើប្រាស់ជាមូលដ្ឋាននៃការឃុំខ្លួន ។ ទោះបីជាច្បាប់ក្នុងស្រុកមានចែងអំពីការសុំនៅក្រៅឃុំដោយមានការធានាក៏ដោយ ក៏ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជានៅតែបន្តពឹងផ្អែកលើការដាក់ពន្ធនាគារ ដែលជាជំហរដាច់ណាត់សម្រាប់ជនជាប់ចោទដែលរង់ចាំការជំនុំជម្រះក្តី ហើយសំណើសុំនៅក្រៅឃុំដោយមានការធានាកម្រនឹងទទួលបានការអនុញ្ញាតណាស់ ។

សវនាការស្តីពីការស្នើសុំនៅក្រៅឃុំនៅសាលាក្តីខ្មែរក្រហម គឺជាឧទាហរណ៍មួយយ៉ាងសំខាន់សម្រាប់តុលាការក្នុងស្រុក នៅពេលដែលព្រះរាជអាជ្ញាចាំបាច់ត្រូវតែស្វែងរកហេតុផលរឹងមាំ ដើម្បីស្នើសុំឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ហើយមេធាវីការពារក្តីឲ្យជនត្រូវចោទត្រូវតែមានសមត្ថភាពក្នុងការបង្ហាញអំពីអំណះអំណាង និងការជជែកតតាំងដើម្បីស្វែងរកមូលដ្ឋានប្រឆាំងនឹងការសម្រេចឃុំឃាំងកូនក្តីរបស់ខ្លួន ។ រីឯ ចៅក្រមត្រូវតែពិនិត្យពិច័យលើអំណះអំណាងទាំងនោះឲ្យបានគ្រប់ជ្រុងជ្រោយ និងចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុសមរម្យ ដោយផ្អែកលើការសន្មតអំពីសេរីភាពថា ជាចំណុចចាប់ផ្តើម ។

សាលាក្តីខ្មែរក្រហមក៏បានបង្កើតយុត្តិសាស្ត្រដ៏មានសារប្រយោជន៍មួយចំនួន ស្តីពីលក្ខខណ្ឌដែលដាក់ឲ្យជនជាប់ចោទស្ថិតនៅក្រោមការឃុំខ្លួន ដោយរាប់បញ្ចូលទាំងការកំហិតរបស់តុលាការពាក់ព័ន្ធនឹងការទាក់ទងរវាងជនជាប់ចោទជាមួយភរិយា និងសិទ្ធិរបស់ជនជាប់ចោទដើម្បីចូលមើលឯកសារក្នុងសំណុំរឿងដោយអនុលោមតាមសិទ្ធិក្នុងការចូលរួមក្នុងការការពារខ្លួន និងដើម្បីធានាអំពីភាពស្មើគ្នាក្នុងការតតាំងក្តីជាមួយនឹងព្រះរាជអាជ្ញា ។ សេចក្តីសម្រេចដែលមានសារសំខាន់មួយទៀតនោះ គឺក្រមនីតិវិធីព្រហ្មទណ្ឌបានហាមប្រាមមេធាវីមិនឲ្យផ្តល់សំណៅ ឬផ្នែកណាមួយនៃឯកសារក្នុងសំណុំរឿងទៅកូនក្តីរបស់ខ្លួន ដែលបានបង្កឲ្យមានការព្រួយបារម្ភជាខ្លាំងទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងចូលរួមក្នុងការការពារខ្លួន ជាពិសេសជនជាប់ចោទ ទាំងឡាយដែលពុំទាន់មានអ្នកតំណាង ។

**៨.៤) ការចេញសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញ**

ការតម្រូវឲ្យចៅក្រមត្រូវតែចេញសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ជា "ការគោរពនូវសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌" ដែលជាយុត្តិសាស្ត្រមួយដ៏សំខាន់សម្រាប់តុលាការក្នុងស្រុក ពីព្រោះជារឿយៗការផ្តល់សំអាងហេតុរបស់តុលាការ នៅមានលក្ខណៈពុំទាន់ពេញលេញ ឬពេលខ្លះពុំមានតែម្តង ។ សេចក្តីសម្រេចជាច្រើនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញអំពីសមត្ថភាពរបស់តុលាការនេះ ក្នុងការធ្វើការប្រកបដោយឯករាជ្យ មិនលម្អៀង និងការវិភាគយ៉ាងល្អិតល្អន់អំពីគោលការណ៍ច្បាប់អន្តរជាតិដែលមានលក្ខណៈស្មុគស្មាញ ជាជាងការទទួលយកភ្លាមៗនូវការបកស្រាយចំពោះអត្ថន័យនៃបទបញ្ញត្តិទាំងនោះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃផ្សេងទៀត ។ ឧទាហរណ៍ នៅក្នុងការពិចារណាអំពីភាពចម្រូងចម្រាសនៃការពង្រីកទម្រង់នៃសហឧក្រិដ្ឋកម្មរួម ("សហឧក្រិដ្ឋកម្មរួមប្រភេទទី៣") ថាជាទម្រង់មួយនៃការទទួលខុសត្រូវ អង្គបុរេជំនុំជម្រះបានធ្វើការវិភាគស៊ីជម្រៅអំពីសមត្ថកិច្ចដែលធ្លាប់

បានយកមកប្រើប្រាស់ពីពេលមុនដើម្បីគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមប្រភេទទីពីរក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាជាងការទទួលយកភ្លាមៗនូវអំណះអំណាងរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី លើបញ្ហាដូចគ្នានេះ ។ ចំណុចនេះបានបង្ហាញពីភាពផ្ទុយគ្នានឹងសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលរកឃើញថា ទំនួលខុសត្រូវប្រភេទនេះអាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយធ្វើការសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមប្រភេទទីបី មិនបានឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ នោះឡើយ ។ អង្គជំនុំជម្រះសាលាដំបូងបានគាំទ្រចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។

### ៤.៥) ការគោរពសិទ្ធិទទួលបានការជំនុំជម្រះក្តី ប្រកបដោយយុត្តិធម៌

សេចក្តីសម្រេចរបស់សាលាក្តីខ្មែរក្រហម ដែលបានបកស្រាយយ៉ាងទូលំទូលាយអំពីសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ហើយដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយយោងតាមយុត្តិសាស្ត្រអន្តរជាតិ អាចជាគំរូសម្រាប់តុលាការក្នុងស្រុក ។ ឧទាហរណ៍ទាក់ទងនឹងការពិចារណាលើសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ត្រៀមដើម្បីការពារខ្លួន និងសិទ្ធិក្នុងការទំនាក់ទំនងជាមួយមេធាវីដែលខ្លួនបានជ្រើសរើស ដោយយោងតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អង្គបុរេជំនុំជម្រះបានបង្គាប់ថា ដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបដិសេធមិនឲ្យក្រុមមេធាវីការពារក្តីធ្វើការថតសំឡេងពីជំនួបរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួននៅមន្ទីរឃុំឃាំង បានរំលោភបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ។ យោងតាមយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សនៃអឺរ៉ុប អង្គបុរេជំនុំជម្រះបានបកស្រាយយ៉ាងក្បោះក្បាយលើមាត្រា១៤ ដោយសម្រេចថា វិធីដែលការិយាល័យសហចៅក្រមស៊ើបអង្កេតអនុវត្តសិទ្ធិនេះក្នុងន័យចង្អៀតគឺ «ពុំស្របនឹងកម្មវត្ថុ និងគោលបំណងនៃការធានាការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ទេ» ។ ស្រដៀងគ្នានេះដែរ សាលាក្តីខ្មែរក្រហមបានចេញសេចក្តីសម្រេចដ៏សំខាន់មួយទៀតស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុងសវនាការ និងនីត្យានុកូលក្នុងការបន្តឃុំឃាំងដោយគ្មានការជំនុំជម្រះក្តី ដែលអាចនឹងអនុវត្តដោយតុលាការក្នុងស្រុក ដើម្បីពង្រឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ ។

ការអនុវត្តជាច្រើនដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើប្រាស់អាចនឹងយកមកប្រើប្រាស់នៅតុលាការក្នុងស្រុក ដើម្បីបំពេញបន្ថែមនូវចំណុចដែលសវនាការក្នុងស្រុកអាក់ខានមិនបានអនុវត្តតាមបទដ្ឋានអន្តរជាតិដែលបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញ ។ ការអនុវត្តប្រភេទនេះរួមមាន សមត្ថភាពរបស់ភាគីក្នុងការជំទាស់ទៅនឹងសំណួរ ការអនុវត្តវិធានស្តីពីភស្តុតាង និងការបង្កើតយន្តការដែលអនុញ្ញាតឲ្យមានការវាយតម្លៃ និងការបដិសេធភស្តុតាង ។ ដោយសារតែក្រមនីតិវិធី ព្រហ្មទណ្ឌចែងត្រឹមតែថា តុលាការក្នុងស្រុកនឹងពិចារណាលើភស្តុតាងដែលដាក់ជូនអង្គជំនុំជម្រះដើម្បីធ្វើការវាយតម្លៃដោយផ្អែកលើការសម្រេចចិត្តរបស់ចៅក្រម ទើបការអនុវត្តបែបនេះនឹងអាចជាគំរូសំខាន់មួយនៅក្នុងការកំហិតការប្រើប្រាស់ភស្តុតាង ដើម្បីធានាការពារសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។

ទោះបីជា មតិភាគច្រើនទទួលស្គាល់ថា សាលាក្តីខ្មែរក្រហមនឹងក្លាយជាតុលាការគំរូសម្រាប់ប្រព័ន្ធ តុលាការក្នុងស្រុកក៏ដោយ ក៏អត្ថបទស្រាវជ្រាវមួយដែលមានចំណងជើងថា "បទពិសោធក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៖ មេរៀនពីសាលាក្តីខ្មែរក្រហម" *(Experiments in International Criminal Justice : Lessons From the Khmer Rouge Tribunal)* បានរកឃើញថា នៅមានភស្តុតាងតិចតួចនៅឡើយ ដែលបង្ហាញថាសាលាក្តីខ្មែរក្រហមអាចជះឥទ្ធិពលវិជ្ជមានដល់ប្រព័ន្ធតុលាការក្នុងស្រុកកម្ពុជា ។ អត្ថបទនោះបានដកស្រង់សម្តីរបស់លោក អ៊ូ វីរៈ អតីតនាយកប្រតិបត្តិមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលបានបង្ហាញពីការយល់ឃើញរបស់ខ្លួនថា ទោះបីជាសាលាក្តីខ្មែរក្រហមបានជួយអភិវឌ្ឍជំនាញ និងចំណេះដឹងដល់អ្នកអនុវត្តច្បាប់ក្នុងស្រុកក៏ដោយ ក៏ការផ្លាស់ប្តូរពិតប្រាកដនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាប្រហែលជាមិន

អាចទៅរួចឡើយ ប្រសិនបើគ្មានការផ្លាស់ប្តូរជាមូលដ្ឋានណាមួយពីសំណាក់រាជរដ្ឋាភិបាល ចំពោះការប្តេជ្ញាចិត្តក្នុងការអនុវត្តឲ្យបាននីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា ។

ស្រដៀងគ្នានេះដែរ លោកស្រី ក្លែរ ដាហ្វី (Claire Duffy) មកពីអង្គការ *Open Society Justice Initiative* បានលើកឡើងថា "ស្របពេលដែលសាលាក្តីខ្មែរក្រហមបានជួយពង្រឹងជំនាញរបស់ចៅក្រម និងមេធាវីក្នុងស្រុក ប្រព័ន្ធតុលាការក្នុងស្រុកនៅពុំទាន់មានការផ្លាស់ប្តូរនៅឡើយ" ។ ទោះបីជា នៅមានភាពទន់ខ្សោយ និងទទួលរងការរិះគន់ក៏ដោយក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅតែជាគំរូដ៏ល្អបំផុតសម្រាប់ការធ្វើកំណែទម្រង់តុលាការ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតុលាការនៅកម្ពុជាដ៏សំខាន់ ។

### ៥) បញ្ហាប្រឈមរបស់សាលាក្តីខ្មែរក្រហម

### ៥.១) បញ្ហាសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី

នៅពេលបច្ចុប្បន្ន ទោះបីជា អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហមបានចេញសាលក្រម ដាក់ទោសជនជាប់ចោទ នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ ហើយក៏ដោយ ក៏ជនជាប់ចោទទាំងពីររូបនៅតែត្រូវបានសន្មតថា ជាជនដែលគ្មានទោសដរាបណាសាលក្រម ឬសាលដីកាពុំទាន់ចូលស្ថាពរ ។ យោងតាមព្យាករណ៍របស់អង្គជំនុំជម្រះ ប្រសិនបើមានបណ្តឹងឧទ្ធរណ៍លើសាលក្រមនៃសំណុំរឿង០០២ ដំណាក់កាលទី១ អង្គជំនុំជម្រះតុលាការកំពូល អាចនឹងចំណាយពេលយ៉ាងហោចណាស់១៨ខែ ដើម្បីចេញសាលដីកា ។ ពោលគឺ គេត្រូវរង់ចាំរហូតដល់ត្រីមាសទី១ក្នុងឆ្នាំ២០១៦ទើបមានសាលដីកាស្ថាពរដើម្បីកំណត់ថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន ពិតជាមានពិរុទ្ធភាពដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាមែនឬយ៉ាងណា បញ្ហាសុខភាព ភាពទ្រុឌទ្រោមផ្នែកផ្លូវកាយ និងវ័យចាស់ជរារបស់ជនជាប់ចោទទាំងពីររូប បានបង្កើតជាក្តីព្រួយបារម្ភចំពោះភាគីពាក់ព័ន្ធអំពីការស្លាប់របស់ជនជាប់ចោទមុនពេលដែលមានសាលក្រម ឬសាលដីកាស្ថាពរ ។ ជាក់ស្តែងនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ជនជាប់ចោទ អៀង សារី ដែលជាជនជាប់ចោទមួយរូបក្នុងចំណោមជនជាប់ចោទ៤រូប ក្នុងសំណុំរឿង០០២ បានស្លាប់ដោយពុំទាន់ទទួលបានការជំនុំជម្រះចប់សព្វគ្រប់ ដែលធ្វើឲ្យបទចោទប្រកាន់ទាំងអស់ប្រឆាំងនឹង អៀង សារី ត្រូវរលត់ ។ រីឯ ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបំបែកចេញពីសំណុំរឿង០០២ និងដោះលែងឲ្យនៅក្រៅឃុំដោយស្ថិតក្រោមលក្ខខណ្ឌ បន្ទាប់ពីរកឃើញថាមានសម្បទាពុំគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការនីតិវិធីតុលាការ ។

ការស្លាប់របស់ជនជាប់ចោទ អៀង សារី និងបញ្ហាវង្វេងវង្វាន់ស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ជាសញ្ញាអាសន្នមួយក្រើនរំឭកដល់អង្គជំនុំជម្រះត្រូវពន្លឿនកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើជនជាប់ចោទដែលនៅសេសសល់ក្នុងសំណុំរឿង០០២ ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។

ទោះបីជាជនជាប់ចោទ នួន ជា និងជនជាប់ចោទ ខៀវ សំផន នៅមានសម្បទាគ្រប់គ្រាន់ ដើម្បីចូលរួមសវនាការ ប៉ុន្តែនៅក្នុងរបាយការណ៍ និងសក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្របានសង្កត់ធ្ងន់អំពីអាយុច្រើនរបស់ជនជាប់ចោទ និងភាពទ្រុឌទ្រោមផ្នែកផ្លូវកាយ ។ នៅក្នុងរបាយការណ៍នោះអ្នកជំនាញវេជ្ជសាស្ត្របានកត់សម្គាល់ថា ជនជាប់ចោទ នួន ជា ត្រូវទទួលការព្យាបាលចំពោះជំងឺគាំងបេះដូង ទោះបីជា ជំងឺសរសៃបេះដូងរបស់គាត់នាពេលបច្ចុប្បន្នមានលំនឹង និងត្រូវបានពិនិត្យត្រឹមត្រូវតាមផ្នែកវេជ្ជសាស្ត្រហើយក៏ដោយ ។

សាស្ត្រាចារ្យ ចន ខាំបែល (John CAMPBELL) អ្នកជំនាញជំងឺមនុស្សចាស់ដែលត្រូវបានអង្គជំនុំជម្រះតែងតាំង បានផ្តល់សក្ខីកម្មនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ ថា "យើងអាចស្មានពីស្ថានភាពរោគរបស់ជនជាប់ចោទបានតិចតួច ហើយយោងលើអាយុ និងស្ថានភាពជំងឺរ៉ាំរ៉ៃមួយចំនួនរបស់ជនជាប់ចោទ វានឹងមិនមែនជាការភ្ញាក់ផ្អើលឡើយ ប្រសិនបើជនជាប់ចោទពុំអាចរស់នៅតទៅទៀត ក្នុងរយៈពេល៦ខែ ខាងមុខ" ។ ជំងឺសរសៃបេះដូង ជំងឺសរសៃឈាមខួរក្បាល និងភាពទ្រុឌទ្រោមនៃផ្នែករាងកាយរបស់ជនជាប់ចោទ បានធ្វើឲ្យការប៉ាន់ស្មានអំពីស្ថានភាពជំងឺរបស់ជនជាប់ចោទនៅពេលអនាគតមានភាពលំបាក និងមានភាពពុំច្បាស់លាស់ ។

ដោយឡែក ជនជាប់ចោទ ខៀវ សំផន ដែលមានអាយុ

៨៣ឆ្នាំ ធ្លាប់ទទួលរងជំងឺដាច់សរសៃឈាមខួរក្បាលកាលពីចុងឆ្នាំ ២០០៧ ដែលតម្រូវឲ្យមានការព្យាបាលអស់រយៈពេលជាច្រើនខែដើម្បីឲ្យស្ថានភាពជំងឺរបស់គាត់ជាសះស្បើយ ។

ជនជាប់ចោទទាំងពីររូបបានចូលសម្រាកនៅក្នុងមន្ទីរពេទ្យអស់រយៈពេលខុសៗគ្នាក្នុងអំឡុងពេលសវនាការ ។ កាលពីខែមករា ឆ្នាំ២០១៣ ជនជាប់ចោទ នួន ជា ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដោយសារជំងឺរលាកទងសួតកម្រិតធ្ងន់ ។ បន្ទាប់មកនៅអំឡុងខែកុម្ភៈ ឆ្នាំ២០១៣ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យម្តងទៀត ដោយសារបញ្ហាសម្ពាធឈាមទាប ។ ចំណែកឯជនជាប់ចោទ ខៀវ សំផន ក៏ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដែរនៅចន្លោះថ្ងៃទី១៦ និង២៥ ខែមករា ឆ្នាំ២០១៣ ដោយសារជំងឺរលាកបំពង់កកម្រិតធ្ងន់ ។

អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបាត់លទ្ធភាពក្នុងការចេញសាលក្រមទាក់ទងនឹងជនជាប់ចោទ អៀង សារី និងជនជាប់ចោទ អៀង ធីរិទ្ធ រួចទៅហើយ ។ ប្រសិនបើកិច្ចដំណើរការនីតិវិធីជំនុំជម្រះ នៅតែត្រូវបានអូសបន្លាយដោយសារបញ្ហាសុខភាព និងវ័យចាស់ជរារបស់ជនជាប់ចោទ ហើយលទ្ធផលចុងក្រោយបែរជាពុំអាចសម្រេចបានសាលក្រម ឬសាលដីកាស្ថាពរមួយនោះនឹងនាំឲ្យមានការខកចិត្តពីសំណាក់ជនរងគ្រោះនៃរបបខ្មែរក្រហមដែលបានទន្ទឹងរង់ចាំយុត្តិធម៌អស់រយៈពេលជាងបីទសវត្សរ៍ ។ ទន្ទឹមនឹងការពន្លឿនកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី អង្គជំនុំជម្រះក៏ចាំបាច់ត្រូវថ្លឹងថ្លែងអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដោយត្រូវធានាថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះក្នុងការពន្លឿនកិច្ចដំណើរការជំនុំជម្រះ នឹងពុំប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការការពារខ្លួនដោយប្រសិទ្ធភាពនៅចំពោះមុខអង្គជំនុំជម្រះ ។

### ៥.២) បញ្ហាកង្វះថវិកា

ចាប់តាំងពីការចាប់ផ្តើមដំណើរការនីតិវិធីនៅក្នុងឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំណាយថវិកាអស់ប្រមាណ២០៩លានដុល្លារ គិតត្រឹមចុងឆ្នាំ២០១៣ ។ ការចំណាយនេះត្រូវបានមើលឃើញថា នៅតិចជាងការចំណាយរបស់តុលាការអន្តរជាតិផ្សេងៗទៀតដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ជាង២ពាន់លានដុល្លារសហរដ្ឋអាមេរិក តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ប្រហែល១ពាន់៨រយលានដុល្លារសហរដ្ឋអាមេរិក និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ប្រហែល៣០០លានដុល្លារសហរដ្ឋអាមេរិក ។ ទោះបីជាសាលាក្តីខ្មែរក្រហមចំណាយតិចជាងតុលាការអន្តរជាតិផ្សេងៗទៀតក៏ដោយ ប៉ុន្តែទឹកប្រាក់ដែលសាលាក្តីខ្មែរក្រហមបានចំណាយប្រមាណ២០៩លានដុល្លារនេះ ទើបតែសម្រេចបានសាលដីកាស្ថាពរក្នុងសំណុំរឿង០០១ ដែលមានជនជាប់ចោទ ឌុច តែមួយរូបប៉ុណ្ណោះ ។ រីឯសំណុំរឿង០០២ ទើបនឹងចេញសាលក្រមដោយអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤កន្លងទៅ ។ ដូច្នេះ បើប្រៀបធៀបនឹងការចំណាយសម្រាប់សំណុំរឿងដែលមានទំហំប្រហាក់ប្រហែលគ្នាជាមួយនឹងតុលាការអន្តរជាតិដទៃផ្សេងទៀត ឃើញថា សាលាក្តីខ្មែរក្រហមបានចំណាយថវិកាច្រើនជាង ។

សូមបញ្ជាក់ថា ការទទួលខុសត្រូវក្នុងការចាត់ចែងលើខ្ទង់ចំណាយនៅសាលាក្តីខ្មែរក្រហម គឺជាភារកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។ ថវិកាដែលចំណាយសម្រាប់ដំណើរការរបស់អង្គជំនុំជម្រះ គឺបានមកពីជំនួយវិភាគទានស្ម័គ្រចិត្តរបស់បណ្តាប្រទេសម្ចាស់ជំនួយ ដែលមានដូចជា រាជរដ្ឋាភិបាលកម្ពុជា ជប៉ុន អូស្ត្រាលី សហរដ្ឋអាមេរិក អាល្លឺម៉ង់ ចក្រភពអង់គ្លេស ន័រវេស សហភាពអឺរ៉ុប បារាំង និង ស៊ុយអែដ ។ល។ ផ្អែកតាមកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្តល់ និងរ៉ាប់រងរាល់ការចំណាយដោយខ្លួនឯងនូវអគារសម្រាប់សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ។ រាជរដ្ឋាភិបាល បានផ្តល់ជាសម្ភារប្រើប្រាស់ ជួយសម្រួល និងផ្តល់សេវាកម្មផ្សេងៗទៀត ដែលចាំបាច់សម្រាប់ប្រតិបត្តិការរបស់អង្គជំនុំជម្រះ ។ ប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់របស់ចៅក្រមកម្ពុជា ព្រះរាជអាជ្ញាកម្ពុជា និងបុគ្គលិកកម្ពុជាផ្សេងទៀត ក៏ជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជាដែរ ។ ចំណែកប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់របស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងបុគ្គលិកអន្តរជាតិផ្សេងទៀត ដែលជ្រើសរើសដោយអង្គការ

សហប្រជាជាតិ ជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

ការចំណាយទាំងអស់របស់សាលាក្តីខ្មែរក្រហម គឺពឹងផ្អែកលើថវិកាដែលផ្តល់ដោយប្រទេសម្ចាស់ជំនួយ ហេតុនេះវិបត្តិខ្វះខាតថវិកាបានចាប់ផ្តើមលេចចេញជារូបរាងនៅពេលប្រទេសដែលធ្លាប់ផ្តល់ជំនួយភាគច្រើនបានស្ទាក់ស្ទើរក្នុងការផ្តល់ជំនួយដល់តុលាការ ជាពិសេស ជំនួយសម្រាប់ភាគីជាតិ ។

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ ដោយសារមូលហេតុកង្វះខាតថវិកា អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីប្រកាសសារព័ត៌មានមួយ ដោយកាត់បន្ថយចំនួនថ្ងៃសវនាការពី៤ថ្ងៃ មកត្រឹម៣ថ្ងៃ ក្នុងមួយសប្តាហ៍ គឺបើកសវនាការពីថ្ងៃចន្ទដល់ថ្ងៃពុធប៉ុណ្ណោះសម្រាប់សប្តាហ៍នីមួយៗ ។ តាមធម្មតា អង្គជំនុំជម្រះបើកសវនាការពីថ្ងៃចន្ទដល់ថ្ងៃព្រហស្បតិ៍ក្នុងសប្តាហ៍នីមួយៗ ។

ចាប់ពីខែធ្នូ ឆ្នាំ២០១២ រហូតដល់ខែកញ្ញា ឆ្នាំ២០១៣ តុលាការបានប្រឈមមុខយ៉ាងធ្ងន់ធ្ងរនឹងវិបត្តិថវិកា ដោយពុំមានថវិកាសម្រាប់បើកប្រាក់បៀវត្សរ៍ជូនបុគ្គលិកជាតិ ដោយរាប់ចាប់តាំងពីអ្នកបើកបររហូតដល់ព្រះរាជអាជ្ញា និងចៅក្រម ។ សវនាការ ត្រូវបានផ្អាកបណ្តោះអាសន្ន ដោយសារ ការធ្វើពហិការមិនចូលបម្រើការងារពីបុគ្គលិកជាតិ ។ បុគ្គលិកខ្មែរជាងពាក់កណ្តាលមកពីផ្នែកគ្រប់គ្រងតុលាការ និងផ្នែកបកប្រែភាសា បានព្រមានថានឹងលាឈប់ពីការងារ ប្រសិនបើពុំមានដំណោះស្រាយ ។ នៅព្រឹកថ្ងៃចន្ទ ទី០៤ ខែមីនា ឆ្នាំ២០១៣ នៅពេលអង្គជំនុំជម្រះចូលមកដល់ក្នុងបន្ទប់សវនាការភ្លាម បុគ្គលិកជាតិខ្មែរផ្នែកបកប្រែភាសាបានប្រកាសជាសាធារណៈនៅចំពោះមុខចៅក្រមថា «យើងខ្ញុំជាបុគ្គលិកផ្នែកបកប្រែភាសានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមប្រកាសអនុវត្តការធ្វើពហិការមិនបំពេញការងារ ចាប់ពីពេលនេះតទៅ (ថ្ងៃចន្ទ ទី០៤ ខែមីនា ឆ្នាំ២០១៣) រហូតដល់យើងខ្ញុំទទួលបានប្រាក់ខែពេញលេញសម្រាប់ខែធ្នូ ឆ្នាំ២០១២ និងខែមករា ខែកុម្ភៈ ឆ្នាំ២០១៣ ទើបយើងខ្ញុំនឹងចាប់ផ្តើមចូលបំពេញការងារដូចប្រក្រតីឡើងវិញ» ។ ការប្រកាសធ្វើពហិការរបស់អង្គភាពបកប្រែភាសានេះ បានទទួលការគាំទ្រពីបុគ្គលិកជាតិនៅផ្នែកផ្សេងៗទៀតសរុបទាំងអស់ចំនួន២៨៧នាក់ ។

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣ បុគ្គលិកផ្នែកប្រតិចារឹកដែលទទួលបន្ទុកកត់ត្រាទាំងស្រុងអំពីកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះបានប្រកាសធ្វើពហិការមិនចូលបម្រើការងារដោយសារ តែពុំទាន់ទទួលបានប្រាក់បៀវត្សរ៍ ។

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ បុគ្គលិកជាតិចំនួន ១០០នាក់ បានដាក់ញត្តិសុំផ្អាកការងារបណ្តោះអាសន្ន ។ ដើម្បីដោះស្រាយនូវវិបត្តិថវិកានេះ លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ បានចេញមុខដោយផ្ទាល់ក្នុងការប្រកាសស្វែងរកជំនួយសម្រាប់សាលាក្តីខ្មែរក្រហម ។ ទោះបីជាមានការអំពាវនាវបែបនេះក្តី ពុំមានប្រទេសណាមួយសន្យាផ្តល់ជំនួយថវិកាជូនភាគីជាតិសម្រាប់បើកប្រាក់បៀវត្សរ៍ជូនបុគ្គលិកខ្លួនឡើយ ។

ដើម្បីដោះស្រាយវិបត្តិ ដែលបុគ្គលិកជាតិធ្វើពហិការពុំព្រមចូលបម្រើការងារនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ ខាងភាគីអង្គការសហប្រជាជាតិនៃសាលាក្តីខ្មែរក្រហម ដែលទទួលបានជំនួយអន្តរជាតិជាបន្តបន្ទាប់ បានប្រកាសផ្តល់ប្រាក់កម្ចីដល់ភាគីកម្ពុជាចំនួន១.១៥លាន ដុល្លារសម្រាប់បើកឲ្យបុគ្គលិកជាតិខ្មែរ ។ បន្ទាប់មក មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តកញ្ចប់ថវិកាសង្គ្រោះបន្ទាន់មួយដែលមានទឹកប្រាក់ប្រមាណ១៥.៥លាន ដុល្លារ សម្រាប់ភាគីអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាថវិកាសម្រាប់ឆ្នាំ២០១៤ ហើយថវិកានេះត្រូវបានប្រើប្រាស់ដោយភាគីជាតិក្នុងលក្ខខណ្ឌជាប្រាក់កម្ចី ។

ដោយសារវិបត្តិខ្វះខាតថវិកា សាលាក្តីខ្មែរក្រហមបានប្រកាសថា ខ្លួននឹងសម្រេចកាត់បន្ថយបុគ្គលិកទាំងជាតិ និងអន្តរជាតិពីចំនួន៤៣៦រូបមកត្រឹម៣១៧រូបនៅត្រឹមឆ្នាំ២០១៥ ។ សម្រាប់គម្រោងថវិកាប្រចាំឆ្នាំ២០១៤ និង ២០១៥ សាលាក្តីខ្មែរក្រហមនៅត្រូវការថវិកាចំនួន៦០.៥លាន ដុល្លារសហរដ្ឋអាមេរិក ដើម្បីបន្តកិច្ចការរបស់ខ្លួន ។ កិច្ចដំណើរការនីតិវិធីសវនាការនឹងត្រូវពន្យារពេលម្តងហើយម្តងទៀត ប្រសិនបើបញ្ហាថវិកាពុំត្រូវបានដោះស្រាយ ។ សាលាក្តីខ្មែរក្រហមពុំគួរអនុញ្ញាតឲ្យបញ្ហាថវិកាក្លាយជាឧបសគ្គរារាំងដល់កិច្ចខិតខំប្រឹងប្រែងក្នុងដំណើរការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហមទេ ។ ដូច្នេះ ទាំងភាគីរាជរដ្ឋាភិបាលកម្ពុជា និងភាគីអង្គការសហប្រជាជាតិ គប្បីខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីស្វែងរកថវិកាគាំទ្រ

ដល់ដំណើរការរបស់សាលាក្តីខ្មែរក្រហមក្នុងកិច្ចការជាប្រវត្តិសាស្ត្រសម្រាប់ប្រជាជនកម្ពុជា ។

**សន្និដ្ឋាន**

ទោះបីជា គម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមមានគោលបំណងសំខាន់ ធ្វើយ៉ាងណាដើម្បីចូលរួមចំណែកក្នុងការលើកស្ទួយឲ្យមាននីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា និងជំរុញឲ្យមានវប្បធម៌សិក្សាស្រាវជ្រាវស៊ីជម្រៅផ្នែកច្បាប់ក្នុងស្រទាប់យុវជនដែលកំពុងសិក្សាជំនាញច្បាប់ក៏ដោយ ក៏ដំណើរការកំណែទម្រង់វិស័យច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ជាកិច្ចការងារមួយដែលមានទំហំធំធេង ដែលទាមទារឲ្យមានការចូលរួមទាំងអស់គ្នាតាំងពីសំណាក់រាជរដ្ឋាភិបាល អ្នកអនុវត្តច្បាប់ មន្ត្រីក្នុងស្ថាប័នតុលាការ និងអង្គការមិនមែនរដ្ឋាភិបាល ។ល ។ គម្រោងសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងបន្តបេសកកម្មរបស់ខ្លួនក្នុងការផលិតប្រភពធនធានសម្រាប់កិច្ចការសិក្សាស្រាវជ្រាវ និងលើកស្ទួយការយល់ដឹងអំពីសមត្ថកិច្ច ឯករាជភាព និងភាពមិនលម្អៀងនៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងប្រព័ន្ធយុត្តិធម៌ទៅដល់ប្រជាពលរដ្ឋ សិស្ស និស្សិត និងមន្ត្រីអនុវត្តច្បាប់ រហូតដល់ពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបិទបញ្ចប់កិច្ចការងាររបស់ខ្លួន ។

តាមរយៈបទពិសោធផ្ទាល់ទាក់ទងនឹងកិច្ចការសង្កេតការណ៍អំពីកិច្ចដំណើរការនីតិវិធី និងការអនុវត្តការងារនៅក្នុងសាលាក្តីខ្មែរក្រហម សមាជិកគម្រោងសង្កេតការណ៍ជឿជាក់ថា សាលាក្តីខ្មែរក្រហមនឹងក្លាយជាគំរូដ៏ល្អបំផុតសម្រាប់ការធ្វើកំណែទម្រង់តុលាការ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតុលាការនៅក្នុងស្រុក ទោះបីជាតុលាការនេះធ្លាប់ទទួលរងការរិះគន់ទាក់ទងនឹងការប្រព្រឹត្តអំពើពុករលួយ និងការទទួលរងឥទ្ធិពលពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក៏ដោយ ។ ជាពិសេស ការធ្វើកំណែទម្រង់លើការអនុវត្តពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី ដែលផ្តោតលើការគោរពសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។

ថ្វីត្បិតមានការរំពឹងទុកខ្ពស់ទាក់ទងនឹងកេរដំណែល ប៉ុន្តែគេពុំត្រូវមើលរំលងឧបសគ្គចម្បងៗដែលកំពុងគំរាមកំហែងដល់កិច្ចដំណើរការនីតិវិធី និងដំណើរប្រព្រឹត្តទៅនៃសាលាក្តីមួយនេះដូចជា បញ្ហាវ័យចាស់ជរា និងសុខភាពកាន់តែទ្រុឌទ្រោមរបស់ជនជាប់ចោទ និងជនរងគ្រោះ និងបញ្ហាថវិកា ។ ចាប់តាំងពីការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីរហូតមកដល់ពេលបច្ចុប្បន្ននេះ ដែលមានរយៈពេលជាង៧ឆ្នាំ និងចំណាយថវិកាអស់ជាង២០០លានដុល្លារ សាលាក្តីខ្មែរក្រហមទើបតែសម្រេចផ្តន្ទាទោសបានជនជាប់ចោទ ឌុច តែមួយប៉ុណ្ណោះ ។

ទោះបីជាអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហមបានចេញសាលក្រមដាក់ទោសជនជាប់ចោទ នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ ហើយក៏ដោយ ជនជាប់ចោទទាំងពីររូបនៅតែត្រូវបានសន្មតថា ជាជនដែលគ្មានទោសដរាប ណាសាលក្រម ឬសាលដីកាពុំទាន់ចូលជាស្ថាពរ ។ គេត្រូវរង់ចាំរហូតដល់មានសាលដីកាស្ថាពរពីសំណាក់អង្គជំនុំជម្រះតុលាការកំពូលទើបអាចដឹងថា ជនជាប់ចោទទាំងពីររូបពិតជាមានពិរុទ្ធភាពមែនឬយ៉ាងណា ។ ហេតុដូច្នេះ ប្រសិនបើកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅតែបន្តអូសបន្លាយដោយសារបញ្ហាសុខភាព និងបញ្ហាកង្វះថវិកា ហើយលទ្ធផលចុងក្រោយបែរជាជនជាប់ចោទស្លាប់មុនពេលមានសាលដីកាស្ថាពរនោះ ជនរងគ្រោះនៃរបបខ្មែរក្រហមដែលបានទន្ទឹងរង់ចាំយុត្តិធម៌អស់រយៈពេលជាងបីទសវត្សរ៍នឹងត្រូវខកចិត្ត ។

ទាំងអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលចាំបាច់ត្រូវខិតខំប្រឹងប្រែងពន្លឿនកិច្ចដំណើរការនីតិវិធីជំនុំជម្រះដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ប៉ុន្តែជាមួយគ្នានេះ អង្គជំនុំជម្រះ ក៏ចាំបាច់ត្រូវពិចារណាអំពីសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទដែរ ។ ម្យ៉ាងវិញទៀត ទាំងភាគីរាជរដ្ឋាភិបាលកម្ពុជា និងភាគីអង្គការសហប្រជាជាតិ ដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងបង្កើតសាលាក្តីខ្មែរក្រហម ពុំគួរអនុញ្ញាតឲ្យបញ្ហាថវិកាក្លាយជាឧបសគ្គរាំងដល់បេសកកម្មជាប្រវត្តិសាស្ត្រក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហមទេ ។ ភាគីទាំងពីរត្រូវតែធានាថា ដំណើរការស្វែងរកយុត្តិធម៌នឹងត្រូវប្រព្រឹត្តទៅដោយចប់ចុងចប់ដើម ដូចដែលខ្លួនធ្លាប់បានសន្យាជាមួយនឹងជនរងគ្រោះ ។

**លីម ជ័យផ័ត្ត, ឌី សុជាតា និង ធួន ឡៃហ៊ុល**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthpechet@dccam.org ។

**◆ ទីកន្លែង : អគារ "ក" ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្តិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទ លេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។




















# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មខក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "Join Criminal Enterprise" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "Common Criminal Plan" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**

# ការឆ្លើយតបទៅអត្ថបទរបស់ រ៉េនឌុល ជីហ្វាលក្វ : ការបកស្រាយពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

***(តពីលេខមុន)***

*កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេក ប៊្លុង* (Siegfried Blunk) *បានលាលែងពីតំណែង ហើយបាននិយាយថា ទោះបីជាគាត់មិនដាក់ខ្លួនគាត់ស្ថិតនៅក្រោមឥទ្ធិពលរបស់រាជរដ្ឋាភិបាលក៏ដោយ គាត់មិនចង់ឲ្យការចោទប្រកាន់គាត់ទាំងប៉ុន្មាននាំឲ្យមានមន្ទិលសង្ស័យមកលើសុចរិតភាពនៃដំណើរការជំនុំជម្រះសំណុំរឿង០០៣ និង ០០៤ ។ សហចៅក្រមស៊ើបអង្កេត អន្តរជាតិបម្រុង ឡូរ៉ង់ កាសប៉ឺ អានសឺម៉េត* (Laurent Kasper-Anserment) *ឡើងកាន់ដំណែងជំនួសចៅក្រមបម្រុង ប៊្លុង ក្នុងខែវិច្ឆិកា ២០១១ ។ ប៉ុន្តែ ឧត្តមក្រុមប្រឹក្សាអង្គចៅក្រមបានបដិសេធមិនទទួលស្គាល់ចំពោះការតែងតាំងរបស់ចៅក្រមបម្រុងរូបនេះ ។ មួយខែបន្ទាប់ពីចូលកាន់តំណែងជំនួសចៅក្រម ប៊្លុង លោកបានបើកការស៊ើបអង្កេតឡើងវិញលើសំណុំរឿង ០០៣ ដោយឯកតោភាគី ។ ការបើកការស៊ើបអង្កេតបែបនេះ មិនត្រូវបានទទួលស្គាល់ដោយ ចៅក្រម យូ ប៊ុនឡេង ដែលជាសហចៅក្រមស៊ើបអង្កេតជាតិ ។ ចៅក្រម យូ ប៊ុនឡេង បានអះអាងថាចៅក្រម កាសប៉ឺ អានសឺម៉េត ពុំមានអំណាចស្របច្បាប់ក្នុងបន្តការស៊ើបអង្កេតលើសំណុំ រឿង០០៣ ។*

*ក្នុងខែមីនា ឆ្នាំ២០១១ ចៅក្រម កាសប៉ឺ អានសឺម៉េត បានលាលែងពីមុខតំណែង ពីព្រោះគាត់យល់ថា គាត់មិនអាចបំពេញកាតព្វកិច្ចរបស់គាត់បាន ដោយសារតែអ្វីដែលគាត់បានចាត់ទុកថាជាការរារាំង ពីសំណាក់ចៅក្រម យូ ប៊ុនឡេង ។ លោក ម៉ាក ហាមិន ដែលធ្លាប់ជាមេធាវីជាន់ខ្ពស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានធ្វើសច្ចាប្រណិធានចូលកាន់មុខតំណែងជាសហចៅក្រមស៊ើបអង្កេតថ្មីនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០១២ ។ ក្នុងខែកុម្ភៈ ឆ្នាំ២០១៣ ចៅក្រម យូ ប៊ុនឡេង និងចៅក្រម ហាមិន បានចេញសេចក្ដីប្រកាសព័ត៌មានរួមគ្នាមួយដែលបង្ហាញពីការខ្វែងគំនិតគ្នារវាងចៅក្រមទាំងពីរទាក់ទងនឹងការស៊ើបអង្កេតនៃសំណុំរឿង០០៣ថា តើគួរតែបន្ត ឬបញ្ចប់ ។ ចៅក្រម ហាមិន បានថ្លែងថា ការស៊ើបអង្កេតនៅតែបន្ត ហើយរាល់របាយការណ៍ប្រចាំខែរបស់តុលាការដែលបោះពុម្ពចាប់តាំងពីថ្ងៃដែលមានសេចក្ដីប្រកាសព័ត៌មានរួមគ្នានេះមក បានបោះពុម្ពផ្សាយពីការបន្តការស៊ើបអង្កេតលើសំណុំរឿង ០០៣ និង ០០៤ រួមទាំងបេសកកម្មចុះទៅស៊ើបអង្កេតមួយចំនួន និងកិច្ចសម្ភាសជាមួយសាក្សី ។*

*រ៉េនឌុល ហាក់បីដូចជាជឿជាក់ថាមានការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាល ហើយសហចៅក្រមស៊ើបអង្កេតពុំបានធ្វើកិច្ចការងាររបស់ខ្លួនឲ្យបានត្រឹមត្រូវ ។ ជាជាងធ្វើសេចក្ដីសន្និដ្ឋានភ្លាមៗថា រាជរដ្ឋាភិបាល ធ្លាប់ និងកំពុងបន្តជ្រៀតជ្រែក ។ រ៉េនឌុល គួរតែពិចារណាអំពីបញ្ហានេះដោយឈរលើមូលដ្ឋានអព្យាក្រឹត ។*

*ទីមួយ មានការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិថាតើជនសង្ស័យគួរតែចាត់ទុកជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា? សហព្រះរាជអាជ្ញាជាតិបានពន្យល់ថា គាត់បាន "ពិនិត្យមើល" ភស្តុតាងយ៉ាងហ្មត់ចត់ ដូច្នេះហើយគាត់នៅតែរក្សាការអះអាងដែលថាជនសង្ស័យក្នុងសំណុំរឿង ០០៣ មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬក៏ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ការខ្វែងគំនិតគ្នាបែបនេះគឺជារឿងមួយសមហេតុផល ទោះបីជាគ្មានការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលក៏ដោយ ពីព្រោះឯកសារទាំងឡាយរបស់តុលាការមិនបានកំណត់និយមន័យនៃពាក្យ "អ្នក*

ទទួលខុសត្រូវបំផុត» ហើយពាក្យនេះអាចមានកំណត់ន័យបានច្រើនយ៉ាង ។ លើសពីនេះទៅទៀត ដូចដែលបានពិភាក្សាខាងលើ អ្នកគាត់តែងឯកសារទាំងអស់នេះមានបំណងកំណត់វិសាលភាពនៃពាក្យនេះឲ្យមានលក្ខណៈចង្អៀតបំផុត ។

ទីពីរ ចាប់តាំងពីមានការបើកការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ សហចៅក្រមស៊ើបអង្កេតទាំងជាតិ និង អន្តរជាតិមិនបានចោទប្រកាន់ជនសង្ស័យមួយរូបណាឡើយរហូតដល់ការស៊ើបអង្កេតបិទបញ្ចប់ ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប៊្លុង ដែលមានបទពិសោធទាក់ទិននឹងច្បាប់អន្តរជាតិ និងធ្លាប់បម្រើការជាចៅក្រមនៅតុលាការពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត បន្ទាប់ពីបម្រើការងារជាចៅក្រមអស់រយៈពេល ២៦ឆ្នាំនៅប្រទេសអាល្លឺម៉ង់ បានពន្យល់ថា «សម្រាប់សំណុំរឿង ០០៣ និង ០០៤ យើងបានធ្វើការវិភាគយ៉ាងស៊ីជម្រៅទាក់ទិននឹងប្រភពដើម និងអត្ថន័យនៃពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» និងបានបង្កើតលក្ខណៈវិនិច្ឆ័យមួយចំនួន ដោយផ្អែកទៅលើច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមួយចំនួន ជាពិសេសតុលាការសម្រាប់ប្រទេសសេរ៉ាឡេអូន ពីព្រោះដែនសមត្ថកិច្ចរបស់តុលាការមួយនេះមានត្រឹមតែជនដែល «ទទួលខុសត្រូវខ្ពស់បំផុត» ដែរ ។

នៅពេលសហចៅក្រមស៊ើបអង្កេត ប៊្លុង លាលែងពីតំណែងក្រោយពីការស៊ើបអង្កេតលើសំណុំរឿង០០៣បានបិទបញ្ចប់អស់រយៈពេលកន្លះឆ្នាំហើយនោះ គាត់បាននិយាយថា ការលាលែងពីតំណែងរបស់គាត់មិនមែនបណ្តាលមកពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលលើការងាររបស់គាត់នោះទេ ប៉ុន្តែ ដោយសារតែមានទស្សនៈសាធារណៈដែលជឿថា រាជរដ្ឋាភិបាលបានលូកដៃមកក្នុងការងាររបស់គាត់នាំឲ្យគាត់សម្រេចចិត្តលាលែងពីតំណែង ។ គាត់បានពន្យល់ទៀតថា គាត់ថែមទាំងបានផ្តួចផ្តើមនីតិវិធីស្តីពីការប្រមាថ តុលាការប្រឆាំងនឹងរដ្ឋមន្ត្រីក្រសួងព័ត៌មាននៃប្រទេសកម្ពុជា ដែលបានពោលថា សំណុំរឿង០០៣ និង០០៤ មិនអាចដំណើរការបាន ។

នៅទីបំផុត សហចៅក្រមស៊ើបអង្កេត ហាមិន បន្តស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ យ៉ាងសកម្មជួយទៅនឹងការអះអាងរបស់ វ៉េនឌុល ដែលថា សំណុំរឿងទាំងពីរបានអូសបន្លាយ នៅក្នុងដំណាក់កាលស៊ើបអង្កេតដែលនាំឲ្យសំណុំរឿងទាំងពីរអាចបញ្ឈប់មុននឹងការបិទបញ្ចប់ការស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិមិនទាន់បានចោទប្រកាន់ជនសង្ស័យណាម្នាក់ឡើយដោយថ្លែងថា ពុំទាន់មាន «ភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នា» ដែលបង្ហាញថាជនសង្ស័យជាមេដឹកនាំជាន់ខ្ពស់ ឬស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទល្មើសស្ថិតនៅក្នុងដែនយុត្តាធិការរបស់សាលាក្តី ។

វ៉េនឌុល ព្យាយាមបញ្ជាក់ថា សេចក្តីសន្និដ្ឋានដែលបានកំណត់ទុកហើយជាមុនរបស់ខ្លួនមានភាពត្រឹមត្រូវ ដោយថ្លែងថា ការខកខានមិនបានជំនុំជម្រះសំណុំរឿង០០៣ និង០០៤ បណ្តាលមកពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាល ដោយពុំបានធ្វើការវិភាគអព្យាក្រឹតមួយទៅលើភាពចម្រូងចម្រាសនេះ ។ វ៉េនឌុល ខកខានក្នុងការទទួលស្គាល់ថា ការខ្វែងគំនិតគ្នារវាងសហចៅក្រមស៊ើបអង្កេតទៅលើការកំណត់ថា តើជនសង្ស័យគួរតែចាត់ទុកជាអ្នកទទួលខុសត្រូវខ្ពស់ អាចជាការខ្វែងគំនិតគ្នាមួយដែលស្របតាមច្បាប់ ឬក៏ភស្តុតាងសម្រាប់គាំទ្រដល់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាពិតជាខ្វះខាតមែន ។ អ្នកដែលមានវិជ្ជាជីវៈច្បាប់អាចនឹងបដិសេធចំពោះការបកស្រាយច្បាប់ និងការប៉ាន់ប្រមាណអង្គហេតុបែបនេះ ។

វ៉េនឌុល ពិនិត្យលើប្រវត្តិចរចាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយ៉ាងសង្ខេប ហើយរកឃើញថាពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» មិនត្រូវបានកំណត់ន័យដោយរាជរដ្ឋាភិបាល ឬអង្គការសហប្រជាជាតិនោះទេ ។ ការយល់ឃើញរបស់ វ៉េនឌុល ដែលថា ការពិនិត្យលើប្រវត្តិចរចាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំបានដោះស្រាយបញ្ហាទាក់ទិន និងអត្ថន័យមិនច្បាស់លាស់នៃពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» ពិតជាត្រឹមត្រូវ ប៉ុន្តែការពិនិត្យរបស់គាត់ពុំមានលក្ខណៈស៊ីជម្រៅ ។ ការពិនិត្យឲ្យបានស៊ីជម្រៅ និងហ្មត់ចត់នឹងបង្ហាញថាពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» មាននៅក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីធានាថា កាំង ហ្គេចអ៊ាវ ហៅ ឌុច ត្រូវបាននាំយកមកកាត់ទោស ។

ការពិនិត្យលើប្រវត្តិចរចាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្ហាញឲ្យឃើញថា ពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" មានគោលបំណងសំដៅទៅលើ ឌុច ។ មុនពេល ឌុច ត្រូវបានឃុំឃាំងនៅខែមេសា ឆ្នាំ១៩៩៩ រាល់ពេលប្រធានបទទាក់ទិននឹងយុត្តាធិការបុគ្គលរបស់តុលាការត្រូវបានលើកឡើងយកមកពិភាក្សា រាជរដ្ឋាភិបាលកម្ពុជាតែងតែសំដៅទៅការកាត់ទោសមេដឹកនាំជាន់ខ្ពស់ ។ ដូចគ្នាដែរ អង្គការសហប្រជាជាតិតែងតែសំដៅទៅមេដឹកនាំជាន់ខ្ពស់ រហូតដល់ពេលក្រុមជំនាញរបស់ខ្លួនបានចេញរបាយការណ៍មួយដែលស្នើសុំឲ្យមានការបង្កើតតុលាការអន្តរជាតិស្រដៀងនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ដែលគួរតែផ្ដោតសំខាន់ទៅលើបុគ្គលទាំងឡាយដែលមានការទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះយុត្តាធិការបុគ្គលរួមបញ្ចូលទាំងមេដឹកនាំជាន់ខ្ពស់ ដែលមានទំនួលខុសត្រូវចំពោះការរំលោភបំពាន រួមទាំងអ្នកនៅថ្នាក់ក្រោមដែលចូលរួមចំណែកដោយផ្ទាល់ក្នុងការប្រព្រឹត្តអំពើឃោរឃៅយ៉ាងព្រៃផ្សៃបំផុត ។ ក្រុមអ្នកជំនាញបានចង្អុលបង្ហាញថា ភស្តុតាងជាឯកសារដែលអាចរកបាន "ទំនងជាមានច្រើនសន្ធឹកសន្ធាប់សម្រាប់អំពើឃោរឃៅមួយចំនួន ជាពិសេសដំណើរការនៃកន្លែងសួរចម្លើយនៅទួលស្លែង (មន្ទីរស-២១ ដែលមាន ឌុច ជាប្រធាន) ។ សម្រាប់អំពើឃោរឃៅមួយចំនួនផ្សេងទៀត ភស្តុតាងជាឯកសារចង្អុលបង្ហាញបុគ្គលទទួលខុសត្រូវផ្ទាល់ ដែលអាចស្ថិតនៅក្នុងជួររាជរដ្ឋាភិបាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន គឺលែងមានទៀតហើយនាពេលបច្ចុប្បន្ន និងប្រហែលជាមិនអាចរកឃើញជារៀងរហូត..." ។ នេះបង្ហាញឲ្យឃើញថា សូម្បីតែក្រុមអ្នកជំនាញក៏ចង់ឲ្យមានការកាត់ក្ដី ឌុច នៅពេលដែលពាក្យនេះត្រូវបានស្នើឡើង ។

អនុសាសន៍របស់ក្រុមអ្នកជំនាញទាក់ទិននឹងការបង្កើតតុលាការ ដោយយកគំរូតាមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ឬតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា មិនត្រូវបានយកមកអនុវត្ត ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិក៏មិនបានថ្លែងថានឹងទទួលយកអនុសាសន៍របស់ក្រុមអ្នកជំនាញទាក់ទិននឹងបុគ្គលយុត្តាធិការ ។ បន្ទាប់ពីបេសកម្មរបស់ក្រុមជំនាញ មកកាន់ប្រទេសកម្ពុជា លោក នីនាន ស៊ីផេន (Ninin Stephen) ដែលជាប្រធានក្រុមបានថ្លែងនៅក្នុងសន្និសីទសារព័ត៌មានមួយថា គឺមាន "តែថ្នាក់ដឹកនាំកំពូល" ប៉ុណ្ណោះដែលត្រូវយកមកកាត់ទោស ។ នាខែមីនា ឆ្នាំ១៩៩៩ អគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជូនរបាយការណ៍របស់ក្រុមអ្នកជំនាញទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ រួមទាំងក្រុមប្រឹក្សាអង្គការសហប្រជាជាតិ ។ ទោះជាយ៉ាងណាក៏ដោយ យោងទៅតាមអ្នកប្រវត្តិវិទូ ស៊ីវិន ហេដឌ័រ "ផ្ទុយទៅនឹងរបាយការណ៍ដ៏ហ្មត់ចត់ (របស់ក្រុមអ្នកជំនាញនៃអង្គការសហប្រជាជាតិ) (អគ្គលេខាធិការអង្គការសហប្រជាជាតិ) បានអះអាងថា ពួកគេបានសន្និដ្ឋានថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុន្តែមិនបាននិយាយថាតើបុគ្គលប្រភេទណាផ្សេងទៀត ដែលអាចចាត់ទុកជាជនសង្ស័យ" ។

ក្រោយពីបេសកកម្មរបស់ក្រុមជំនាញមកកាន់ប្រទេសកម្ពុជា ឌុច បានចេញមុខជាសាធារណៈនៅខែមេសា ឆ្នាំ១៩៩៩ និងចាប់ផ្ដើមផ្ដល់បទសម្ភាស ។ គាត់ស្ថិតនៅក្រោមការឃុំខ្លួនរបស់តុលាការយោធានៅខែឧសភា ឆ្នាំ១៩៩៩ ។ យោងទៅតាម ស៊ីវិន ហេដឌ័រ នាយករដ្ឋមន្ត្រី ហ៊ុន សែន បង្ខំចិត្តឃុំឃាំង ឌុច ដើម្បីបំបិទមាត់គាត់ ។ នៅពេលនោះហើយពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានលើកឡើងក្នុងកិច្ចពិភាក្សាស្ដីពីយុត្តាធិការបុគ្គលរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីធានាថា ឌុច នឹងត្រូវនាំយកមកកាត់ទោសនៅក្នុងតុលាការណាមួយនាពេលអនាគត ទោះបីជាគាត់មិនត្រូវបានចាត់ទុកជាមេដឹកនាំជាន់ខ្ពស់ ។ យោងទៅតាមលោក ថមម៉ាស់ ហាម៉ាប៊ឺក អ្នកតំណាងពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅប្រទេសកម្ពុជាបានមានប្រសាសន៍ថា "ឌុច មិនបានកាន់តំណែងថ្នាក់ដឹកនាំនៅក្នុងបក្សនោះទេ ប៉ុន្តែនៅតែត្រូវបានចាត់ទុកថាមានការទទួលខុសត្រូវខ្ពស់ចំពោះការសម្លាប់រង្គាល ។ ប្រសិនបើគាត់មិនត្រូវបាននាំយកមកកាត់ទោសនោះទេ វាពិតជារឿងមួយដែលគួរឲ្យចោទសួរ" ។ នេះគឺជា ប្រភពព័ត៌មានមួយដែល រ៉េនឌល អាក់ខាន មិនបានយកមកពិចារណា ។ ***(នៅមានត)*** **ម៉ៃឃើល ការណាវ៉ាស**

# សុខ រ៉េត អតីតកម្មកររោងចក្រថ្មពិលតាខ្មៅ

ក្រោយថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ ប្រជាជនទាំងអស់ត្រូវខ្មែរក្រហមបន្ទំឲ្យចេញពីទីក្រុង ក៏ដូចជាទីប្រជុំជននានា នៅទូទាំងប្រទេស ។ ចំពោះទីក្រុងភ្នំពេញ គឺមានតែយោធា និងកម្មាភិបាលខ្មែរក្រហម ឬកម្មកររោងចក្រដែលមានទីតាំងនៅក្បែរៗទីក្រុងប៉ុណ្ណោះ ដែលអាចរស់នៅបាន ។ សុខ រ៉េត បានមករស់នៅ និងធ្វើការជាមួយប្ដី នៅទីក្រុងភ្នំពេញ ក្រោយថ្ងៃជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ ។ គាត់អាចមករស់នៅ និងធ្វើការបាន ដោយសារតែអង្គការអនុញ្ញាតឲ្យមកនៅជាមួយប្ដីគាត់ ។ ប្ដី រ៉េត ធ្វើការនៅកន្លែងឡានមន្ទីរខស្សរាហកម្មរដ្ឋ ចំណែក រ៉េត ត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅរោងចក្រថ្មពិល នៅតាខ្មៅ ។

នៅរោងចក្រថ្មពិលមានសមាជិកសរុប៦០០នាក់ ដែលមានឈ្មោះ សៀ ជាប្រធាន ។ កម្មករ គឺធ្វើការទៅតាមផ្នែករៀងៗខ្លួន ដូចជា ផ្នែកធ្វើបណ្ដូល ផ្នែកកាត់ម៉ាក ផ្នែករុំ និងផ្នែកកាត់កំប៉ុង ជាដើម ។ រ៉េត ធ្វើការនៅផ្នែកកាត់កំប៉ុង ។ ការងារជាកម្មកររោងចក្រថ្មពិល មិនមានអ្វីជាការលំបាកសម្រាប់ រ៉េត ក៏ដូចជាអ្នកដទៃនោះទេ ព្រោះអ្នកទាំងអស់គ្នាមានរបបអាហារគ្រប់គ្រាន់ គឺមួយថ្ងៃបីពេល ។ រាល់ព្រឹកមានបបរ ហើយថ្ងៃត្រង់ និងល្ងាច គឺមានបាយជាមួយនឹងម្ហូបផ្សេងៗ ។

រៀងរាល់ល្ងាច រ៉េត តែងតែត្រឡប់មកសម្រាកជុំគ្នាជាមួយនឹងប្ដីវិញ នៅឯផ្ទះដែលអង្គការចែកឲ្យ ។ រ៉េត រំឭកថា យើងរស់នៅក្នុងផ្ទះថ្មមួយ ចំពោះភ្លើងអគ្គិសនីមានប្រើប្រាស់គ្រប់គ្រាន់ ។ រ៉េត គេងបើកកង្ហាររទល់ៗភ្លឺ ។ ទីក្រុងភ្នំពេញពេលនោះ ស្ងាត់ណាស់ តែពេលខ្លះក៏មានសភាពអ៊ូអរដែរ នៅពេលដែលមានភ្ញៀវបរទេសមក ។ រ៉េត បានឃើញភ្ញៀវបរទេសទាំងនោះមានដូចជា គុយបា ចិន ជាដើម ។ ចំណែកផ្សារថ្មី គឺយើងអាចចូលបានតែពេលណាយើងត្រូវទៅបើករបបតែប៉ុណ្ណោះ ។ ពេលព្រឹកឡើង ខាងផ្នែកសេដ្ឋកិច្ចមកបើកម្ហូបនៅផ្សារថ្មី ដូចជា នំប៉័ង ត្រី សាច់ ជាដើម ។ ការងាររបស់ រ៉េត នៅរោងចក្រមិនជាលំបាកណាស់ណាទេ ហើយអំឡុងពេលដែលគាត់ធ្វើការនៅទីនោះ គាត់ឃើញគណៈប្រតិភូជាន់ខ្ពស់ខ្មែរក្រហមទៅមើលការងារនៅរោងចក្រដែរ មានដូចជា ចេង អន និង វន វ៉េត ក្រៅពីនោះ គាត់មិនដែលឃើញអ្នកផ្សេងទៀតទេ ។ កម្មករនៅរោងចក្រថ្មពិលនេះ មិនមែនសុទ្ធតែស្លៀកពាក់ខ្មៅទាំងអស់ទេ អ្នកខ្លះក៏ស្លៀកពាក់ពណ៌ខៀវដែរ ក្រោយពីសម្រាកការងារបើតាមអ្វីដែល រ៉េត ចងចាំ គឺអ្នកទាំងអស់គ្នាអាចស្លៀកសម្លៀកបំពាក់អ្វីក៏បាន អាវពណ៌ អាវផ្កាអ្វីក៏បាន នេះនិយាយតែអង្គភាពថ្មពិលរបស់គាត់ប៉ុណ្ណោះ ។ ចំពោះអង្គភាពផ្សេងៗគាត់មិនដឹងថាយ៉ាងណានោះទេ ។

ថ្មពិលជាច្រើនដែលបានផលិតរួច រ៉េត ឮថា ភាគច្រើនត្រូវនាំចេញទៅប្រទេសចិន ។ ក្រៅពីរោងចក្រថ្មពិលនេះ រ៉េត បានឲ្យដឹងថា មានរោងចក្រជាច្រើនទៀតដែលដំណើរការនៅពេលនោះ មានរោងចក្របារី រោងចក្រក្រណាត់ រោងចក្រក្រដាសជាដើម ។ នៅឆ្នាំ១៩៧៨ របបអាហារនៅរោងចក្ររបស់ រ៉េត បានផ្លាស់ប្ដូរឲ្យនំប៉័ងជំនួសបាយ ឬបបរវិញ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មានសម្លមួយមុខពីរមុខ សម្រាប់ហូបជាមួយនំប៉័ងដែរ ។

រ៉េត ធ្លាប់បានស្នើសុំអង្គការមកលេងផ្ទះបានពីរលើក គឺនៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៨ ការមកលេងនេះ រ៉េត ក៏មិនបានចាប់អារម្មណ៍អ្វីដែរពីសហករណ៍ គ្រាន់តែដឹងថា ប្រជាជនទាំងអស់ហូបរួម ឪពុកម្ដាយរបស់គាត់ ក៏ដូច្នេះដែរ ។ រ៉េត ពិតជាមិនដឹងថាមានការបង្អត់អាហារប្រជាជន ឬមានប្រជាជនជាច្រើនកំពុងជួបប្រទះនូវភាពអត់ឃ្លាននោះទេ ព្រោះគាត់ធ្វើការនៅភ្នំពេញ មិនបានដឹងពីហេតុការណ៍ទាំងនេះឡើយ ។ ពេលដែល រ៉េត ទៅដល់ភូមិអ្នកស្រុក មេភូមិជាដើម ដែលមានកូនបម្រើបដិវត្តន៍ តែងតែមកសួរនាំគាត់ពីសុខទុក្ខកូនរបស់គេ ព្រោះកូនទាំងនោះ ភាគច្រើនធ្វើការនៅភ្នំពេញ ។ រ៉េត រំឭកថា ប្ដីរបស់គាត់ ណាំ វុទ្ធី នេះ គឺធ្វើការនៅកន្លែងឡានមន្ទីរខស្សរាហកម្មរដ្ឋរហូតដល់ថ្ងៃរំដោះ ទីក្រុងភ្នំពេញឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៨១ វុទ្ធី ក៏បានស្លាប់ដោយជំងឺនៅ

ព្រំដែនថៃ ។

មកភ្នំពេញ រ៉េត ធ្លាប់ឮពីគុកទួលស្លែង គ្រាន់តែមិនដឹងថា គុកនោះនៅទីណា ហើយទំហំប៉ុណ្ណានោះទេ សូម្បីតែ ឌុច ក៏ រ៉េត មិនដែលស្គាល់ដែរ ហើយទើបតែស្គាល់ឈ្មោះ និងមុខនៅពេលដែលបានមើលឃើញក្នុងទូរទស្សន៍ប៉ុណ្ណោះ ។

ក្រោយរបបខ្មែរក្រហមដួលរលំ នៅខែមករា ឆ្នាំ១៩៧៩ រ៉េត និងប្តី ក៏ដូចជាខ្មែរក្រហមផ្សេងទៀត បានរត់ភៀសខ្លួនចេញពីក្រុងភ្នំពេញ ។ រ៉េត និងប្តី បានរត់ទៅដល់ត្រពាំងក្រឡឹង បន្ទាប់មកក៏បានឡើងឡានជាមួយខ្មែរក្រហមផ្សេងទៀតធ្វើដំណើរបន្តទៅដល់ថៃតាមខ្វងយៃ ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ មុនពេលចេញពីភ្នំពេញ រ៉េត ក៏បានឮការប្រកាសថា ឲ្យចេញពីភ្នំពេញបីថ្ងៃសិនដែរ មិនខុសពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ក៏មានការប្រកាសបែបនេះពីសំណាក់ខ្មែរក្រហមដែរ ។ កាលនៅជំរំក្នុងដីថៃនោះ គឺមានការជ្រើសរើសយកទៅរស់នៅប្រទេសទីបីច្រើន តែ រ៉េត សម្រេចចិត្តមិនចាកចេញ ព្រោះប្តីគាត់ធ្វើជាទាហានខ្មែរក្រហម ទៅច្បាំងបាត់ហើយ បើគាត់ទៅចោលប្តី ខ្លាចគេថា គាត់ផិតប្តី ហេតុនេះ គាត់ក៏សម្រេចចិត្តមិនចាកចេញ ដោយសុខចិត្តរង់ចាំប្តី ។ នៅឆ្នាំ១៩៨២ រ៉េត បានត្រឡប់មករស់នៅខាងអន្លង់វែងវិញ ។ រស់នៅទីនោះបានមួយឆ្នាំ គាត់ក៏ផ្លាស់មករស់នៅថ្មដាវិញ ។ នៅថ្មដា គឺមិនបាននៅក្នុងទឹកដីខ្មែរនៅឡើយទេ គឺ រ៉េត និងមនុស្សមួយចំនួនទៀតភាគច្រើនជាស្រីៗ រស់នៅក្នុងដីថៃសិន គឺនៅជំរំម៉ាក់មូក ដោយប្តីៗឡើងមកវាយជាមួយវៀតណាម ដោយកាលណោះ ប្រធានកងពល ឈ្មោះ តាស៊ុម ។ រ៉េត នៅជំរំរហូតដល់សមាហរណកម្មរួច ទើបរដ្ឋាភិបាលចាត់ឲ្យមករស់នៅភូមិចំការជ្រៃនេះ រហូតដល់បច្ចុប្បន្ន ។

រ៉េត រៀបការប្តីក្រោយនៅឆ្នាំ១៩៨២ ប្រាំខែបន្ទាប់ពីប្តីមុនរបស់គាត់ស្លាប់ដោយសារជំងឺ ។ ប្តីក្រោយរបស់ រ៉េត ឈ្មោះ ឯក ផល មាននាទីជាប្រធានអនុសេនាធំ តែក្រោយសមាហរណកម្មរួច គាត់មាននាទីប្រធានអភិរក្សបរិស្ថាន ។ មកដល់បច្ចុប្បន្ននេះ គាត់បានចូលនិវត្តន៍ពីការងារ និងមកធ្វើជាក្រុមប្រឹក្សាស្រុកវិញ ។ រ៉េត មានស្រុកកំណើតនៅភូមិម្ទេស ឃុំស្វាយជុក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ គាត់មានបងប្អូនបង្កើតប្រាំមួយនាក់ ដែលមានឪពុកឈ្មោះ សុខ ស៊ិន (ស្លាប់) និងម្តាយ អ៊ុម វ៉ាយ (ស្លាប់) ។ សព្វថ្ងៃ រ៉េត និងគ្រួសារ មានកូនចំនួនប្រាំនាក់រស់នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

**ឆាង សារះមុនិន្ទ**



កម្មាភិបាលខ្មែរក្រហមផលិតចាន នៅរោងចក្រមួយ ក្នុងទីក្រុងភ្នំពេញ

# យុត្តិធម៌ ពិតជាមានសម្រាប់ជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម

បន្ទាប់ពីថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥ ថ្នាក់ដឹកនាំមួយចំនួនរបស់រដ្ឋការ លន់ នល់ ត្រូវសម្លាប់ភ្លាម បន្ទាប់ពីខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុង ។ ក្នុងនោះដែរមេទាហាន និងពលទាហាន លន់ នល់ រាប់ពាន់នាក់ ក៏ជាគោលដៅដែលខ្មែរក្រហមយកទៅសម្លាប់ក្រោមហេតុផលផ្សេងៗ ។ ជាក់ស្តែង ទិត្យ ស៊ីនឿន ជាអតីតទាហាន លន់ នល់ មួយរូបដែលមានជីវិតរស់ ដោយការលាក់ប្រវត្តិរូបរបស់ខ្លួន ។

ជាយុវជនអាយុ ២៣ឆ្នាំ ស៊ីនឿន បានចូលធ្វើជាទាហាន លន់ នល់ ហ្វឹកហាត់នៅស្វាយស៊ីសុផុន ខេត្តបន្ទាយមានជ័យ ។ បន្ទាប់ពីហ្វឹកហាត់ចប់ មេបញ្ជាការរបស់គាត់បានផ្លាស់គាត់ឲ្យមកឈរនៅវត្តលួង ដែលស្ថិតក្នុងភូមិដាក់បាត ខេត្តពោធិ៍សាត់វិញ ។ នៅឆ្នាំ១៩៧៤ ស៊ីនឿន និងសមាជិកក្នុងក្រុមទាំងអស់២៦នាក់ ត្រូវបានអង្គភាពជ្រើសរើសឲ្យទៅរៀនខាងកាំភ្លើងធំ នៅខេត្តកំពង់ស្ពឺ រយៈពេល៦ខែ ។ បន្ទាប់ពីការហ្វឹកហាត់នេះបានបញ្ចប់ ស៊ីនឿន ត្រូវអង្គភាពបញ្ជូនទៅឈរជើងនៅស្វាយដូនកែវវិញ ដើម្បីប្រយុទ្ធជាមួយខ្មែរក្រហម ហើយក្រោយមកទៀត គាត់ក៏ផ្លាស់ទៅឈរជើង នៅខាងត្រពាំងជង រហូតដល់ថ្ងៃជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ ។

ក្រោយខ្មែរក្រហមកាន់កាប់ប្រទេសទាំងស្រុង ស៊ីនឿន ក៏បានត្រឡប់មកភូមិកំណើតវិញ នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ស្របពេលនោះ ក៏មានការអំពាវនាវពីខ្មែរក្រហមឲ្យអតីតទាហាន លន់ នល់ ទាំងអស់មកចុះឈ្មោះដើម្បីទៅជួបជាមួយអង្គការ និងទៅទទួលសម្តេច ។ មិនត្រឹមតែប៉ុណ្ណោះ ខ្មែរក្រហមក៏បានកុហកទៀតថា បើអ្នកណាពាក់សក្តិប៉ុន្មាន នឹងឲ្យពាក់សក្តិដដែល ដើម្បីចាប់ដៃគ្នាកសាងប្រទេសឡើងវិញ ។ អតីតទាហាន លន់ នល់ ជាច្រើនបានជឿនូវការឃោសនាទាំងអស់នេះ ហើយបាននាំគ្នាទៅចុះឈ្មោះតាមការប្រកាស ។ ជាក់ស្តែងតាមរយៈព្រឹត្តិបត្រសង្ខេបរឿងក្តីការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមលេខ២១ បានចុះផ្សាយអត្ថបទមួយទាក់ទងនឹងសាក្សីមួយរូប ដែលជាអតីតកម្មាភិបាលខ្មែរក្រហម បានប្រាប់ទៅតុលាការទាក់ទងនឹងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃថា «នៅពេលនោះខ្ញុំបានទទួលបញ្ជាពីថ្នាក់វរៈឲ្យជូនដំណឹងទៅតាមអង្គភាពរបស់ទាហាន លន់ នល់ ទាំងអស់ដើម្បីមកប្រជុំនៅសាលាខេត្តពោធិ៍សាត់ ។ ក្រោយពេលប្រជុំរួចទាហាន លន់ នល់ ប្រហែលជាង១០ឡាន ត្រូវបានបញ្ជូនទៅសម្លាប់នៅទួលពោធិ៍ជ្រៃ» ។

តមកទៀតខ្មែរក្រហមក៏ចាប់ផ្តើមឲ្យប្រជាជនទាំងអស់ធ្វើប្រវត្តិរូបរបស់ខ្លួនឡើងវិញ ហើយបានប្រើពាក្យកុហកដដែលថា អ្នកណាធ្វើអ្វីពីមុនមក អង្គការនឹងឲ្យទៅធ្វើការដូចដើមវិញ ។ ទោះបីជាមានការឃោសនាពីបញ្ហានេះជាច្រើនដងមកហើយ ស៊ីនឿន នៅតែមិនប្រាប់ពីប្រវត្តិរូបពិតដែរ នៅខិតខំធ្វើការងារនៅក្នុងភូមិដដែល ។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ អង្គការបានស៊ើបដឹងថា ស៊ីនឿន ធ្លាប់ជាអតីតទាហាន លន់ នល់ ប៉ុន្តែ ដោយគាត់បានដឹងពីរឿងនេះមុន គាត់បានធ្វើពុតជាឈឺពោះ ហើយរត់ទៅភូមិផ្សេងដែលគ្មានអ្នកស្គាល់ និងរស់នៅដោយភាពភ័យខ្លាចជានិច្ច ។

នៅចុងឆ្នាំ១៩៧៦ មេកងបានបញ្ជូនស៊ីនឿនឲ្យទៅលីបាវស្រូវដាក់ក្នុងឃ្លាំង នៅវត្តក្លោកមាស (សព្វថ្ងៃឈ្មោះវត្តក្វាន ហៅវត្តក្លោកមាស) ដែលស្ថិតនៅក្នុងភូមិផ្ទះស្រែ ឃុំស្វាយលួង ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។ នៅវត្តនេះ ខ្មែរក្រហមបានចាប់ផ្សឹកព្រះសង្ឃ ហើយវិហារ និង កុដិ ត្រូវខ្មែរក្រហមយកធ្វើជាកន្លែងដាក់សម្ភារ កន្លែងធ្វើបង្គី នង្គ័ល រនេះ ជាដើម ។ នៅចុងឆ្នាំ ១៩៧៧ ស៊ីនឿន ត្រូវអង្គការផ្លាស់សហករណ៍កណ្តៀង ដោយមាននាទីជាអ្នកវាស់ដីឲ្យប្រជាជនជីក ។ នៅសហករណ៍នោះ គឺលំបាកណាស់ ស៊ីនឿន ធ្លាប់ឃើញខ្មែរក្រហមធ្វើទារុណកម្មប្រជាជនដោយបង្អត់អាហារ ចំពោះអ្នកណាដែលធ្វើមិនបានតាមផែនការកំណត់របស់អង្គការ ។ មនុស្សជាច្រើនបានស្លាប់នៅការដ្ឋានការងារ ដោយសារភាពអត់ឃ្លាន និងជំងឺ ។ អ្នកខ្លះដោយសារតែភាពស្រេកឃ្លានរបស់

ខ្លួន ហ៊ានប្រថុយជីវិតលួចដំឡូង ពោត ឬអ្វីដែលអាចហូបបាន ទោះបីជាដឹងថា ការធ្វើបែបនេះនឹងទទួលពិន័យយ៉ាងធ្ងន់ ឬត្រូវអង្គការយកទៅសម្លាប់ចោលក៏ដោយ ។

នៅឆ្នាំ១៩៧៨ អង្គការបានផ្លាស់ ស៊ីនឿន ពីការងាររាស់ដី ឲ្យទៅធ្វើជាកងពិសេស ដែលមាន តាផុន ជាមេកង ។ ស៊ីនឿន មាននាទីជាអ្នកកាប់ព្រៃនៅភ្នំក្រវាញ តំបន់៧ និងកាប់ឈើយកមកធ្វើរទេះគោ ធ្វើនង្គ័ល ។ រហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមករំដោះ ស៊ីនឿន ក៏ដូចជាប្រជាជនដទៃទៀត គឺមានសេរីភាព និងនាំគ្នាធ្វើដំណើរទៅភូមិកំណើតរបស់ខ្លួនវិញ ។ នៅតាមផ្លូវត្រឡប់មកភូមិកំណើតវិញ គាត់បានជួបជាមួយកងទ័ពវៀតណាមមួយក្រុម ពេលនោះ កងទ័ពវៀតណាមបានសម្គុត និងរកបាញ់គាត់ ព្រោះគិតថា គាត់ជាយោធាខ្មែរក្រហម ប៉ុន្តែដោយសារតែ ស៊ីនឿន ចេះតែលើកដៃឡើងលើ ហើយស្រែកថា "ខ្ញុំកម្ពុជា ៗ ទេ" និងគាប់ជួនមានកងទ័ពវៀតណាមម្នាក់ចេះនិយាយភាសាខ្មែរផង ក៏បានដោះលែងគាត់ឲ្យធ្វើដំណើរទៅមុខទៀត ។ ស៊ីនឿន ក៏បានមករស់នៅជួបជុំជាមួយគ្រួសារនៅភូមិកំណើតវិញ នៅភូមិកណ្ដៀង ឃុំស្យា ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ សព្វថ្ងៃរស់នៅភូមិផ្ទះស្រែ ឃុំស្វាយលួង ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ។

រហូតមកទល់ពេលនេះ ស៊ីនឿន នៅតែឆ្ងល់ក្នុងចិត្តថា តើម្ដាយ និងបងប្អូនរបស់គាត់បានធ្វើអ្វីខុស បានជាខ្មែរក្រហមយកអ្នកទាំងនោះទៅសម្លាប់ដោយគ្មានកំហុសបែបនេះ? រឿងរ៉ាវទាំងនេះនៅតែដក់ជាប់ក្នុងចិត្តរបស់គាត់ ហើយវាក៏ជាអតីតកាលដ៏ជូរចត់មួយសម្រាប់គាត់ដែលមិនអាចបំភ្លេចបានឡើយ ។



យោធាខ្មែរក្រហមប្រយុទ្ធ នៅសមរភូមិមុខ

ក្រោយពីបានចូលរួមស្ដាប់ការប្រកាសសាលក្រមកាលពី ខែសីហា ឆ្នាំ២០១៤ របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ចំពោះសំណុំរឿង ០០២ ដំណាក់កាលទី១ ដែលតុលាការបានធ្វើការសម្រេចដាក់ទោសអតីតមេដឹកនាំខ្មែរក្រហម ខៀវ សំផន និង នួន ជា ឲ្យជាប់ពន្ធនាគារអស់មួយជីវិត សម្រាប់ ស៊ីនឿន គឺពិតជាសប្បាយចិត្តណាស់ ពីព្រោះការឈឺចាប់ចំពោះគាត់ដែលជាជនរងគ្រោះម្នាក់ក្នុងសម័យខ្មែរក្រហម វាពិតជាឈឺចាប់ហួសប្រមាណ ។ បើប្រៀបធៀបនឹងការឈឺចាប់របស់គាត់ដែលទទួលរងពីរបបយង់ឃ្នងមួយនេះ ដាក់ទោសប៉ុណ្ណឹងក៏មិនទាន់គ្រប់គ្រាន់សម្រាប់គាត់ដែរ ប៉ុន្តែ គ្រាន់តែបានស្រាកស្រាន្តខ្លះ ។

ជាចុងក្រោយ ស៊ីនឿន បានសម្ដែងការកោតសរសើរដល់តុលាការខ្មែរក្រហមដែលមានស្មារតីខ្ពស់ក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះទាំងអស់ ក៏ដូចជារូបលោកផ្ទាល់ដែលរង់ចាំការកាត់ទោសនេះអស់ជាច្រើនឆ្នាំមកហើយ ។

**ធួន ឡៃហ៊ុល**

# អ្នករួចរស់ជីវិតពីរបបខ្មែរក្រហម

## *រឿងពិតរបស់ខ្ញុំ*



អ៊ុច ស៊ុនឡាយ

**(តចប់)**

ដោយសារផែនការយុទ្ធសាស្ត្រដ៏ធំរបស់មជ្ឈិមបក្សប្រកបដោយមហិច្ឆតា និងឈានទៅមើលងាយលើវៀតណាមដែលធ្លាប់បង្រៀនសង្រ្គាមឈ្លបមកលើកងទ័ពបដិវត្តន៍កម្ពុជា និងធ្លាប់សាមគ្គីជិតស្និទ្ធជាមួយគ្នា រួមលេណដ្ឋានតែមួយនោះ ក្នុងការវាយពួកចក្រពត្តិ និងពួកបរិវារផងនោះ ទើបវៀតណាមបានវាយបកមកវិញ ចាប់ខ្លួនរាប់សិបនាក់នូវកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ព្រមទាំងបានកម្ទេចរាប់រយនាក់ទៀតផង ។

ផែនការបោសសម្អាត កម្ទេចនេះ ជាពាក្យក្នុងជួរកម្មាភិបាលបដិវត្តន៍សំដៅធ្វើវិសុទ្ធកម្មចលនាបដិវត្តន៍ ព្រោះអង្គការបានលើកដោយអំនួតអួតអាងថា ៖

◆ ការមិនមានការចាយវាយប្រាក់កាសនេះ ជាភាពអស្ចារ្យដែលគ្រប់ប្រទេសលើសកលលោក មិនមានប្រទេសណាអាចធ្វើបានដូចនៅកម្ពុជាទេ ។ ពោល គឺកម្ទេចចោលលោកចាស់ កសាងលោកថ្មី ។

◆ ការលុបបំបាត់សាសនា គ្រប់ជំនឿជាតិសាសន៍ទាំងព្រះពុទ្ធសាសនា យេស៊ូគ្រិស្ត ប្រូតេស្តង់ មូស្លីម ជាដើម សុទ្ធតែត្រូវលុបបំបាត់ និងបោសសម្អាត និងឈានទៅកម្ទេចឲ្យខ្ទេចទៅជាផេះផង់អស់ ។

នោះគឺភាពមហាអស្ចារ្យ មហារុងរឿងរបស់ចលនាបដិវត្តន៍កម្ពុជា ដែលក្រុមកម្មាភិបាលបដិវត្តន៍កម្ពុជា បានឃោសនាផ្សព្វផ្សាយ និងបោះពុម្ពក្នុងទស្សនាវដ្តី "ទង់បដិវត្តន៍" ។ ទន្ទឹមនឹងគោលការណ៍បណ្តេញជនជាតិវៀតណាមឲ្យទៅប្រទេសវិញនោះ ការពិតមិនមែនបណ្តេញដោយស្រួលទៅតាមច្បាប់អន្តរជាតិទេ គឺពួកកងទ័ពចាំសម្លាប់នៅតាមដងផ្លូវឆ្លងកាត់នៅតាមព្រៃ ភ្នំ មិនបានទៅដល់វៀតណាមទេ ។ ចំពោះការនិយាយគ្រាមភាសា ឬភាសាសាមញ្ញក៏ដូចជាកម្មាភិបាលបដិវត្តន៍ ការប្តូរផ្លាស់ និងការធ្វើបដិវត្តន៍ដែរ ។ ឧទាហរណ៍ នំបញ្ចុកទៀក ខ្មែរហៅថា នំអង្កញអណ្តែត, ទូកដរ ខ្មែរហៅថា ទូកចម្លង ។ ក្រោយដែលហៅបងប្អូនជនជាតិវៀតណាមជួបជុំឡើងឡានទៅក្នុងវត្តក្រគរ ដោយគ្មានបងប្អូនកូនចៅណាមកជូនដំណើរឡើយ ។ នោះជាការរំលោភសិទ្ធិដ៏ខ្លាំងក្លាមួយរបស់បដិវត្តន៍កម្ពុជា និងកម្មាភិបាលដឹកនាំដែលទទួលបទបញ្ជាពីមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដើម្បីបោសសម្អាតជនវៀតណាម ឬអ្នកដែលធ្លាប់ជួយ និងសហការជាមួយកងទ័ពវៀតណាមនាពេលកន្លងមក ។

ការជ្រួលច្របល់ផ្នែកផ្លូវចិត្តពីក្នុងចំណោមប្រជាជនតាមសហករណ៍នីមួយៗ ខ្សឹបខ្សៀវគ្នាពីមាត់មួយទៅមាត់មួយ ពីការបញ្ជូនវៀតណាមទៅស្រុកវិញ គេនាំគ្នាថា យួន ដោយមិនឲ្យនិយាយថា វៀតណាមទេ ។ ថ្ងៃមួយនៅពេលដោះគោពីភ្ជួរស្រែហើយ ពូស៊ុម យឿន កងផលិតនៅសហករណ៍ "ក២" ភូមិទួលមនោរម្យបាននិយាយប្រាប់លោកគ្រូ ទូច តាំងឡេង ជាប្រជាជនថ្មីនៅសហករណ៍ជាមួយគ្នាថា "ដឹកគោទៅអូងនៀក" ប្រែថា ដឹកគោទៅដឹកទឹក ព្រោះពាក្យ "អូងនៀក" នេះ ជាភាសាវៀតណាមថា "ដឹក

ទឹក» ។

នៅពេលនោះ មានកងឈ្លបឈ្មោះ ឈឿង បានឮច្បាស់ ហើយហៅឈ្មោះទាំងពីរនាក់ទៅមន្ទីរសន្តិសុខភ្លាម ។ ពេលបាត់មិនឃើញអ្នកទាំងពីរទៅកន្លែងបាយដូចសព្វមួយដង ទើបនាំគ្នាសួរនាំមាត់មួយទៅមាត់មួយទើបដឹងថា អ្នកទាំងពីរត្រូវអង្គការយកទៅរៀនសូត្របាត់ហើយ ។

កាលខ្ញុំទៅបើកបៀវត្សរ៍នៅអធិការបឋមសិក្សាក្រចេះ ខ្ញុំធ្លាប់បានជួបពូទូច តាំងឡេង នៅអធិការដ្ឋានខេត្តក្រចេះ ហើយបាននិយាយនឹងគាត់ ។ គាត់បានសួរនាំពីរឿងបង្រៀនសិស្សនៅភូមិសិរីសុន្ទី ឃុំកន្ទួត និងធ្លាប់រាក់ទាក់គ្នា មិនប្រកាន់អ្នកតូចតាចអីទេ ។ គាត់គឺជាឪពុកបង្កើតរបស់លោកឧត្តមសេនីយ៍ ទូច ណារុថ ជាអតីតស្នងការរាជធានីភ្នំពេញ ។

ការដឹកប្រមូលអាណិកជនវៀតណាមពីគ្រប់សហករណ៍ដោយភូតភរកុហកថា ដឹកទៅប្រទេសវៀតណាមនោះ មិនពិតប្រាកដទេ គឺការបោកប្រាស់ទាំងស្រុង ព្រោះពេលក្រោយមកតៃកុងឡានបានបញ្ជាក់ប្រាប់ថា ជិតភ្នំ៥ពាន់ នៅក្នុងទឹកដីឃុំស្វាយជ្រះ កងទ័ពបញ្ជាឲ្យឈប់ ហើយឲ្យឡានត្រឡប់មកវិញភ្លាម ។ ពេលនោះ កងទ័ពបញ្ជាឲ្យដើរជាជួរ ហើយតម្រង់ទៅជើងភ្នំ ហើយតៃកុងឡាននោះមិនហ៊ាន នៅជិតទៀតឡើយ ខំបើកឡានយ៉ាងលឿនវិលទៅក្រចេះ តំបន់៥០៥ វិញ ។ ក្រោយឆ្នាំ១៩៧៩ អ្នកស្រុកនន កោះស្រកា បានរាយការណ៍ថា មានឆ្អឹងសាកសពនៅជ្រលងភ្នំ៥ពាន់ និងមាននៅកោះស្រកា ជាច្រើន ដោយការនាំជនជាតិវៀតណាមពីក្រចេះ ក្រគរ ឫស្សីចារ ថ្មក្រែ សំបុក កោះទ្រង់យកទៅសម្លាប់នៅជើងភ្នំ៥ពាន់ក្នុងឃុំស្វាយជ្រះ ស្រុកស្នួល ។

ការសម្លាប់ជនជាតិវៀតណាមនេះ មិនសំដៅទៅលើការហៅមកប្រមូលផ្តុំដើម្បីយកទៅកម្ទេចទេ ទោះបី គណៈសហករណ៍ក្តាប់បាននៅសល់មួយនាក់ ពីរនាក់ ឬកូនចៅ ដែលរត់លូនពួនជ្រកនៅទីណាក៏ដោយ ក៏ក្រុមឈ្លបចិត្តឃោរឃៅទាំងនោះ គ្មានអាណិតអាសូរ មេត្តាអ្វីទេគឺឲ្យតែដឹង គណៈសហករណ៍បញ្ជាឲ្យចាប់ យកទាំងយប់ ហើយសម្លាប់ចោលនៅក្នុងព្រៃ មាត់អូរ ក្បាលទំនប់ជាដើម ។

ចំពោះការបែងចែកតំបន់ភូមិភាគគ្រប់គ្រងរបស់អង្គការ គឺតំបន់៥០៥ គឺជាតំបន់ស្វយ័ត មិនចំណុះក្រោមភូមិភាគឦសាននោះទេ គឺផ្ទាល់ទៅមជ្ឈិមបក្សតែម្តង ។ តំបន់៥០៥ នេះ មានស្រុកស្នួល ទាំងមូល ស្រុកសំបូរ និងស្រុកក្រចេះ ។

ឯនៅខាងត្រើយទន្លេមេគង្គ ត្រើយខាងលិច ហៅថា ស្រុកព្រែកប្រសប់មានប្រវែងជាង៤០គីឡូម៉ែត្រ ចាប់តាំងពីមុខស្រុកសំបូរ រហូតដល់ភ្នំសុពណ៌កាឡី គឺស្ថិតក្នុងភូមិភាគកណ្តាល ឬភូមិភាគ២០៣ ។

ចំពោះស្រុកឆ្លូង ដែលពីសង្គមចាស់ស្ថិតក្នុងខេត្តត្រូវបញ្ចូលទៅភូមិភាគបូព៌ា លាតសន្ធឹងយ៉ាងធំទូលាយ មានដូចជា ត្បូងឃ្មុំ ទ្រមូង ឆ្លូង អូររាំងឪ តំបែរ ទឹកជ្រៅ ព្រះស្តេច កំពង់ត្របែក ព្រែកតាមាក់ វិហារសួគ៌ បាភ្នំ មេសាង ពារាំង ពាមរក៍ ពាមជរ៍ ជាដើម ។

ដោយផែនការបណ្តេញវៀតណាម កម្ទេចវៀតណាមនេះជាផែនការសម្ងាត់បំផុត ព្រោះ ប៉ុល ពត ចាត់ទុកថា វៀតណាមជាសត្រូវស្លូវពូជ ម្ល៉ោះហើយគំនិតចិត្ត និងគោលនយោបាយផ្ទៃក្នុងពុំមានពេលរលុប ឬសាបសូន្យថយឥទ្ធិពលសោះឡើយ ។

លោកស្រី ធីបេ ជាម្តាយក្មេករបស់ខ្ញុំ គាត់បានដឹងថា ក្រុមកុម្មុយនីស្ត ប៉ុល ពត ពិតជាមិនសន្តោសប្រណីដល់អ្នកជាប់ខ្សែស្រឡាយកាត់វៀតណាមនេះឡើយ ក៏ប៉ុន្តែ គាត់រស់នៅស្រុកខ្មែរតាំងពីគាត់កើតដល់បច្ចុប្បន្នអាយុជាង៥០ឆ្នាំហើយ ។ គាត់ទៅវត្តធ្វើបុណ្យជាមួយពុទ្ធសាសនិកជនខ្មែរតាំងពីសង្គមចាស់រៀងដរាបមក ពុំដែលប្រកែកប្រណាំង ឬប្រឆាំងអ្វីនឹងរដ្ឋអំណាចសោះឡើយ ។

ចាប់តាំងពីបានឮគេនិយាយគ្នាថា អង្គការហៅជនជាតិវៀតណាមឡើងឡាន បញ្ជូនទៅស្រុកវិញ ប្រមាណមួយខែមុន គាត់ព្រួយបារម្ភ ដេកមិនលក់ បាយមិនបាន ខ្វល់ខ្វាយសព្វគ្រប់ ។ ប៉ុន្តែរកច្រកណាចេញមិនបានឡើយ ទោះបីរត់ មិនដឹងរត់ទៅខាងណា បើកងទ័ព និងកងឈ្លប តាមដានស៊ើបអង្កេត និងយាមល្បាតតាមគ្រប់សហករណ៍ទាំងអស់ រាយបណ្តាក់គ្នាដូចខ្សែយាមតាមមាត់បឹង ។ មានតែរង់ចាំក្តីស្លាប់តែប៉ុណ្ណោះ ទោះបីមិនទាន់ដល់អាយុត្រូវស្លាប់ក៏ដោយ ។

អនិច្ចា! សែនខ្លោចផ្សាណាស់ចំពោះអ្នកដែលរស់នៅតាមសហករណ៍ក្នុងជំនាន់នោះ ពេលរស់បានមួយថ្ងៃមានចិត្តត្រេកអរថា អាត្មាអញរស់បានមួយថ្ងៃ រង់ចាំពេលយប់ មិនដឹងពេលណា

ប្រៀប ដូចត្រីក្នុងត្រក មិនដឹងគេចាប់យកទៅធ្វើម៉ាន?

តាមដឹងពេលក្រោយមក ថាគាត់បានលបលាក់មាសនៅតាមរឹមជើងខោ និងនៅខោទ្រនាប់មួយចំនួន និងមានការផ្តាំផ្ញើកូនចៅ ព្រមទាំងឪពុកក្មេកខ្ញុំឈ្មោះ ចាយ គឹមអេង ហៅ ស្មៀនអ៊ីថា ចាំជួបគ្នាពេលស្រុកសន្តិភាពក្រោយថ្ងៃរំដោះ ពីរបបកុម្មុយនីស្តនេះ ។ គាត់យល់ថា អង្គការ នឹងបញ្ជូនទៅស្រុកវៀតណាម ជាក់ប្រាកដ ព្រោះបើគិតចម្ងាយផ្លូវពីក្រចេះទៅស្រុកស្នួល ចម្ងាយតែ៨០គីឡូម៉ែត្រ ហើយពីស្រុកស្នួល ទៅដល់ព្រំដែនវ៉ាលី មានចម្ងាយតែ១៩គីឡូម៉ែត្រប៉ុណ្ណោះ ។ ផ្លូវឡានបើកតែ២ម៉ោងដល់ព្រំដែន គេចោលនៅទីនោះហើយ ក៏ប៉ុន្តែមិនដឹងទៅជាយ៉ាងណាឡើយ អង្គការមានល្បិចពិសពុលណាស់ ភូតភរ បោកប្រាស់ខ្លាំងណាស់ ។

បញ្ហាវៀតណាមនេះ ជាបញ្ហាក្តៅគគុកណាស់ ព្រោះដួរកម្មាភិបាលបក្ស ប៉ុល ពត បានធ្វើការគាបត្បៀត ប្រៀបធៀបមនុស្សទាំងប្រជាជនថ្មី សុទ្ធតែជាខ្មែរខ្លាំង ខ្មែរយួន ខ្លាំងបង្កប់ ខ្មែរយៈ សេ.អ៊ី.អា កា.ហ្សេ.បេ ម៉្លោះហើយ សូម្បីតែបររទេះភ្លូកបាក់ខូចក៏ត្រូវគេចោទប្រកាន់ថា ខ្មែរយៈខ្លាំងបង្កប់ ។ បើមានគោក្របីស៊ីស្រូវ ដោយការធ្វេសប្រហែសអ្វីមួយ នោះអ្នកមើល អ្នកថែ អ្នកឃ្វាលត្រូវទទួលរងទារុណកម្ម ឬទណ្ឌកម្មមួយមិនអាចលើកលែងបានឡើយ ។

## ១៥) ការបង្កើតសហគមន៍កសិករ

នៅឃុំក្រគរ ទន្ទឹមនឹងមានសហករណ៍ពី «ក១-ក៥» មានការរៀបចំចាត់តាំងបង្កើតសហគមន៍មួយកន្លែង ស្ថិតនៅទួលស្នួល ដែលជាមជ្ឈមណ្ឌលប្រមូលផ្តុំកសិករថ្នាក់ក្រោមប្រមាណ២០គ្រួសារមករស់នៅមួយដុំជាប់ៗផ្ទះគ្នា ក្រោមការជួយឧបត្ថម្ភ និងយកចិត្តទុកដាក់ផ្ទាល់ពីអង្គការថ្នាក់តំបន់៥០៥ ។

សហគមន៍នេះ គ្រប់គ្រងដឹកនាំដោយសមមិត្តនារី រឿន ដែលជាគណៈមូលដ្ឋានចាស់តាំងពីមុនឆ្នាំ១៩៧០មកម្ល៉េះ ។ អ្វីដែលសហករណ៍គ្មាន គឺនៅសហគមន៍មាន ព្រោះបានពីរបស់ជ័យភណ្ឌដែលកងទ័ពទទួលបានពីសមរភូមិមុខ ហើយបញ្ជូនមកសមរភូមិក្រោយ នោះគឺមាននៅសហគមន៍នេះ ទាំងក្រណាត់ មុង តង់ប្រក់ ភ្លៀង អំបិល និង អង្ករ ។

គ្រប់សហគមន៍ទាំងអស់ ដែលមាននៅតាមឃុំដទៃផ្សេងទៀត ក៏មានលក្ខណៈដូចគ្នារបៀបនេះដែរ ។ ចំពោះកូនចៅអ្នកសហគមន៍ ពុំមានមកលេងសើចជាមួយកូនចៅប្រជាជនប្រភេទទី១ ឬទី២ សោះឡើយ បានសេចក្តីថា ក្រុមសហគមន៍ពុំមានធ្វើការលាយឡំ ឬចូលគ្នាជាមួយក្រុមសហករណ៍សោះឡើយ ។

ការបង្កើតសហគមន៍ទាំងនេះ គឺជាឧត្តមភាពខ្ពស់នៃគោលនយោបាយបដិវត្តន៍សម្រាប់ឲ្យកែប្រែជីវភាពនៃកសិករក្រកណ្តាលថ្នាក់ក្រោម និងកសិករក្រថ្នាក់ក្រោមបំផុតឲ្យរីកចម្រើនទាំងជីវភាពសេដ្ឋកិច្ច តាមរូបភាព «ឃ្លោកលិច អំបែងអណ្តែត» ។

ពាក្យសុភាសិត «ឃ្លោកលិច អំបែងអណ្តែត» នាពេលនេះ គឺត្រូវបានអនុវត្តយ៉ាងពេញលេញ ព្រោះឃ្លោកធ្លាប់តែអណ្តែត ឯអំបែងទោះជាអំបែងចាន អំបែងពាង តែងតែលិច ប៉ុន្តែពេលនេះ មានតែសម័យបដិវត្តន៍នេះហើយ ដែលឃ្លោកត្រូវលិច អំបែងត្រូវអណ្តែត ឬថាទឹកឡើង ត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី ។

សហគមន៍នេះ បានមាក់ងាយយ៉ាងចាស់ដៃចំពោះអ្នកនៅសហករណ៍ និងក្រុមប្រវាស់ដៃថា ក្រុមប្អូនៗ ពុំមានសិទ្ធិនិយាយរក ឬជួយផ្តល់យោបល់លើការកសាងទំនប់ ប្រឡាយ ភ្លឺស្រែ ឬសាងសង់ផ្ទះសម្បែងលើចំណុចខុះខាតណាបានសោះឡើយ ។ តាមដឹងតាមរយៈគណៈសហករណ៍បាននិយាយក្នុងអង្គប្រជុំថា «សម មិត្ត ហ៊ូ យន់, ហ៊ូ នឹម និង ខៀវ សំផន» ប្រៀបដូចជាព្រះទាំងបីអង្គដូច្នោះ ព្រោះតាំងពីសង្គមសីហនុមកម្ល៉េះ អ្នកទាំងបី មិនមានបែកបាក់គ្នាទេ គឺវេញត្របាញ់គ្នាជាធ្លុងមួយ ដឹកនាំ និងមគ្គុទេសក៍ចលនាបដិវត្តន៍ដ៏មហារុងរឿងមហាអស្ចារ្យនេះ ។

លោក ហ៊ូ នឹម នោះហើយជារដ្ឋមន្ត្រីទទួលបន្ទុកការងារកែប្រែសង្គមសហករណ៍ភាវូបនីយកម្មដែលជាបដិវត្តន៍ធំធេង កែប្រែជីវភាពកសិករនៅទូទាំងប្រទេស ។ ឯលោក ហ៊ូ យន់ វិញ ក៏ជារដ្ឋមន្ត្រីទទួលការងារកែប្រែសង្គមស្អាតស្អំយុត្តិធម៌យ៉ាងសំខាន់ទាំងការបោះពុម្ពក្រដាសប្រាក់ជាថ្មីឡើងវិញ ពិសេស កម្ទេចលោកចាស់ កសាងលោកថ្មី ទាំងទស្សនៈ និងគោលជំហរអនុវត្ត ។

ដូច្នេះ សន្និដ្ឋានថា លោកទាំងបីនេះ សុទ្ធតែជាក្បាលម៉ាស៊ីនកំពូលនៃចលនាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ នាំទៅបដិវត្តន៍

វប្បធម៌នៃវណ្ណៈអធនដ៏មហាភ្លឺស្វាង មហាជោគជ័យ មហារុងរឿង មហាអស្ចារ្យ ប៉ុន្តែ គួរឲ្យអនិច្ចា និងសែនសង្វេគ នាទីចុងក្រោយនេះ ហ៊ូ យន់ និង ហ៊ូ នឹម បែរជាជាប់ឃុំឃាំងនៅគុកទួលស្លែង និងឈានទៅស្លាប់ខ្លួន ឃ្លាតឆ្ងាយពីលោក ខៀវ សំផន ។ យ៉ាងណាមិញ ខ្សែរយៈលោក ហ៊ូ យន់ ក្តី ហ៊ូ នឹម ក្តី ក៏ត្រូវអង្គការថ្នាក់លើចាប់ខ្លួនទាំងខ្សែៗ និងឈានទៅកម្ទេច ជាបន្តបន្ទាប់ពុំមាននៅសេសសល់សោះឡើយ ។

ដោយឡែក ឪពុកបង្កើតរបស់ខ្ញុំ ក្រោយពេលដែលអង្គការជម្លៀសគាត់ពីផ្ទះឲ្យទៅរស់នៅព្រៃគគីរ ក្នុងឃុំចង្រ្កង់ឲ្យនៅក្នុងក្រុមសាមគ្គីនោះ ។ សូម្បីកូនចៅនៅសហករណ៍ផ្សេងគ្នា ក៏ពុំដែលបានទៅដល់ជួបសន្ទនា សួរសុខទុក្ខអ្វីសោះ ពោលគឺ កាត់ផ្តាច់មនោសញ្ចេតនាអស់រលីងរវាងឪពុកម្តាយ កូន ចៅ ។ នៅពេលដែលគាត់លួចដុតត្រែងមួយសរសៃជំនួសធូប ហើយលួចសូត្រធម៌ ពេលនោះហើយដែលឈ្លបបានតាមដានសកម្មភាពគាត់ ហើយនាំខ្លួនគាត់យកទៅគណៈសហករណ៍បាត់ខ្លួនរៀងរហូត មិនដឹងជាវាយកទៅសម្លាប់ចោលនៅទីណាទេ ។

## ១៦) ការប្តូរផ្លាស់កម្មាភិបាលភូមិភាគ

តាមរយៈការជួបជុំប្រជាជនតាមសហករណ៍នៅរៀងរាល់ខែមានថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ កម្មាភិបាលដឹកនាំសហករណ៍តែងលើកណែនាំពីការងារ គោលដៅការងារ ផែនការអនុវត្តការងារពិសេស សភាពការណ៍ដឹកនាំជារួមនៅតាមតំបន់ និងភូមិភាគ ។

នៅតំបន់៥០៥ ដែលជាតំបន់ស្វយ័តទទួលតែស្រុកក្រចេះ ស្រុកស្នួល និងស្រុកសំបូរ តែប៉ុណ្ណោះ ពុំមានទទួលទូទាំងខេត្តក្រចេះ ឬស្ថិតក្រោមការគ្រប់គ្រងរបស់ភូមិភាគឦសានទេ ។

សមមិត្ត សុន (សាស្រ្តាចារ្យ ស៊ឹម សុន) ត្រូវបានដំឡើងតួនាទីជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសកូរ៉េ ។ សមមិត្តយី (អតីតប្រធាននិស្សិតចម្រើនជឿនលឿន ឈ្មោះដើម ប៊ុន ណាន) ត្រូវបានដំឡើងតួនាទីជាគណៈតំបន់៥០៥ ជំនួសសមមិត្ត សុន ។

សមមិត្ត កង និង កួន ក៏ត្រូវដំឡើងនាទីក្នុងជួរថ្នាក់ដឹកនាំគណៈតំបន់៥០៥ដែរ ។ ដោយឡែក នៅថ្នាក់ភូមិភាគ ក៏មានការប្តូរផ្លាស់ និងដំឡើងតួនាទីពីភូមិភាគមួយទៅភូមិភាគមួយទៀតជាបន្តបន្ទាប់ ។ ចាប់ពីក្រោយឆ្នាំ១៩៧៥ ការប្តូរកម្មាភិបាលមានលេចឮកញ្ជ្រាប់ច្រើនកន្លែង មានពេលខ្លះគណៈសហករណ៍ពុំបញ្ចេញឈ្មោះ និងទីកន្លែងច្បាស់លាស់ទេ គ្រាន់តែកុំឲ្យមាននៅកន្លែងយើងតែប៉ុណ្ណោះ ។ ក្នុងឆ្នាំ១៩៧៧ សភាពការណ៍កាន់តែប្តូរផ្លាស់ខ្លាំងឡើងៗ ការធ្វើវិសុទ្ធកម្មក្នុងជួរបក្សកាន់តែពង្រីង ។ កម្មាភិបាលសហករណ៍បានលើកប្រាប់ជាបន្តបន្ទាប់នូវការក្បត់របស់ថ្នាក់ដឹកនាំបក្សនៅភូមិភាគបូព៌ា ដោយមានចេញឈ្មោះច្បាស់ៗ ព្រមទាំងខ្សែរយៈឈ្មោះ ឈូក, ឌឿន, ចក្រី, ស្រេង និង ឈ្មោះដទៃទៀតជាច្រើន ។

តាមរយៈការចាប់ខ្លួន ការតាមដានខ្សែរយៈ អង្គរក្ស កងការពារ ពិសេសក្រុមគ្រួសារ ប្រពន្ធ កូន ប្តីរបស់កម្មាភិបាលរូបនោះ ។ បញ្ហានេះ បង្កឲ្យមានការប្តូរកម្មាភិបាលពីភូមិភាគឦសានទៅកាន់ភូមិភាគនិរតីដកកម្មាភិបាលពីបូព៌ាមកកាន់ភូមិភាគឦសាន ហើយផ្លាស់កម្មាភិបាលពីភូមិភាគនិរតី មកកាន់ភូមិភាគកណ្តាល និងរំលែកខ្លះទៅភូមិភាគបស្ចិម ឬពាយ័ព្យ តាមការចាត់តាំងរបស់មជ្ឈិមបក្ស ដោយគ្មានប្រកែកប្រណាំងសោះឡើយ ។ ម្យ៉ាងគ្មាននៅសេសសល់កម្មសិទ្ធិអ្វីជាប់ផ្ទាល់ខ្លួនឡើយ ។ កម្មសិទ្ធិសមរម្យមានស្លាបព្រាមួយតូចប៉ុណ្ណោះ ។

## ១៧) ការចាប់ខ្លួនកម្មាភិបាលតំបន់៥០៥ និងគណៈភូមិភាគ

ការជ្រួលច្របល់ក្នុងជួរកម្មាភិបាលដឹកនាំនៅចុងឆ្នាំ១៩៧៧ កាន់តែខ្លាំងឡើងៗ ។ កម្មាភិបាលនៅភូមិភាគឦសានត្រូវចាប់ និងបញ្ជូនទៅស្វាត់បាត់ខ្លួន ហើយយកកម្មាភិបាលភូមិភាគបូព៌ាមកជំនួសវិញ ដោយចោទថា កម្មាភិបាលភូមិភាគឦសាន ក្បត់មជ្ឈិមបក្ស ។

ប្រជាជនយើង បានឃើញផ្ទាល់ភ្នែកនូវការចងអូសសមមិត្ត ញ៉ែម ពុន ដែលជាកម្មាភិបាល នៅខេត្តក្រចេះ អូសដោយជិះរហូតដល់ស្លាប់ ។ ដោយឡែកនៅតាមការដ្ឋានធំៗនៅក្នុងខេត្តក្រចេះ មានមណ្ឌលឧក្រិដ្ឋកម្ម អូរសំពោច, អូរលង និងខ្ទាន់ពីរ មានការផ្លាស់ប្តូរកម្មាភិបាលគ្រប់គ្រងដែលកាចសាហាវ ។ នៅសំរ៉ែងមាត់ព្រែកឆ្លង ឃុំឃ្សឹម និងក្បាលស្នួល ។ ក្នុងស្រុកស្នួល មិនត្រឹមតែផ្លាស់ទេ គឺកម្មាភិបាលទាំងនោះត្រូវប្រែទៅជាអ្នកទោស ជាប់គុកនៅទីនោះហើយធ្វើទារុណកម្មធ្ងន់ទៀត ។ ចំពោះស្រុកសំបូរ មានការដ្ឋានភ្នំស្រួច គោកក្ដួច កោះសុំ ប្រស្រាល និង ក្បាំប៉ែ សុទ្ធសឹងជា

កន្លែងការដ្ឋានក្តៅ ។ ស្រុកព្រែកប្រសប់ ថ្វីត្បិតតែស្ថិតនៅភូមិភាគ ២០៣ ឬភូមិភាគកណ្តាល តែក៏មានការដ្ឋានក្តៅនៅបាក់រទេះ ពិសេស អណ្តូងទឹក ក្នុងវត្តជ្រោយអំពិលជិតភ្នំសុពណ៌កាឡី គឺជាកន្លែងវាយសម្លាប់មនុស្សទម្លាក់អណ្តូងទឹក ឡើងពណ៌ខ្មៅ ខៀវ ចោលក្លិនអសោចយ៉ាងក្រៃលែង ។

ដោយឡែកនៅស្រុកឆ្លូង ដែលជាស្រុកមួយស្ថិតនៅភូមិភាគបូព៌ា ជាភូមិភាគក្តៅខាងការបង្រ្កាប និងសម្លាប់ ដោយចងទាំងខ្សែៗ វាយទម្លាក់បេ៥២ ។ ជនរងគ្រោះទាំងនោះភាគច្រើននាំយកពីឆ្ងាយៗ និងជាខ្សែរយៈនៃកម្មាភិបាលភូមិភាគបូព៌ាផ្ទាល់ ចំពោះឃុំជីផុង មានទីតាំងក្នុងព្រៃមួយកន្លែង ដែលមានសាកសព និងឆ្អឹងជនរងគ្រោះ និងស្លាកស្នាមឧក្រិដ្ឋកម្មដែលទាហាន ប៉ុល ពត បានសម្លាប់ប្រជាជនយើង ។

## ១៨) ថ្ងៃកំណើតរណសិរ្ស

នៅឃុំជើងឃ្លូ ស្រុកស្នួល ខេត្តក្រចេះ តាំងពីក្រោយចាប់ជនជាតិវៀតណាមបញ្ជូនទៅវៀតណាម សភាពការណ៍កាន់តែរឹករវរខ្លាំងឡើងៗ ពិសេស ជួរកម្មាភិបាលនៅមូលដ្ឋាន ។ ការលេចពុការចាប់សមមិត្តនេះ សមមិត្តនោះ ដោយពុក្យត់បក្ស ។

រដូវវស្សា ឆ្នាំ១៩៧៨ ជារដូវដកស្ទូងរបស់កសិករដែលគ្រប់សហករណ៍បានដំណើរការប្រក្រតី ដោយកម្មាភិបាលលើកទិសដៅវាយសម្រុក៣តោនទៅ៧តោនក្នុងមួយហិកតា ។ គ្រប់មុខព្រួញសុទ្ធតែខិតខំធ្វើការងារដោយអនុវត្តតាមផែនការទាំងអស់ ទាំងកងផលិត កងដាំបន្លែ និងកងដឹកជញ្ជូនដោយប្រៀបធៀបខ្លួនយើងម្នាក់ៗទៅនឹងយុទ្ធជនសមរភូមិមុខ ដោយស្មារតីអង់អាចក្លាហានព្យាយាមមុះមុត ត្រៀមប្រយុទ្ធជាប់ជានិច្ច ខាំកកេរ បណ្តាច់ឫសកែវខ្នាំងឈានទៅទទួលជោគជ័យ នៅទីចុងបំផុត ។

ដោយឡែក នៅគ្រប់សហករណ៍ក្រោយដកស្ទូងរួចហើយក្រុមកងផលិតគ្រប់សហករណ៍ត្រូវដកកម្លាំងខ្លះដើម្បីឲ្យកាប់ឫស្សីបង្អែងគ្នោតនៅអូរធ្យូង និងតាមមាត់អូរព្រែកទេ ដើម្បីឲ្យក្រុមឡើងត្នោត ធ្វើស្ករត្នោតសម្រាប់សហករណ៍ ។ ក្នុងចំណោមអ្នកចាត់តាំងត្រូវចេញដំណើរទៅកាប់ឫស្សីធ្វើបង្អែងត្នោតនេះ មានរូបខ្ញុំ ពូស៊ាង នៅ «ក៥» , ញ៉ាវ នៅ «ក៣» និង ប៉ាន់ងួន នៅ «ក៤» ជាដើម ។ ការទៅកាប់បង្អែងត្នោតនេះ បានចាប់ផ្តើមនៅខែតុលា ឆ្នាំ១៩៧៨ តាមផែនការត្រូវក្រសោបឲ្យបាន ១០ក្រសោប ក្នុងរយៈពេល១០ថ្ងៃនេះ ។ ការត្រៀមរៀបចំ មានដាក់ចាន ឆ្នាំងអង្ករ ត្រីប្រឡាក់ផ្អក ទំពាំងជូរ ល្ពុងត្រាំទឹកផ្អក អំបិល សម្រាប់យកទៅហូបតាមទូកនៅតាមអូរ ក្នុងពេលទៅកាប់ឫស្សី បង្អែងត្នោតនោះ ។

ដោយឡែកនៅឯសហករណ៍នោះវិញ អង្គការបានដាក់ទិសជម្លៀសប្រពន្ធកូន អ្នកទៅកាប់ឫស្សី ទាំងអស់គ្នាឲ្យទៅកោះទ្រង់ ដែលស្ថិតនៅចំកណ្តាលទន្លេមេគង្គ ។ គឺក្នុងឱកាសជម្លៀសអ្នកទាំងនោះហើយ ដែលជាពេលវេលានាំមនុស្សយកទៅសម្លាប់នៅរណ្តៅក្បាលកោះទ្រង់ ក្រោមដើមឈើធំមួយ វាយសម្លាប់បំបាត់ពូជ ទាំងកូនក្មេងតូចតាច សរុបមានមនុស្សជាង១០នាក់ ។ អ្នកទាំងអស់នោះមាន ប្រពន្ធខ្ញុំ ឈ្មោះ សា គឹមនី និងកូន៣នាក់, ប្រពន្ធ តុត ញ៉ៅវ ឈ្មោះ សាលី និងកូន ៣នាក់ និងប្រពន្ធរបស់ យិន យឹម ឈ្មោះ អឹម ម៉ាលីន និងកូន២នាក់ ។ នេះបើតាមការនិយាយប្រាប់ពីឈ្មោះ យុត ធុល ជាអ្នកបររទេះនៅភូមិកោះទ្រង់ បាននិយាយឲ្យដឹងថា អង្គការឲ្យគាត់បររទេះដឹកអ្នក៣គ្រួសារ គឺមួយគ្រួសារដឹកមួយរទេះទៅក្បាលកោះទ្រង់ កន្លែងស្ងាត់ ដោយប្រាប់ថា ទៅជួបប្តី ដែលត្រឡប់ពីកាប់ឫស្សីបង្អែងត្នោតវិលមកវិញនៅកំពង់មាត់ទន្លេ ។ ពេលទៅជិតដល់ឈ្លបឲ្យឈប់នៅផ្លូវបំបែកនៅក្នុងព្រៃឫស្សី ហើយដេញចុះភ្លាមៗ ឲ្យបររទេះប្រញាប់ត្រឡប់វិញភ្លាម ។ យុត ធុល បានឃើញកងឈ្លបទាំងនោះមានអាវុធ២នាក់ និងមានអ្នកឯទៀតស្ទុះមកចាប់ដៃប្រទាញប្រទង់ភ្លាមៗ ម្នាក់ទាញស្ត្រីម្នាក់ៗ រៀងៗខ្លួនគ្រប់គ្នា ហើយវាយផ្តួលធាក់អូសនាំទៅរណ្តៅនៅជិតដើមឈើធំមួយ ។

ក្នុងចំណោម ពួកពេជ្ឈឃាដឃោរឃៅទាំងអស់នេះ មានឈ្មោះ អ៊ុក តាំងហ៊ិន ជាមេឈ្លបសាហាវជាងគេ ប្រពន្ធឈ្មោះ ចំរើន ក្រោយមករត់ទៅអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ទល់មុខភ្នំពេញ ។ ក្រោយមក ឈ្លបបានយកសំពត់ខោអាវរបស់អ្នកទាំងនោះ ទៅចែកសហករណ៍វិញ ដោយនិយាយថា «ជ័យភណ្ឌបដិវត្តន៍» ។ នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ប្តីៗដែលចេញទៅបេសកកម្មកាប់ឫស្សីបានវិលមកវិញ បានហៅអ្នកទាំងនោះ មកជួបជុំបំពាក់បំប៉នស្មារតី និងសតិអារម្មណ៍ដោយនិយាយថា «ត្រូវលះបង់ និង

កាត់សាច់ស្អុយចេញឲ្យផុត» ។

ទន្ទឹមនឹងការយកមនុស្សទៅកម្ទេច ឬដាក់មួយដុំតាមការខុទ្ទេសនាមរបស់គណៈសហករណ៍ឈ្មោះ មឿន «ក២» នោះ មានការរៀបចំចាត់តាំងពិធីមង្គលការ ១២គូ ដែលបានប្រារព្ធធ្វើនៅសហករណ៍ «ក៣» ស្ថិតនៅអូរឫស្សី ។ ក្នុងពិធីនេះ មានរៀបចំលោកស្មៀន អ៊ី ជាឪពុកក្មេកខ្ញុំ ជាមួយមីង លេន ដែលជាអ្នកពោះម៉ាយ និងមេម៉ាយ ។ មួយចំនួនទៀត គឺជ្រើសពីគ្រប់សហករណ៍តាំងពី«ក១,ក២,ក៣ ,ក៤ និង ក៥» ក្រោមអធិបតីភាពនៃមេដឹកនាំសហករណ៍ដោយមានចាក់មេក្រូ និងពិធីជប់លៀងស៊ុបគោមួយពេល ពុំមានភ្លេងភ្លាត់អ្វី និងគ្មានញាតិមិត្តបងប្អូនចូលរួមទេ មានតែគណៈសហករណ៍ សហគមន៍ និងកងឈ្លបតែប៉ុណ្ណោះ ។

មិនបានប៉ុន្មានផង លេចព្ញព័ត៌មានថា នៅស្រុកស្នួល មានព្រឹត្តិការណ៍ប្រជុំកងទ័ពតស៊ូ មានធ្វើមីទ្ទីងចាត់តាំងរៀបចំរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅភូមិដើងឃ្លូ ស្រុកស្នួល ដោយមានគោលនយោបាយ ១១ «ខ» គឺ ៩ «ខ» សម្រាប់តំបន់រំដោះ និង ៣ «ខ» សម្រាប់គោលនយោបាយបរទេស ។

ការបញ្ជូនកងទ័ព ដែលបានជ្រើសរើសពីក្នុងសហករណ៍បានជាច្រើននាក់ នៅ «ក២» កន្លែង ដែលខ្ញុំកំពុងរស់នៅមានជាអាទិ៍ៈ ឈ្មោះ វឿន និង ហ៊ាន ជាដើម សុទ្ធតែអ្នកស្ម័គ្រចិត្តយ៉ាងអង់អាចក្លាហានបំផុត ហើយបានឡើងរថយន្តទៅហ្វឹកហាត់រយៈពេលមួយអាទិត្យនៅវាលយន្តហោះ ខេត្តក្រចេះ ត្រៀមទៅវាយវៀតណាមពេលដ៏ខ្លីខាងមុខ ។

ការចាត់បញ្ជូនកងទ័ពពីគ្រប់តំបន់ និងគ្រប់ភូមិភាគដែលស្ថិតជាប់ព្រំដែនប្រទេសវៀតណាមនេះ មានតាំងពីដើមខែតុលា ឆ្នាំ១៩៧៨ ។ ការវាយទន្ទ្រានវាយចូលប្រទេសវៀតណាមនេះ បានចាប់ផ្តើមចូលជ្រៅប្រមាណ៣០គីឡូម៉ែត្រពីព្រំដែន ដោយបានដុតបំផ្លាញអគារ ផ្ទះសម្បែង សម្លាប់ស្ត្រី និងកូនក្មេងជាច្រើននៅខេត្តសុងប៊ែ ខេត្តតៃនិញ និងខេត្តអាងយ៉ាង ជាដើម ។

នៅឯខេត្តក្រចេះ គេបានឮសូរសំឡេងគ្រាប់ផ្លោងគ្រឹមៗ តាំងពីព្រឹកព្រលឹមស្រាងៗរហូតដល់ពេលយប់ជារៀងរាល់ថ្ងៃ ។ មហាជន ប្រជាជន ដែលខិតខំធ្វើការងារតាមសហករណ៍នានាបានខ្សឹបខ្សៀវគ្នាថា សំឡេងផ្គរលាន់ពីទិសបូព៌ាមកហើយ ជាសញ្ញាថានឹងមានអ្នកមានបុណ្យមកជួយរំដោះយើង ក្នុងពេលឆាប់ៗនេះចេញពីស្ថាននរកអវចីនៃរបប ប៉ុល ពត ដែលធ្វើរួម ហូបរួម បំបាត់កម្មសិទ្ធិ និងការបង្ខំឲ្យធ្វើពលកម្មគ្មានស្រាកស្រាន្តនេះ ។ បងប្អូនខ្លះ បានបន់ស្រន់នៅពេលយប់ស្ងាត់ សុំឲ្យកងទ័ពវាយចូលមករំដោះឲ្យបានឆាប់ៗកុំឲ្យងាប់មនុស្សច្រើនពេក ដោយរបបឃោរឃៅព្រៃផ្សៃរបស់ ប៉ុល ពត នេះ ។ របបរស់នៅរយៈកាលជាង៣ឆ្នាំនេះ ធ្វើឲ្យខ្មែរទាំងអស់រស់នៅដូចជាសត្វធាតុ គ្មានលក្ខណៈជាមនុស្សសោះ ព្រោះក្រគ្មានអ្វីសោះ សូម្បីថ្នាំដុសធ្មេញ ច្រាសដុសធ្មេញ សាប៊ូដុសខ្លួន ក្រាសសិតសក់ ក៏គ្មានដែរ ។ ម្ល៉ោះហើយ ម្នាក់ៗមានក្លិនខ្លួនមិនល្អ មិនស្អាត ហាក់ដូចគ្មានអនាម័យសោះ ។ ចំពោះអាហារូបត្ថម្ភ ចំណីអាហារវិញ គឺហូបមិនគ្រប់គ្រាន់ហូបតែបបររាវ វាល់វែក ចែកគ្នាហូប តម្រង់ជួរនៅតាមសហករណ៍សុំយករបប២វែកសម្រាប់ហូប ។ ហេតុនេះ រូបរាងកាយមនុស្សម្នាក់ៗនៅសល់តែស្បែកដណ្តប់ឆ្អឹង ស្គមស្គាំងក្បាលជង្គង់ធំជាងខ្លួន គ្មានកម្លាំងកំហែង សូម្បីតែចងដៃអូស ដួលក្រោកមិនរួចផង ។ ទន្ទឹមនេះ ការភ័យខ្លាច ការបាក់ស្បាត ដោយសារបានឃើញនឹងភ្នែកស្រស់ៗនូវការសម្លាប់មនុស្សទៅក្នុងរណ្តៅ ការគ្មានមេត្តាធម៌ សន្តោសប្រោសប្រណី សូម្បីឃើញជនរងគ្រោះលើកដៃសំពះសុំការអត់ឱន ឬសុំរស់ ក៏ឈ្លប ឬអង្គការមិនអនុគ្រោះដែរ ។

### ១៩) ថ្ងៃ៣០ ធ្នូ ១៩៧៨ រំដោះខេត្តក្រចេះ

កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបង្កើនកម្លាំងខ្លាំងមហិមា ប្រៀបដូចទឹកបាក់ទំនប់ ដោយបានប្រជាជន មហាជនគ្រប់មជ្ឈដ្ឋានទាំងកម្មករ កសិករ យុវជនយុវនារី គ្រប់ជនជាតិបញ្ញវន្តចូលរួមសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម វាយរំដោះកាន់កាប់ស្រុកស្នួលទាំងស្រុង ហើយគ្រប់គ្រងទាំងស្រុងផ្លូវជាតិលេខ៧ ពីស្នួលទៅខេត្តក្រចេះ ក្នុងចម្ងាយផ្លូវរាប់សិបគីឡូម៉ែត្រ ។ កងរថក្រោះរបស់កងទ័ពប្រជាជនរំដោះវៀតណាមរាប់សិបគ្រឿងបានបើកបរតាមផ្លូវជាតិលេខ៧ បុកចូលតម្រង់ក្រុងក្រចេះ ដោយមានរថយន្តដឹកកងទ័ពមកដាក់ទម្លាក់ចោលនៅឃុំកន្ទួត ឲ្យក្រុមថ្មើរជើងវាយសន្ទាប់កងទ័ពខ្មែរក្រហម ។ ដោយឡែក នៅតាមសហករណ៍ចាប់ផ្តើមមានការជ្រួលច្របល់យ៉ាងខ្លាំង ដោយម្នាក់ៗតាមចាប់គោក្របី រកជ្រូក មាន់ ទា និងរកស្រូវអង្ករនៅជង្រុករួម

ផ្ទក ប្រហុកនៅផ្ទះបាយរួម សម្ភារប្រើប្រាស់ទុកដាក់សម្រាប់ក្រុមគ្រួសាររៀងៗខ្លួន ។ ខ្មែរក្រហមបានកៀរប្រជាជនឲ្យភៀសខ្លួនទៅតាមដងទន្លេមេគង្គឲ្យទៅនៅខាងស្រុកសំបូរ និងឲ្យឆ្លងទន្លេមេគង្គទៅត្រើយម្ខាងទៀត ។ ពួកកងទ័ពចាំការពារប្រជាជនទាំងអស់មិនឲ្យខ្មាំងឈ្លានពានបានឡើយ ។ នេះជាសម្ដីរបស់មេបញ្ជាការមកកាន់កាប់ថ្មី ។ ប្រការសំខាន់ មិនដឹងជាយុទ្ធសាស្ត្របៀបណាបានជាអង្គការ ប៉ុល ពត កាន់កាំភ្លើងគ្រប់ដៃ ដេញប្រជាជនឲ្យរត់តាមដងផ្លូវ នាំគ្នាទៅកាន់ខាងស្រុកសំបូរ ដើម្បីឆ្លងទៅត្រើយម្ខាង ខាងភ្នំដី ខេត្តកំពង់ធំ តម្រង់ទៅកាន់សំបុកចុងក្រោយ គឺនៅប៉ៃលិន ដែលជាប៉ុស្តិ៍បញ្ជាការធំបំផុតនៃកម្ពុជាប្រជាធិបតេយ្យ ។

ចំពោះរូបខ្ញុំ និងបងប្អូនមីងមាប្រមាណ៧នាក់មិនរត់ទៅណាទេ គឺសំខាន់គេចឲ្យផុតពីកងឈ្លប ហើយទៅពួនសម្ងំនៅបាតព្រែកក្រគរ ធ្វើយ៉ាងណាឲ្យអង្គការដេញមនុស្សឲ្យផុតទៅ យើងអស់ព្រួយបារម្ភហើយ ព្រោះបើយើងចេះតែរត់មិនដឹងទិសតំបន់មុខជាយើងរត់តាមបណ្ដោយគ្រាប់ផ្លោង មុខជាប្រឈមនឹងស្លាប់ ។

ក្រៅពីឮសូរសំឡេងគ្រាប់ផ្លោងគ្រឹមៗ ទំនងជាធ្លាក់កណ្ដាលទន្លេមេគង្គ ក្នុងបំណងស្ទាក់កុំឲ្យប្រជាជនរត់ឆ្លងទៅត្រើយម្ខាងទៀត ប៉ុន្តែមានប្រជាជនច្រើនបាននាំគ្នាដើររហូតដល់ភូមិក្បាលជ្រួរជិតទៅដល់ស្រុកសំបូរទៅហើយ ។

ខ្ញុំ និងឪពុកមា តែងនិយាយខ្សឹបគ្នា ដើម្បីកុំឲ្យឮសូរសំឡេងកុំឲ្យមានផ្សែងផុត ក្នុងន័យថា លាក់ខ្លួនក្នុងគុម្ពព្រៃឫស្សី តាមដងព្រែកនោះ អាចជាលេណដ្ឋានបានផង និងមិនអាចមានអ្នកណាដឹងទីកន្លែងនោះបានឡើយ ។

នៅពេលរសៀលប្រមាណម៉ោង៣ យើងបានឮសូរសំឡេងមេក្រូស្រែកល្លើយៗពីចម្ងាយ តាំងពីផ្លូវបំបែករង្វង់មូលប៉ុស្តិ៍កុងត្រូលទៅខាងជើង ដោយសំឡេងអំពាវនាវឲ្យប្រជាជននាំគ្នាមកនៅផ្ទះសម្បែង ភូមិកររបស់ខ្លួនវិញ ។ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមបានមករំដោះបងប្អូនពីសហករណ៍ ប៉ុល ពត ហើយ ។ ក្រចេះរំដោះហើយ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៨ នេះហើយ ។

កងទ័ពរំដោះបានចូលកាន់កាប់ខេត្តក្រចេះតាំងពីម៉ោង៩ព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៨ នេះហើយ ។ សំឡេងមេក្រូបន្ទឺខ្សោសនស័ព្ទនៅលើរថយន្តហ្ស៊ីបកាត់មួយគ្រឿង បើកបរយឺតៗតាមផ្លូវជាតិ ហើយមានពេលខ្លះឈប់នៅផ្លូវបំបែក រួចបើកយឺតៗទៅមុខទៀត ដោយសន្សឹមៗ ឈប់នៅមុខវត្តក្រគរយ៉ាងយូរ ដើម្បីអ្នកអាននៅលើឡាន អាចបញ្ចប់ឃ្លាទាំងអស់ ។ ពូ តាំង ឈន មីង ម៉ុត សាវឿន បានឮពេញត្រចៀកទាំងស្រុងនូវឃ្លាប្រយោគនៃការប្រកាសនេះ ។

លុះស្ដាប់ឮច្បាស់គ្រប់ៗគ្នាហើយ ទើបសម្រេចចិត្តព្រមព្រៀងគ្នា ក្រោកចាកចេញពីលេណដ្ឋាន និងជាកន្លែងលាក់ខ្លួនបំពួនអាត្មា នាំគ្នាដើរចេញមកតាមផ្លូវចុងព្រែក ដោយពូ តាំង ឈន នាំដើរមុខ ដោយទឹកមុខរីករាយស្រស់ស្រាយ ។

បន្ទាប់មក គឺអ្នកមីង ម៉ុត សាវឿន ដោយមានទូលបង្វេចខោអាវ និងយួរឆ្នាំងដាំបាយមួយ អ្នកទី៣ គឺឈ្មោះ អាង ឌឿ ដែលជាកូនស្រីពូ តាំងឈន មានស្ពាយថង់មួយចងមាត់ជិតដែលជាកម្មសិទ្ធិរបស់ក្រុមយុវជននៅក្នុងអង្គភាព ហើយដើរក្រោយគេ គឺរូបខ្ញុំមានស្ពាយថង់តូចមួយដែលជាកម្មសិទ្ធិសមរម្យរបស់ខ្លួន ។

ពេលដើរចេញមក ជួបកងទ័ពវៀតណាមម្នាក់ឈរយាមនៅក្រោមម្លប់ដើមស្វាយហោឈប់ ហើយគាត់សួរថា បងទៅណា? មានកងទ័ពខ្មែរយើងតែម្នាក់គត់ក្នុងអង្គភាពនោះ ដែលស្ថិតនៅក្រោមផ្ទះអ្នកស្រុក ស្ថិតនៅប្រមាណ១០ម៉ែត្រពីដើមស្វាយនោះ ។

ពូ តាំង ឈន ឆ្លើយថា ខ្ញុំមកពីស្រែនៅទួលមនោរម្យ ទៅផ្ទះសម្បែងខ្ញុំវិញនៅក្រគរ ព្រោះឮការប្រកាសពីកងទ័ពរណសិរ្ស ។ កងទ័ពខ្មែរ បាននិយាយប្រាប់កងទ័ពវៀតណាម ពីខ្លឹមសារខាងលើ ហើយនាំហៅចូលទៅក្រោមផ្ទះអ្នកស្រុកដែលគ្មានមនុស្សនៅតែកងទ័ពបានមកជ្រកនៅធ្វើការងារនៅខាងក្រោមផ្ទះនោះ ។ ប្រធានធំរបស់កងទ័ពនោះ បានសាកសួរព័ត៌មានសព្វគ្រប់ពីក្នុងការដែលខ្មែរក្រហមបានដេញប្រជាជនឲ្យភៀសខ្លួនទៅត្រើយខាងលិចទន្លេមេគង្គ បើមានអ្នកមិនទៅតាមបញ្ជាទេ ខ្មែរក្រហមនឹងបាញ់សំឡុតឲ្យទៅមុខ និងមិនឲ្យបកក្រោយជាដាច់ខាត ។ រីឯកម្លាំងទ័ពស្រួចបានសម្រុកមកដល់ទីរួមខេត្តក្រចេះ ហើយបានបែងចែកជាពីរមុខព្រួញ គឺមុខព្រួញទី១ ទៅខាងក្រោមប៉ែកឃុំរកាកណ្ដាលចុះនៅចុងខ្សាច់ ឆ្លងទន្លេមុខព្រួញមួយទៀតទៅខាងស្រុកសំបូរតម្រង់ទៅខាងភ្នំដី ។ មុខព្រួញកំពង់ធំបានផ្លោងគ្រាប់ស្ទាក់ប្រជាជនមិនឲ្យ

ទៅខាងដីថៃ ក្នុងលក្ខណៈយ៉ាងរហ័ស និងលឿនណាស់ មិនឲ្យយឺតយ៉ាវខុសពេលវេលា និងយឺតផែនការឡើយ ។

ដោយចុងខែធ្នូ ថ្ងៃ៣០ ៣១ ឆ្នាំ១៩៧៨នេះ ចូលរដូវប្រាំងទឹកទន្លេមេគង្គរីងស្ងួតនៅបាតទន្លេ ងាយស្រួលដល់ការឆ្លងទឹកពីត្រើយខាងកើតទៅត្រើយខាងលិចបានងាយស្រួល ។ ដោយសារការវាយសម្រុកយ៉ាងឆាប់រហ័សចេញពីខាងខេត្តក្រចេះនោះហើយទើបគ្រប់មុខព្រួញបានទៅដល់កំពង់ធំ បាត់ដំបង និងតំបន់ព្រំដែនប្រទេសថៃ បានលឿន និងទប់ស្កាត់ទាន់ពេលវេលាចំពោះការដេញប្រជាជនទៅខាងប្រទេសថៃ ។ មហិច្ឆតាធំធេងនៃកងទ័ពរណសិរ្សបានវាយរំដោះទីតាំងខេត្តដូចជា កំពង់ធំ នៅថ្ងៃ១ មករា ឆ្នាំ១៩៧៩ ខេត្តសៀមរាប នៅថ្ងៃ៣ មករា ឆ្នាំ១៩៧៩ និងតាមបណ្តាខេត្តនានានៅខាងភាគពាយ័ព្យក្នុងដើមខែមករា ១៩៧៩ ចំពោះក្រុងភ្នំពេញ ក៏មានកងទ័ពរណសិរ្សវាយចេញពីខេត្តស្វាយរៀង រំដោះខេត្តព្រៃវែង ឆ្លងកាត់តាមព្រែកតាមាក់ វិហារសួគ៌ រំចូលក្រុងភ្នំពេញ ។

នៅព្រឹកថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ រំដោះភ្នំពេញ ជាថ្ងៃប្រវត្តិសាស្ត្រ ។ ចំពោះសម្តេចព្រះនរោត្តម សីហនុ ត្រូវយោធាប៉ុល ពត ជម្លៀសព្រះអង្គ និងព្រះអគ្គមហេសីចេញពីព្រះបរមរាជវាំងតាំងពីថ្ងៃ៥ មករា ឆ្នាំ១៩៧៩ម៉្លេះ ។ ការដែលយោធាប៉ុល ពត ជម្លៀសព្រះអង្គនាំចេញពីភ្នំពេញមុនកងទ័ពរណសិរ្សចូលដល់នោះហើយ ដែលកម្លាំងកងទ័ពបង្កើនល្បឿនវាយសម្រុកឲ្យបានកាន់តែឆាប់ទៅដល់ជិតក្រុងប៉ៃលិន ដែលជាសំបុកចុងក្រោយរបស់ខ្មែរក្រហម និង គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ។

ក្រោយរំដោះទឹកដីមាតុភូមិកម្ពុជា ជាប្រវត្តិសាស្ត្រនៅថ្ងៃ៧ មករា ១៩៧៩ គណៈចាត់តាំងគណៈសហករណ៍ កម្មាភិបាលដឹកនាំតាមអង្គភាពជាច្រើន ត្រូវបានកងទ័ពរណសិរ្សចាប់ខ្លួនបាន និងនាំទៅប្រមូលផ្តុំមួយកន្លែងត្រៀមដឹកយកទៅអប់រំណែនាំនៅឡុងយ៉ាវ និង ឡុងខាញ់ ប្រទេសវៀតណាម ។

នៅខេត្តក្រចេះ យើងឃើញប្រជាជនបានចង្អុលប្រាប់កងទ័ពនូវឈ្មោះមនុស្សឃោរឃៅ ឈ្មោះកម្មាភិបាលសហករណ៍ឲ្យកងទ័ពវៀតណាមចាប់ខ្លួនយកទៅដាក់នៅវត្តប៉ាំឆា ក្រុងក្រចេះ ហើយមានរថយន្តដឹកជញ្ជូនតាមឡានទៅកាន់វៀតណាម ធ្វើការអប់រំរៀនសូត្ររយៈពេលមួយខែទៅ៣ខែ រួចនាំមកដាក់នៅវត្តប៉ាំឆា ហើយឲ្យធ្វើការរកស៊ីសាមញ្ញនៅផ្ទះ និងភូមិកររបស់ខ្លួនវិញ ។ ក្រោយការរំដោះនៅថ្ងៃ៣០ ខែធ្នូ ១៩៧៨ និងនៅដើមខែមករា ១៩៧៩ ខេត្តក្រចេះបានប្រែមុខមាត់ថ្មី គឺលុបបំបាត់នូវសហករណ៍ហូបបាយរួម ការរស់នៅតាមលក្ខណៈឯកជន បងប្អូនបានវិលមករស់នៅតាមផ្ទះសម្បែង ភូមិកររបស់ខ្លួនវិញ ហើយបងប្អូនដែលមកពីខាងភ្នំពេញក៏ប្រុងប្រៀបរកទូក រកបុស្សីក្តោបជាក្បូន ២-៣ កាត់ជិះបណ្តែតខ្លួនទៅខាងក្រោមរកទឹកដីកន្លែង ភូមិកំណើតរបស់ខ្លួនវិញ ។ អ្នកខ្លះរករទេះគោ ក្របី ដើម្បីដឹកជញ្ជូនកូន ចៅ របស់របរពិសេស អ្នកខ្លះចូលតាមសហករណ៍រកបានស្ករពាង ប្រហុក ផ្អកអំបិល ដើម្បីជាស្បៀងក្នុងការធ្វើដំណើរត្រឡប់ទៅផ្ទះសម្បែងរបស់ខ្លួនវិញ ។

ចាប់ពីក្រោយថ្ងៃ៧ មករា ១៩៧៩ ប្រទេសជាតិ និងប្រជាជន បានរួចផុតពីគ្រោះមហន្តរាយប្រល័យពូជសាសន៍ ប៉ុល ពត លុបបំបាត់សហករណ៍ លុបផ្ទះបាយ គ្មានការបង្ខំឲ្យធ្វើការធ្ងន់ រៀបចំចាត់តាំងរដ្ឋអំណាចភូមិ ឃុំ ស្រុក ខេត្តឡើងវិញ បង្កើតឲ្យមានហេដ្ឋារចនាសម្ព័ន្ធជាតិ មានមណ្ឌលជួយកុមារកំព្រារាប់ម៉ឺននាក់នៅទូទាំងប្រទេស ។ ។

ប្រជាជនបានវិលទៅផ្ទះកំណើត ភូមិកំណើត ជួបជុំម៉ែ បងប្អូនដែលនៅសេសសល់ពីស្លាប់ ប្រជាជនរីករាយក្រៃលែង ។ នៅដើមរដូវវស្សា កសិកររៀបចំភ្ជួររាស់ដកស្ទូងឲ្យទាន់ខែរដូវ ដោយមានភូមិ ឃុំ ជួយចាត់ចែងដីធ្លី ស្រែចម្ការឡើងវិញ តាមរូបភាពក្រុមប្រវាស់ដៃជួយគ្នា អ្នកមានគោម្នាងផ្សំជាមួយអ្នកមានគោ ឬក្របីម្នាង ជួយកម្លាំងពលកម្មដល់ស្ត្រីមេម៉ាយ តាមគោលនយោបាយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។

ទន្ទឹមនេះ គណៈសហករណ៍ចាស់ដែលធ្លាប់ធ្វើការក្នុងរបបនោះត្រូវបានគោលនយោបាយសន្តោសប្រណី ឲ្យរស់នៅធ្វើស្រែចម្ការ និងខ្លះធ្លាប់អប់រំកុមារក៏បានឲ្យនៅបង្រៀនដូចធម្មតាវិញតាមភូមិឃុំនានា ។ ដោយប្រទេសពុំមានការគ្រងរាជ្យពីព្រះមហាក្សត្រម៉្លោះហើយនាមប្រទេសកម្ពុជា គឺត្រូវបានប្តូរទៅជា «សាធារណរដ្ឋប្រជាមានិតកម្ពុជា» ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានបំពេញរចនា

សម្ព័ន្ធចាត់តាំងយ៉ាងប្រញាប់ប្រញាល់ និងរួសរាន់បំផុត ក្នុងការជ្រើសមនុស្សឲ្យធ្វើមេភូមិ អនុប្រធានភូមិ មេឃុំ និងជំទប់ ដោយពុំមានការបោះឆ្នោតអ្វីទេ គឺចាត់តាំងរៀបចំរដ្ឋអំណាច ភូមិ ឃុំ តាមការណែនាំ និងចង្អុលបង្ហាញពីថ្នាក់លើ ។

ទន្ទឹមនឹងនេះ ក្រុមជំនាញការវៀតណាម បានបង្កើនកិច្ចសហការជាមួយកម្មាភិបាលជនជាតិខ្មែរ ដែលមកពីវៀតណាមផ្ទាល់ ។ លោក សំខាន់ ជាប្រធានក្រុមជំនាញការខេត្តក្រចេះ ។ ចំពោះខេត្តក្រចេះ មានលោក ពាន ពន្នី មកពីវៀតណាម ត្រូវបានទទួលការចាត់តាំងជាប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្តក្រចេះ ។ រីឯលោក ដោក ដាន ត្រូវទទួលខាងលេខាបក្សខេត្តក្រចេះ និងមានសមាជិកជាបញ្ជាការយោធា គឺមានលោក ចាន់ សុរិយា និងលោក ទូន ចែម ជាអនុប្រធានយោធាខេត្ត ។ ជាបន្តបន្ទាប់ មានការបើកសន្និបាតរណសិរ្សសាមគ្គីសង្គ្រោះជាតិខេត្តក្រចេះ មានបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការរណសិរ្សខេត្តមាន ៈ លោកស្រី បេង វ៉ែន ជាប្រធាន (អតីតភរិយាកម្មាភិបាលភាគខាងជើង ដែលមានប្រវត្តិត្រូវខ្មែរក្រហមយកទៅសម្លាប់) , ទី២ លោកស្រី សាន ជាអនុប្រធាន ជាកម្លាំងផ្ទៃក្នុង និងមានសមាជិកជាតំណាងកងទ័ព, តំណាងកម្មករ, តំណាងកសិករ, តំណាងបញ្ញវន្ត, តំណាងជនជាតិភាគតិច, ព្រះគ្រូ សៅ សាយ ដែលបានបំពេញផ្នួសឡើងវិញ ជាតំណាងព្រះសង្ឃ សាសនា រីរូបខ្ញុំបាទជាលេខាធិការអចិន្ត្រៃយ៍ប្រចាំការងាររណសិរ្សខេត្តក្រចេះ ទន្ទឹមនេះ ការចាត់តាំងនិងការប្រគល់តួនាទី ខ្ញុំឲ្យទទួលការងារឃោសនាការ វប្បធម៌ និងព័ត៌មានខេត្តថែមមួយទៀត ដោយត្រូវបង្កើតឡើងវិញនូវក្រុមភ្លេងប្រពៃណីបុរាណ និងភ្លេងសម័យមួយក្រុមដែរ ។ រណសិរ្ស និងឃោសនាការខេត្តក៏បានចាប់ផ្តើមបើកការឃោសនា ទាំងយប់ទាំងថ្ងៃ ចុះទៅតាមបណ្តាស្រុកនានាក្នុងខេត្ត គ្រឿងឧគ្ឃោសនស័ព្ទយកទៅផ្សព្វផ្សាយដល់មហាជន ប្រជាជន នៅតាមភូមិឃុំឆ្ងាយៗ មានចុះទៅស្រុកសំបូរ ស្រុកព្រែកប្រសប់ និងស្រុកស្នួល ជាដើម ។ ឃោសនានយោបាយ ១១ "ខ" ពិសេស ចលនាអូសទាញអតីតទាហានខ្មែរក្រហម បាក់ទ័ពដែលនៅពួនសម្ងំនៅក្នុងព្រៃឲ្យចេញមកសារភាព ហើយវិលទៅរួមរស់នៅជាមួយគ្រួសារ ប្រពន្ធកូន បងប្អូន នៅតាមភូមិឃុំកំណើតវិញ ដោយគ្មានយកទោសពៃរ៍អ្វីទាំងអស់ ។ រូបខ្ញុំក៏ស្ថិតនៅក្នុងគណៈចលនាជនវង្វេងផ្លូវថ្នាក់ខេត្ត ដែលមានប្រធាន អនុប្រធាន និងលេខាធិការ គឺរូបខ្ញុំបាទផ្ទាល់ជាអ្នកសរសេររបាយការណ៍បូកសរុបផ្ញើជូនគណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្ត ។

ក្រោយពេលបង្កើតបាន គណៈចលនាជនវង្វេងផ្លូវដែលមានបណ្តាញរហូតស្រុកទាំងប្រាំ ពិសេស រណសិរ្សថ្នាក់ស្រុក ក៏មានរៀបចំជាសាខាតាមស្រុកផងដែរ ។ ការរៀបចំរចនាសម្ព័ន្ធចាត់តាំងមន្ទីរ ក្រសួងនានា មានជាអាទិ៍ ៈ

◆ មន្ទីរខេត្ត គឺសាលាខេត្តចាស់ កាលពីរបបសង្គមចាស់

◆ មន្ទីរបក្ស ជ្រើសយកផ្ទះថ្មល្អស្អាតសល់ពីសង្គមចាស់

◆ មន្ទីររណសិរ្សខេត្ត មន្ទីរអប់រំសិក្សាធិការខេត្ត សុខាភិបាលខេត្ត យុវជនបដិវត្តន៍ខេត្ត មន្ទីរនារីខេត្ត សហជីពខេត្តតំណាងកម្មករ អគ្គិសនីខេត្ត រដ្ឋាករទឹកខេត្ត និងឈានទៅរៀបចំវត្តអារាមតាមខេត្តស្រុកជាបន្តបន្ទាប់ បើកទូលាយជំនឿសាសនាឲ្យប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ ដោយសិទ្ធិសេរីភាព ប្រជាធិបតេយ្យពេញបរិបូរណ៍ ។

ក្រោយមកមានការផ្លាស់ប្តូរឈ្មោះប្រទេសសាធារណរដ្ឋប្រជាមានិតកម្ពុជា ទៅជា "រដ្ឋកម្ពុជា" យោងតាមនយោបាយរបស់រដ្ឋាភិបាលដែលកំពុងឈានទៅជួបចរចារវាងសម្តេចព្រះនរោត្តម សីហនុ និងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកាលនោះ សមមិត្ត ហ៊ុន សែន ជានាយករដ្ឋមន្ត្រីនៃរបបរដ្ឋកម្ពុជា ។ ចាប់ពីក្រោយថ្ងៃ២ ធ្នូ ១៩៨៧ មានការចរចានៅ Fer Antoi de NOIRE ប្រទេសបារាំង ឈានទៅដល់ការសុំយាងវិលនិវត្តន៍មកវិញរបស់សម្តេចព្រះនរោត្តម សីហនុ និងព្រះអគ្គមហេសី ព្រមទាំងព្រះរាជវង្សានុវង្សមួយចំនួនផង ក្នុងគោលបំណងអនុវត្តនូវគោលនយោបាយផ្សះផ្សា បង្រួបបង្រួមជាតិ អនុវត្តតាមសន្ធិសញ្ញាសន្តិភាព ២៣ តុលា នៃក្រុងប៉ារីស ចំពោះការដោះស្រាយបញ្ហាកម្ពុជា ។

ការរៀបចំបោះឆ្នោតដោយមាន អ៊ុន តាក់ (អង្គការសហប្រជាជាតិ) ធ្វើឡើងនៅគ្រប់ខេត្ត ក្រុង ស្រុកនៅទូទាំងប្រទេស តាមសំណើរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ មានព្រះនរោត្តម សីហនុ ជា ព្រះប្រធាន ។

ពេលនោះ ដែលសម្តេច ព្រះនរោត្តម សីហនុ បានថ្លែងការណ៍នៅព្រះបរមរាជវាំង បញ្ជាក់ពីការរស់នៅសម័យ ប៉ុល ពត ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលក្រោយពីការសុំលាលែងពីព្រះប្រធានរណសិរ្សកាលពីឆ្នាំ១៩៧៦ បញ្ជាក់ថា ៖

“ប៉ុល ពត បានដាក់គុកព្រះអង្គ និងព្រះមហេសីឲ្យរស់នៅក្នុងផ្ទះតូចមួយក្នុងព្រះបរមរាជវាំង ហើយដាក់បញ្ញត្តិ និងហាមមិនឲ្យដើរចេញក្រៅពីវាំង មិនឲ្យមានការជួបជាមួយទូត ឬឯកអគ្គរដ្ឋទូតណា ទោះបីមានលិខិតពីក្រៅប្រទេសចូលមកទាក់ទងជាមិត្តភាពជាមួយព្រះអង្គ ក៏អង្គការបំបិទបំបាត់សិទ្ធិទាំងអស់ ជាពិសេសដាច់ខាតមិនឲ្យច្បាប់ ឬបើកសិទ្ធិលិខិតឆ្លងដែនអ៊ី វីសាអ៊ី ដើម្បីចេញទៅបរទេសបានសោះឡើយ” ។

ពេលនោះហើយ ដែលរដ្ឋកម្ពុជាយើងត្រូវបានប្តូរនាមឈ្មោះសាជាថ្មីទៅជា “ព្រះរាជាណាចក្រកម្ពុជា” ជាលើកទីពីរឡើងវិញ ។ ការនេះ សភាពនេះ របត់នយោបាយបែបនេះ គ្មានប្រទេសជាតិណា នៅលើសកលលោកនេះ មានការវិវត្ត និងឈានពីមានព្រះមហាក្សត្រប្រែជាគ្មានស្តេច ហើយទីចុងបំផុត ឈានទៅជាមានព្រះមហាក្សត្រគ្រងរាជ្យនៅលើព្រះរាជបល្ល័ង្កឡើងវិញសោះឡើយ ។

ព្រះរាជាណាចក្រកម្ពុជា បានពង្រីកអត្តិភាពនយោបាយទាំងកិច្ចការពារ កសាងជាតិឡើងវិញ ក្រោមព្រះរាជកិច្ចដឹកនាំនៃព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ក្នុងការបង្រួបបង្រួមជាតិ សាជាថ្មី ។ យ៉ាងណាមិញ រដ្ឋធម្មនុញ្ញនៃអតីតរដ្ឋកម្ពុជា និងបណ្តាស្ថាប័ន ដូចជា រដ្ឋសភា ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ត្រូវបានកែសម្រួល និងរៀបចំធ្វើវិសោធនកម្មឡើងវិញ ទាំងរដ្ឋកិច្ច ត្រូវដូរទៅជារាជកិច្ច ទទួលស្គាល់សាជាថ្មីនូវរាល់សេចក្តីសម្រេច ព្រះរាជក្រម រាជក្រឹត ពិសេស ព្រះនាមរបស់សម្តេចព្រះ នរោត្តម សីហនុ ទៅតាមសភាពដើមកាលពីសម័យព្រះរាជាណាចក្រកម្ពុជាទី១ ឡើងវិញទាំងស្រុង ។

បើពិចារណាទៅ ការផ្លាស់ប្តូររបបនយោបាយមានដល់ទៅ ៥-៦របបនយោបាយ ក្នុងពេលជាង១០ឆ្នាំកន្លងទៅនេះ ដែលខ្ញុំបានឃើញ ទទួលស្គាល់ និងបានរស់នៅឆ្លងកាត់ក្នុងជីវិត ។

**អ៊ុច ស៊ុនឡាយ**

# ដំណឹងស្វែងរកឪពុក

ខ្ញុំបាទឈ្មោះ ព្រា ភារុន កើតឆ្នាំ១៩៦០ មានស្រុកកំណើតនៅភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ សព្វថ្ងៃរស់នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ខ្ញុំបាទមានបងប្អូន៥នាក់ (ស្រី២នាក់ ប្រុស៣នាក់) និងមានម្តាយឈ្មោះ នួន គឹមហៀង សូមប្រកាសរកឪពុក ឈ្មោះ ព្រា ហង្សរី កើតឆ្នាំជូត ។ មុនរបបខ្មែរក្រហម ឪពុកខ្ញុំធ្វើជាពិធីការសាលាក្រុងសៀមរាប ផ្នែករៀបចំបុណ្យជាតិ ។ ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ខេត្តសៀមរាប ក៏ដូចជាភូមិស្រុកដែលគ្រួសារខ្ញុំរស់នៅគឺភូមិទ្រាំង ។ ខ្មែរក្រហមបានស៊ើបដឹងថា ឪពុកខ្ញុំជាអតីតអ្នករដ្ឋការ ធ្វើការនៅសាលាខេត្ត ។ នៅយប់មួយចន្លោះពីថ្ងៃ១៧ ដល់ ១៩ មេសា ឆ្នាំ១៩៧៥ ខ្ញុំចាំមិនច្បាស់ ខ្មែរក្រហមបានមកហៅឪពុកខ្ញុំពីផ្ទះទាំងយប់ ដោយមិនប្រាប់ថាទៅណាទេ ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង និងស្គាល់ពីឪពុកខ្ញុំឈ្មោះ ព្រា ហង្សរី នេះ សូមទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទខ្ញុំបាទផ្ទាល់លេខៈ ០១៦ ៥១៨ ៧៨៧

***សូមអរគុណ!***

# ការកម្ទេចខ្មាំងរបស់អង្គការ

### សេចក្ដីផ្ដើម

កាលពីជាងសាមសិបឆ្នាំកន្លងទៅ ប្រជាជនកម្ពុជាគ្រប់រូប ដែលធ្លាប់ហែលឆ្លងក្នុងរបបខ្មែរក្រហម ពិតជាបានជួបប្រទះនូវសោកនាដកម្មរាប់រយជំពូក រួមមាន ការបង្ខំមនុស្សឲ្យធ្វើការជាទម្ងន់ ការបង្អត់អាហារ ការធ្វើទារុណកម្ម និងការសម្លាប់ជាដើម ។ អនុស្សាវរីយ៍ដ៏សោកសង្រេងបែបនេះ កើតមានមិនត្រឹមតែនៅក្នុងខេត្តកំពង់ចាមមួយប៉ុណ្ណោះទេ ប៉ុន្តែវាបានកើតមាននៅគ្រប់តំបន់ទូទាំងប្រទេសកម្ពុជា ដែលបណ្ដាលអោយប្រជាជនកម្ពុជាជាង ២លាននាក់ ត្រូវបាត់បង់ជីវិត ។ ចំពោះព្រឹត្តិការណ៍បញ្ចប់សោកនាដកម្មដោយឧក្រិដ្ឋកម្មគឺជាព្រឹត្តិការណ៍តូចមួយនៃប្រវត្តិសាស្ត្រមនុស្សជាតិដ៏គួរឲ្យព្រឺខ្លាច និងអាណោចអាធ័មបំផុត អំពីការធ្វើឃាតមនុស្សដ៏ផុយស្រួយ ដែលបានប្រព្រឹត្តឡើងដោយផ្ទាល់ពីសំណាក់មិត្តភក្តិ និងបងប្អូនរបស់ខ្លួន ដោយមានមូលដ្ឋានផ្ដើមចេញពីខ្មែរក្រហមបានគំរាមកំហែង និងប្រព្រឹត្តអំពើឧក្រិដ្ឋកម្មដ៏ឃោរឃៅលើជីវិតមនុស្សអស់រាប់សិបនាក់ ។

ព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់នេះ កើតមាននៅភូមិព្រែកអណ្ដូង ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ នាខែមករា ឆ្នាំ១៩៧៨ គឺក្នុងអំឡុងពេលដែលអង្គការកំពុងចាប់ខ្លួន និងសម្លាប់យ៉ាងរង្គាលចំពោះបងប្អូន ដែលអង្គការកំពុងស្វែងរកចាប់ខ្លួនប៉ុន្តែចាប់ពុំទាន់បាននៅឡើយ ហើយបានរីករាលដាលកាន់តែធំឡើងៗជាបន្តបន្ទាប់ ពីគ្រួសារមួយទៅគ្រួសារមួយ រួមទាំងប្រជាជនផ្សេងៗទៀត ដោយសារខ្មែរក្រហមបានស្រាវជ្រាវទៅតាមចម្លើយសារភាពរបស់អ្នកទោសមុនៗ ដែលនាំឲ្យវិនាសហិនហោច ខ្ទេចខ្ទីជាមួយនឹងការបំបែកពីសមាជិកគ្រួសារផង ។

សកម្មភាពសម្លាប់មនុស្សរបស់ខ្មែរក្រហមនៅពេលនោះ បានធ្វើឡើងដោយការកម្ទេចផុតពូជតែម្ដង សូម្បីកូនង៉ែតក៏មិនទុកដែរ ។ ដូច្នេះឃើញថា ហេតុការណ៍នេះកើតឡើងដោយសារមានអំពើព្រៃផ្សៃច្រើនរូបភាព និងស្មុគស្មាញ ។ យើងពិតជាពុំអាចដឹងបានគ្រប់ជ្រុងជ្រោយទេ ។ តែទោះយ៉ាងណាក្ដី ខ្ញុំសូមសាកល្បងរៀបរៀងហេតុការណ៍នេះ តាមអ្វីដែលខ្ញុំបានជួបក្នុងវ័យកុមារ និងសាកល្បងស្រាយបញ្ហាមួយចំនួន សម្រាប់ជាវិភាគទានជូនមិត្តអ្នកអានពិចារណា ។

### ១) ប្រធានភូមិជាសមាជិករណសិរ្ស

ក្នុងរបបខ្មែរក្រហម ភូមិព្រែកអណ្ដូង ស្ថិតនៅឃុំព្រែកក្របៅ ស្រុកកងមាស តំបន់៤១ ភូមិភាគឧត្តរដែលមាន កុយ ធួន ជាអ្នកគ្រប់គ្រងភូមិភាគនេះ ។ នៅក្នុងឆ្នាំ១៩៧៧ ឈ្មោះភូមិភាគឧត្តរ បានដូរទៅជាភូមិភាគកណ្ដាលនៅក្រោមការគ្រប់គ្រងរបស់ កែ ពក ។

នៅឃុំខ្លះនៅស្រុកកងមាស ដូចជា ឃុំព្រែកក្របៅ ការបែងចែកកម្លាំងមនុស្សឲ្យទៅធ្វើការ នៅតាមសហករណ៍របស់ខ្មែរក្រហមបានចាប់ផ្ដើមអនុវត្តតាំងពីមុនពេលចូលកាន់កាប់ទីក្រុងភ្នំពេញមកម៉្លេះ ។ ប្រជាជនបានទៅធ្វើការរួម ប៉ុន្តែនៅដើមដំបូងការប្រមូលផលបានបែងចែកតាមកម្លាំងពលកម្ម និងជាបណ្ដើរៗឈានទៅប្រមូលផលទុករួម និងហូបបាយរួម នៅពេលបានគ្រប់គ្រងអំណាចពេញទី ។ ដោយឡែកចំពោះប្រជាជនមួយក្រុមទៀត ដែលធ្លាប់បានចូលរួមនៅក្នុងចលនារណសិរ្សរួបរួមជាតិកម្ពុជាមុនពេល ប៉ុល ពត បានកាន់អំណាច អង្គការបានប្រមូលផ្ដុំឲ្យទៅធ្វើការ នៅក្នុងសហករណ៍មួយដោយឡែក ដោយបានប្រគល់ដីព្រៃមួយកន្លែងឲ្យក្រុមនេះ កាប់គាស់រានសម្រាប់ធ្វើស្រែចម្ការ នៅដោយឡែកពីគេដែរ ។ ក្នុងនោះមានលោក ឃុត ខាន់ ដែលជាមនុស្សដ៏សំខាន់ម្នាក់ក្នុងចំណោមមនុស្សសំខាន់ៗជាច្រើននាក់ទៀតនៅក្នុងសហករណ៍ពិសេស និងជាសមាជិករណសិរ្ស ត្រូវបានខ្មែរក្រហមតែងតាំងជាប្រធានកង៤(ប្រធានភូមិ) ប្រចាំភូមិព្រែកអណ្ដូង (នាពេលនោះសម័យរណសិរ្ស) ។ បេក្ខភាព ខាន់ ក្នុងឋានៈជាប្រធានកងនេះ គឺជាមនុស្សទីមួយហើយដែលខ្មែរក្រហមបានជ្រើសរើសសម្រាប់ជាកម្មាភិបាលរបស់គេ ដោយមានឈ្មោះ យ៉ា សាន ជាអនុប្រធាន និងជាលេខាធិការផង ។ ប៉ុន្តែ ខាន់ បានកាន់កិច្ចការជាប្រធានកង

បានតែប៉ុន្មានខែ អង្គការបានដកភារកិច្ចគាត់ឲ្យមកកាន់ជាប្រធានក្រុមផ្នែកកសិករ្សរាស់ និងដកសួនវិញ ។ ចំណែក តំណែងប្រធានកងត្រូវជំនួសដោយសមមិត្ត ស្មោះ នៅក្នុងដំណាក់កាលមួយនៃការកែប្រែក្នុងជំហានលោតផ្លោះនៅចុងឆ្នាំ១៩៧៥ ។

នេះគឺជាពេលវេលាដ៏សំខាន់មួយនៃការបើកទំព័រសកករាជថ្មី ដែលបង្ហាញឲ្យឃើញកាន់តែច្បាស់ក្នុងការប្រែក្លាយពីសហករណ៍បែងចែកផលតាមកម្លាំងពលកម្ម ឲ្យទៅជាការប្រមូលផលទុករួម និងសាគមន៍ប្រជាជនដោយការធ្វើមេស៊ីរួម រួមជាមួយនឹងការប្រមូលចានឆ្នាំងដាក់ឃ្លាំងរួម និងលុបបំបាត់ការចាយលុយ ដើម្បីឲ្យប្រជាជនរស់នៅស្មើភាពគ្នា គ្មានអ្នកមាន គ្មានអ្នកក្រ ដែលខ្មែរក្រហមតែងទន្ទេញជាប់មាត់ថាជា "សង្គមគ្មានវណ្ណៈ" ។

នៅឆ្នាំ១៩៧៦ អង្គការបានរៀបចំធ្វើប្រវត្តិរូបថ្មីមួយ ដើម្បីឲ្យដឹងអំពីសមាសភាពប្រជាជនមូលដ្ឋាន ប្រជាជនថ្មី ឆ្នាំ១៩៧៣-១៩៧៥ និងដើម្បីស្វែងរកមនុស្សដែលមានប្រវត្តិរូបស្មុគស្មាំ ។

ដូច្នេះ គឺចាប់តាំងពីពេលនេះមក ការបញ្ជូនកម្មាភិបាលភូមិឃុំខ្លួនដើម្បីឲ្យទៅរៀនសូត្រ ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ក្នុងនោះមានសមមិត្ត ស្មោះ, ផល, ហុន និងសមមិត្ត សែន សាន ជាដើម ដែលអង្គការបានតែងតាំងជាប្រធានភូមិព្រៃកអណ្តូងនេះជាបន្តបន្ទាប់គ្នា បន្ទាប់ពី យុត ខាន់ ហើយអ្នកទាំងនេះ គ្មានបុគ្គលណាម្នាក់បានវិលត្រឡប់មកស្រុកភូមិវិញឡើយ ។ រីឯបុគ្គលទាំងឡាយ ដែលជាសមាជិករណសិរ្ស ក៏ត្រូវបានខ្មែរក្រហមចាប់ខ្លួនបញ្ជូនឲ្យទៅរៀនសូត្រស្មើរទាំងអស់ដែរ នៅឆ្នាំ១៩៧៧ ។

## ៧) គេចខ្លួន

ជាមួយនឹងការបញ្ជូនខ្លួនកម្មាភិបាលភូមិឃុំ ឲ្យទៅរៀនសូត្រ អង្គការក៏បានស្រាវជ្រាវរកឃើញថា អតីតសមាជិករណសិរ្សភាគច្រើនធ្លាប់បានចូលបម្រើជាទាហានកំណែននៅសម័យ លន់ នល់ ។ ដូចនេះ ការចាប់ខ្លួនមនុស្សទាំងនេះ ត្រូវបានអនុវត្តជាហូរហែដែលការបើកឆាកចាប់ខ្លួនមុនគេគឺ យុត ខាន់, ពាង សេង និងមនុស្សមួយចំនួនទៀត ។

នៅខែកញ្ញាឆ្នាំ១៩៧៧ វេលាម៉ោង៤រសៀល ទាហានអាវខ្មៅចំនួនពីរនាក់មានអាវុធជាប់ដៃ បានមកតាមចាប់ខ្លួនសមមិត្ត ខាន់ រួមទាំងសមមិត្ត ពាង សេង ក្នុងពេលអ្នកទាំងពីរកំពុងដើរពិនិត្យមើលក្រុមបន្តុបផ្លើនផល កំពុងដកស្ទូងស្រូវបណ្តោញទឹកនាវដូវទឹកសម្រកខាងត្បូងភូមិ ដោយនិយាយថា អង្គការឲ្យទៅរៀនសូត្រ ។

យោធាអាវខ្មៅបានបណ្តើរអ្នកទាំងពីរឲ្យមករង់ចាំនៅក្រោមដើមស្វែងធំខ្ពស់មួយដើម ដោយពុំទាន់បានចាប់ចងនៅឡើយ ដើម្បីរង់ចាំខ្លួគេដែលទៅតាមចាប់ខ្លួនអ្នកទោសផ្សេងទៀត ។ ដោយសារនៅទីកន្លែងនោះមានព្រៃឫស្សី និងព្រៃរនាមយ៉ាងច្រើនដុះនៅតាមបណ្តោយមាត់អូរដ៏វែងមួយដែលស្ថិតនៅក្រោយភូមិ ។ ឱកាសនោះ ខាន់ បានធ្វើកលជាសុំទៅជុះអាចម៍ ហើយក៏បានគេចខ្លួននៅពេលនោះតែម្តង ។ យុត ខាន់ បានរត់ទៅពួនសម្ងំលាក់ខ្លួននៅក្នុងព្រៃរនាមក្រាស់មួយកន្លែងឈ្មោះថា "អ្នកតាដំបងក្រញូង" អស់រយៈពេលជាច្រើនថ្ងៃ ។ ជាមួយគ្នានេះ លោកយាយ វ៉ន់ វ៉ាង អាយុ៧៧ឆ្នាំ ធ្លាប់រស់នៅក្នុងភូមិព្រៃកអណ្តូងនេះជាយូរមកហើយ មានប្រសាសន៍ថា "ខាន់ អាចគេចខ្លួនផុតពីភ្នែកទាហានអាវខ្មៅ ដោយសារគាត់ចេះមន្តអាគមបំបាំងកាយ" ។ នេះជាហេតុផលប្រពៃណីដ៏សមរម្យមួយដែរ ព្រោះ ខាន់ តែងដាក់កូនសៀវភៅមន្តអាគមតាមខ្លួនជានិច្ច ។

ពេលត្រឡប់មកវិញ និងដឹងថា ខាន់ គេចខ្លួនបាត់គេបានតាមរកអស់រយៈពេលយ៉ាងយូរ ប៉ុន្តែរកពុំឃើញឡើយ ។ ទាហានអាវខ្មៅក៏បានបណ្តើរអ្នកទោសទាំងពីរនាក់ ដែលបានចាប់ខ្លួនមកកាន់រោងបាយ បន្ទាប់មកបានចាប់ចងដៃទាំងពីរទៅក្រោយ និងបញ្ជាឲ្យឡើងជិះរទេះសេះ រួចដឹកយកទៅទិសខាងត្បូងសំដៅទៅសាលាស្រុកកងមាសបាត់ទៅ ។

តាមសម្តីប្រពន្ធ ពាង សេង បានឲ្យដឹងថា មុនពេលចាប់ខ្លួន សេង បាននិយាយប្រាប់ប្រពន្ធថា គាត់នឹងមិនរស់ទេ ព្រោះអង្គការពិតជាមកចាប់ខ្លួនគាត់មិនខាន ។ ពេលនោះ គាត់ក៏មិនរត់ដែរ គឺសុខចិត្តស្លាប់តែម្នាក់ឯងចុះដើម្បីឲ្យប្រពន្ធ និងកូនស្រីទាំង៦នាក់របស់គាត់បានរស់នៅរហូតមកដល់សព្វថ្ងៃនេះ ។

ពិតមែនហើយទោះបីវិញ្ញាណក្ខន្ធរបស់ សេង អាចសោយសុខបានមួយផ្នែក ប៉ុន្តែ នៅមានមួយផ្នែកទៀតនឹងទទួលលទ្ធផលផ្ទុយពីនេះ ពីព្រោះគាត់ត្រូវខ្មែរក្រហមចាប់ខ្លួនយកទៅសម្លាប់ចោលដោយពុំដឹងមូលហេតុ ។

រីឯ យុត ខាន់ ក្រោយពីគេចខ្លួន និងពួនសម្ងំនៅកន្លែងខាងលើ

បានមួយរយៈរួចមក គាត់បានផ្លាស់ប្តូរទីកន្លែងលាក់ខ្លួនមួយទៅមួយជាញឹកញាប់ដើម្បីកុំឲ្យអង្គការចាប់ខ្លួនបាន ដោយទទួលបានការផ្គត់ផ្គង់ស្បៀងអាហារតាមរយៈប្រពន្ធ និងក្រុមសាច់ញាតិរបស់គាត់ ដែលបានលួចយកបបរពីរោងបាយ និងពេលខ្លះមានអង្ករ អំបិល ឬប្រហុកជាដើម ។ ក្នុងពេលដកស្ទូងអ្នកស្រី សុខ អៀ ប្រពន្ធរបស់គាត់តែងលួចយកពេលវេលាកំបាំងពីភ្នែកកម្មាភិបាលខ្មែរក្រហម ដើម្បីដើររាវខ្យងក្តាមនៅតាមបឹង ឬអូរនានាមកស្ងោរលាក់យកទៅឲ្យប្តីរបស់អ្នកស្រីរៀងរាល់ពេលទាំងព្រលឹមចុងសក់ ។ អ្នកភូមិដែលបានធ្វើការជាមួយគាត់បានដឹងគ្រប់គ្នា ប៉ុន្តែបានជួយលាក់រឿងនេះ ព្រោះគ្មានអ្នកស្រុកភូមិណាម្នាក់ស្អប់ ឬមានគំនុំជាមួយ ខាន់ នោះទេ ។ អ្នកទាំងនោះភ័យខ្លាចតែម្យ៉ាង គឺអង្គការអាចនឹងចោទថា ជួយលាក់បាំងខ្មាំងតែប៉ុណ្ណោះ ។

សភាពការណ៍ចាប់ផ្តើមតឹងតែង ព្រោះអង្គការចាប់ផ្តើមសង្ស័យអ្នកស្រុកភូមិ ជាពិសេស គឺគ្រួសារ ខាន់ អំពីការលួចយកស្បៀង ។ ចាប់តាំងពីពេលនេះមក យុត ខាន់ ទំនងជាគេចខ្លួនទៅក្នុងព្រៃនាស្រុកចំការលើ ដែលក្នុងរយៈពេលនោះ ប្រជាជនភូមិព្រែកអណ្តូងទាំងមូល បានជួបប្រទះនៅយុគដ៏ខ្មៅងងឹត ដោយសារកម្មាភិបាលខ្មែរក្រហមបានតាមដានយ៉ាងយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នបំផុត ។ មិនតែប៉ុណ្ណោះ ប្រជាជនទាំងនេះបានក្លាយទៅជាគោលដៅនៃការចោទប្រកាន់ថា ជាក្រុមក្បត់ប្រឆាំងនឹងអង្គការ និងប្រឈមមុខនឹងការចាប់ខ្លួន ។ សូម្បីកម្មាភិបាលភូមិ ឃុំក៏ត្រូវប្រឈមមុខនឹងការចោទប្រកាន់ដូចគ្នាដែរ ។

### ៣) សភាពការណ៍ក្តៅគគុកនៃការចាប់ខ្លួន

ក្រោយមកប្រមាណមួយខែបន្ទាប់ពី ខាន់ ត្រូវបាត់ខ្លួនភាពមន្ទិលសង្ស័យរបស់អង្គការបានឈានទៅរកការចាប់ខ្លួនតាមរូបភាពចោទប្រកាន់ថាជា "អ្នកផ្តល់ស្បៀងអាហារ ជួយលាក់បាំង ឬឃុបឃិតជាមួយខ្មាំង" ដែលខ្មែរក្រហមបានចាត់ទុកថា ជាអំពើក្បត់យ៉ាងធ្ងន់ធ្ងរ និងជាគោលដៅដែលត្រូវកម្ទេចចោល ។ ទន្ទឹមនឹងការចោទប្រកាន់បែបនេះ អង្គការបានចាប់ខ្លួនប្រពន្ធ ខាន់ និងកូនស្រីគាត់អាយុ៦ឆ្នាំម្នាក់ទៀត យកទៅឃុំឃាំងនៅមន្ទីរសន្តិសុខ គុកវត្តអូរត្រកួន ប៉ុន្តែខ្មែរក្រហមពុំទាន់សម្លាប់ភ្លាមៗនៅឡើយទេ គឺខ្មែរក្រហមបានទុកមួយរយៈដើម្បីសួរចម្លើយរកខ្សែបណ្តាញឲ្យអស់ ។

ដោយសារការធ្វើទារុណកម្មសួរចម្លើយធ្ងន់ធ្ងរពេក អៀ មិនត្រឹមបានឆ្លើយដាក់ក្រុមគ្រួសារ និងអ្នកស្រុកភូមិប៉ុណ្ណោះទេ សូម្បីតែឪពុកបង្កើតរបស់ខ្លួនក៏បានឆ្លើយដាក់ដែរថា បានលួចយកអង្ករផ្តល់ឲ្យ ខាន់ ដែរ ។ តាមពិត ឪពុករបស់គាត់មិនបានធ្វើអ្វីសោះជាងនេះទៅទៀត តាសុខ ចាស់ជរាណាស់ទៅហើយ ។

តាមរយៈការឆ្លើយសារភាពរបស់ អៀ គឺក្នុងរយៈពេលតែពីរ ឬបីសប្តាហ៍ អង្គការបានចាប់ខ្លួនក្រុមគ្រួសាររបស់គាត់ និងអ្នកស្រុកភូមិអស់ជាច្រើនគ្រួសារ ។ ការចាប់ខ្លួននេះកើតមានជាបន្តបន្ទាប់ និងមានទំហំធំធេងហើយជ្រៅទៅៗ ព្រោះអង្គការបានចាប់ខ្លួនជាខ្សែសង្វាក់ និងទាំងគ្រួសារតែម្តង ។ ទោះបីកូនដែលទៅធ្វើការតាមកងចល័តនានា ក៏អង្គការតាមចាប់យកទៅសម្លាប់ទាំងអស់ រួមទាំងកូនងែតនៅបៅទឹកដោះផង ។ គឺគ្រាន់តែនៅភូមិព្រែកអណ្តូងមួយប៉ុណ្ណោះ ចំនួនមនុស្សដែលខ្មែរក្រហមចោទថា ជាខ្មាំង និងបានចាប់ខ្លួនយកទៅកម្ទេចចោលដោយមូលហេតុខាងលើនេះមានចំនួនជិត ៣០ នាក់ ទាំងប្រុសស្រីក្មេងចាស់ កូនងែតដែលនៅបៅទឹកដោះនៅឡើយ ។ ចំនួននេះពុំបានរាប់បញ្ចូលចំនួនប្រជាជនរាប់សិបនាក់ទៀតដែលខ្មែរក្រហមបានចាប់ខ្លួន យកពីភូមិនោះទាំងគ្រួសារៗ ទៅកម្ទេចចោលនៅគុកវត្តអូរត្រកួន និងនៅកន្លែងដទៃទៀត ។ ក្នុងនោះ មានទាំងប្រជាជនមូលដ្ឋាន និងប្រជាជនជម្លៀសដោយពុំដឹងមូលហេតុ ។

យោងតាមសម្តីអ្នកស្រី ខេង ស្រ៊ុម អតីតអ្នកទោសខ្មែរក្រហម ដែលធ្លាប់ជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខវត្តអូរត្រកួន ក្នុងរយៈពេល៤ខែ និងធ្លាប់ធ្វើជាចុងភៅសម្រាប់អ្នកទោស នៅក្នុងគុកនេះ បាននិយាយថា "អៀ បានឆ្លើយដាក់សាច់ញាតិ និងអ្នកស្រុកភូមិ រួមមានៈ គ្រួសារ ចាប, គ្រួសារ នៅ យៀន និងគ្រួសារ ហូ ព្រមទាំងឪពុកបង្កើតរបស់គាត់ម្នាក់ទៀតឈ្មោះ សុខ ដែលមានអាយុជាង៦០ឆ្នាំ ។ គ្រួសារ ប៊ូ ចាប មានសមាជិក៨នាក់, គ្រួសារ នៅ យៀន មានសមាជិក៦នាក់, គ្រួសារ សន ហូ មានសមាជិក៥ នាក់ និងសែន សាន ជាប្រធានភូមិព្រែកអណ្តូង ព្រមទាំងលោក ស្រឿន ម្នាក់ទៀត ។

មនុស្សទាំងអស់នេះ ត្រូវបានខ្មែរក្រហមយកទៅកម្ទេចចោលនៅក្នុងគុកវត្តអូរត្រកួនទាំងអស់ ។ ខាងក្រោមនេះ គឺជាដំណើររឿងនៃការចាប់ខ្លួនគ្រួសារទាំងនេះ និងមនុស្សមួយចំនួនទៀតៈ

### ក) គ្រួសារ ប៉ូ ចាប

គ្រួសារ ចាប ត្រូវអង្គការចាប់ខ្លួនដោយបានចោទប្រកាន់ថា មានគំនិតក្បត់ មិនព្រមប្រាប់ទីកន្លែងលាក់ខ្លួនរបស់ខ្មាំងជូនអង្គការ ព្រមទាំងបានជួយចិញ្ចឹមបាយថែមទៀត ព្រោះកូនប្រុសរបស់គាត់ឈ្មោះ ចាប ក្តិប ដែលមានអាយុជាង១០ឆ្នាំ បានលួចយកបបរពីរោងបាយ ទៅឲ្យ ខាន់ដល់ទីកន្លែងលាក់ខ្លួនជាច្រើនសប្តាហ៍ ។

ដំបូងខ្មែរក្រហមបានចាប់ខ្លួនគ្រួសារ ចាប មានចំនួនតែ៥ នាក់ប៉ុណ្ណោះ ក្នុងនោះមាន ប៉ូ ចាប ប្រពន្ធឈ្មោះ យុត យ៉េន និងកូនប្រុស ៣នាក់ រួមមាន ចាប ក្តិប, ចាប ជិន និង ចាប គា បណ្តើរឲ្យឡើយជិះរទេះសេះដោយមានចងដៃទៅក្រោយ ទាំងប្តីប្រពន្ធ និងកូនប្រុសម្នាក់ៗ ទៀត គឺ ចាប ក្តិប ដែលជាមនុស្សសំខាន់ ។ ក្នុងនោះគ្រួសារ ប៉ូ ចាប នៅសល់កូនរបស់គាត់ចំនួន៥ នាក់ទៀត ដែលខ្មែរក្រហមពុំទាន់បានចាប់ខ្លួន ប៉ុន្តែអ្នកទាំងនោះត្រូវបាននាំខ្លួនទៅនៅពេលក្រោយ ដែលខ្ញុំនឹងជម្រាបជូននៅទំព័រខាងក្រោម ។

លោក ប៉ូ ចាប ត្រូវក្រុមសន្តិសុខយកទៅធ្វើទារុណកម្មសួរចម្លើយយ៉ាងសាហាវ ព្រៃផ្សៃ និងវេទនាក្រៃលែង ។

តាមសម្តីអ្នកស្រី ខេង ស្រ៊ីម អតីតអ្នកទោសខ្មែរក្រហម បានឲ្យដឹងថា «អា ហន មកពីភូមិភាគនិរតី និង អា បុត មកពីខេត្តកំពង់ធំ បានយក តាចាប ទៅវាយសួរចម្លើយរហូតបាក់ដៃទាំងពីរ និងឲ្យមានដំបៅរលួយ ហើយធ្លាក់ស្មាទាំងសងខាងហើមពោរ ដោយសារតែយកទៅបង្ហូតរ៉ៃត ។ ជាមួយនឹងការចោទប្រកាន់របស់អង្គការចំពោះគ្រួសារ ចាបដូចខាងលើនេះ ខេង ស្រ៊ីម ក៏បាននិយាយដោយដកស្រង់សម្តីរបស់ យុត យ៉េន ប្រពន្ធ ចាប ថា «ថ្ងៃនោះកូនខ្ញុំឃ្លាន! ខ្ញុំបានទៅសុំបបរពីរោងបាយឲ្យកូនខ្ញុំស៊ី ពេលនោះ មីក្បៀ បានឲ្យយកបបរទៅឲ្យ ខាន់ ប្តីវាស៊ី ដែលបានលាក់ខ្លួននៅកន្លែងបបុស ។ ខ្ញុំមិនដឹងថា វាក្បត់ខ្ញុំសោះ!» ។ សម្តីទាំងនេះ គឺជាការបង្ហាញនូវភាពស្មោះត្រង់ និងការសោកស្តាយ ព្រមទាំងបញ្ជាក់នូវក្តីអស់សង្ឃឹមដែលថា ក្រុមគ្រួសាររបស់គាត់មានកំហុសចំពោះអង្គការដែលមិនអាចរួចផុតពីការប្រហារជីវិតរបស់អង្គការឡើយ ។

ទន្ទឹមនឹងនេះលោក សាន រីម អតីតអ្នកទោសខ្មែរក្រហមនៅគុកវត្តអូរត្រកួន រយៈពេល១៥ថ្ងៃ ធ្លាប់បានភ្លក់រសជាតិអំពីវិធីសាស្ត្រសួរចម្លើយរបស់សន្តិសុខនៅទីនេះដែរ បានអះអាងថា ប្រធានសន្តិសុខឈ្មោះ អាហន និងអនុប្រធានឈ្មោះ អាបុត ដែលអ្នកទាំងពីរគឺជាអ្នកគ្រប់គ្រងសន្តិសុខ និងអ្នកទោសនៅវត្តអូរត្រកួន ព្រមទាំង ជាអ្នករិះរកសួរចម្លើយ និងធ្វើទារុណកម្មអ្នកទោសផងនោះ ទំនងជាបានយក តាចាប ទៅធ្វើទារុណកម្មសួរចម្លើយយ៉ាងសាហាវឃោរឃៅ និងធ្ងន់ធ្ងរបំផុតដូចជាយកគល់ពីងពង់វាយគ្រប់កន្លែង ទើបបណ្តាលឲ្យដៃទាំងពីររបស់គាត់បានបាក់មានដំបៅរលួយ និងមានវិធីផ្សេងទៀត ដូចជា ចងដៃទាំងពីរទៅក្រោយ ហើយថ្ពក់ចុងដៃ និងបង្ហូតរ៉ៃតឡើងលើខ្ពស់ដល់ដំបូលសាលារៀន (កន្លែងសួរចម្លើយ) បន្ទាប់មកទម្លាក់ចុះជាច្រើនដង ។ បើនៅតែមិនបានចម្លើយ វានឹងបង្ហូតឡើងបន្តទៀតហើយព្យួរទុកយ៉ាងយូរ ទើបបណ្តាលឲ្យធ្លាក់ស្មាទាំងសងខាងបែបនេះ ។

ដូច្នេះគ្រួសារ ប៉ូ ចាប ដែលខ្មែរក្រហមចាប់ខ្លួនទាំងពូជយកទៅធ្វើទារុណកម្មយ៉ាងវេទនា និងសម្លាប់ចោលយ៉ាងសាហាវឃោរឃៅបែបនេះគឺដោយសារមូលហេតុចោទថា បានចិញ្ចឹមបាយ ខាន់តែម្យ៉ាងប៉ុណ្ណោះ ដែលជាអំពើមួយអយុត្តិធម៌បំផុតសម្រាប់គ្រួសាររបស់គាត់ ។

### ខ) គ្រួសារ នៅ យៀន

គ្មានប្រភពណាបានដឹងច្បាស់លាស់អំពីមូលហេតុនៃការចាប់ខ្លួនគ្រួសារ នៅ យៀន និងការធ្វើទារុណកម្មបែបណានោះទេ ព្រោះថា ខេង ស្រ៊ីម គ្រាន់តែបាននិយាយថាបានជួបគ្រួសារ នៅ យៀន ទាំងប្តីប្រពន្ធ និងកូនដែលខ្មែរក្រហមបានចាប់យកទៅឃុំឃាំងនៅគុកវត្តអូរត្រកួនមួយរយៈ ដែលក្រោយមក ខ្មែរក្រហមបានយកទៅសម្លាប់ចោលទាំងអស់គ្មានសល់ម្នាក់ឡើយ ។ ចំណែកអ្នកស្រី ស៊ិន ឡៃអ៊ី អ្នកស្រុកភូមិព្រែកអណ្តូងបាននិយាយថា «ខាត់ ស៊ឹម ប្រពន្ធ នៅ យៀន គឺជាប្រធានរោងបាយផ្នែកនារី ត្រូវបានអង្គការចាប់ខ្លួនទាំងគ្រួសារ ដោយចោទប្រកាន់ថា បានរួមគំនិតក្បត់ក្នុងការនាំយកស្បៀងអាហារពីរោងបាយទៅឲ្យឈ្មោះ ខាន់ ដែរ ។

នៅពេលចាប់ខ្លួននោះ នៅ យៀន នៅសល់កូនស្រីពីរនាក់ទៀត ដែលម្នាក់មានជំងឺខ្វិនជើងទាំងសងខាង និងម្នាក់ទៀតនៅធ្វើការក្នុងកងកុមារ ដែលខ្មែរក្រហមពុំបានបញ្ជូនខ្លួននៅឡើយ ។ ប៉ុន្តែពេលក្រោយមក ទើបខ្មែរក្រហមយកអ្នកទាំងនោះទៅតាមក្រោយ ។

**(នៅមានត) ហេង កុសល**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៤ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.


A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 179, 2014 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.